ABA BANK

NATIONAL BANK OF CANADA GROUP

របាយការណ៍ប្រចាំឆ្នាំ

២០២៥

របាយការណ៍
ប្រចាំឆ្នាំ
២០២៥

ខ្លីៗ អំពី ធនាគារ ABA

ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ធនាគារ ABA) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៦។ យោងតាមរបាយការណ៍ត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ចាប់ពីឆ្នាំ ២០២១ ដល់ ២០២៥ នាពេលបច្ចុប្បន្ននេះ ABA គឺជាធនាគារពាណិជ្ជដ៏ធំជាងគេនៅកម្ពុជា ផ្អែកលើទ្រព្យសកម្មសរុប, ប្រាក់បញ្ញើអតិថិជន, កម្ចី និងប្រាក់ចំណេញសុទ្ធ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ធនាគារ ABA បម្រើសេវាកម្មហិរញ្ញវត្ថុយ៉ាងពេញលេញដល់អតិថិជនជាច្រើន រួមមាន សហគ្រាសធុនតូច និងមធ្យម, អាជីវកម្មខ្នាតមីក្រូ និងរូបវន្តបុគ្គល តាមរយៈសាខាទាំង ១០៤, ស្ម័យសេវា ABA ២៤/៧ ចំនួន ៤៥ ទីតាំង, ម៉ាស៊ីនស្ម័យសេវាជាង ១,៩០០ នៅទូទាំងប្រទេស ព្រមទាំងកម្មវិធីធនាគារតាមទូរស័ព្ទដៃ និងសេវាធនាគារអនឡាញដ៏ទំនើប។

ធនាគារមេរបស់ ABA គឺធនាគារជាតិកាណាដា ដែលមានទ្រព្យសកម្មប្រមាណ ៤៤៧ ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៦ និងមានបណ្តាញធនាគារឆ្លើយឆ្លងដ៏ធំទូលាយនៅទូទាំងពិភពលោក។ ធនាគារនេះមានទីស្នាក់ការកណ្តាលនៅទីក្រុងម៉ុងរេអាល់ (Montreal) និងមានសាខានៅស្ទើរតែគ្រប់ខេត្តនៃប្រទេសកាណាដា ដោយបម្រើអតិថិជនចំនួន ៣,១ លាននាក់។ មូលបត្ររបស់ធនាគារជាតិកាណាដា ត្រូវបានចុះបញ្ជីក្នុងផ្សារភាគហ៊ុនតូរ៉ុនតូ (TSX: NA) ហើយមូលធននីយកម្មទីផ្សាររបស់ធនាគារនេះមានទំហំរហូតដល់ ៤៦,៥ ពាន់លានដុល្លារអាមេរិក។

STANDARD &POOR'S

ចំណាត់ថ្នាក់លទ្ធភាពសងកម្រិត **"B+"** ពីទីភ្នាក់ងារវាយតម្លៃឥណទាន Standard & Poor's (S&P) Global Ratings អនាគត **"ស្ថិរភាព"**

១៦,២ ពាន់លានដុល្លារអាមេរិក
ទ្រព្យសកម្មសរុប

១២,៩ ពាន់លានដុល្លារអាមេរិក
ប្រាក់បញ្ញើសរុប

៩,៦ ពាន់លានដុល្លារអាមេរិក
កម្ចីដុលសរុប

២,៧ ពាន់លានដុល្លារអាមេរិក
មូលធនរបស់ភាគហ៊ុនិក

៣៧៧,៦ លានដុល្លារអាមេរិក
ប្រាក់ចំណេញសុទ្ធ

១០.៣១៣ នាក់
បុគ្គលិក

១០៣ សាខា

៤៥ ទីតាំង
ស្ម័យសេវា

មាតិកា

១	សាររបស់នាយកប្រតិបត្តិ	៤
២	អំពីធនាគារ ABA	៦
	អំពីយើងខ្ញុំ	៨
	ចក្ខុវិស័យ បេសកកម្ម គុណតម្លៃ	៩
	ពានរង្វាន់	១០
	ធនាគារអន្តរការី	១១
	ការគូសបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ	១២
	លទ្ធផលហិរញ្ញវត្ថុ	១៣
	បណ្តាញសាខា	១៤
៣	អភិបាលកិច្ចសាជីវកម្ម	១៦
	ភាគហ៊ុនិក	១៧
	មហាសន្និបាតប្រចាំឆ្នាំរបស់ភាគហ៊ុនិក	១៧
	រចនាសម្ព័ន្ធអភិបាលកិច្ចសាជីវកម្ម	១៨
	ក្រុមប្រឹក្សាភិបាល	២០
	កិច្ចប្រជុំក្រុមប្រឹក្សាភិបាល	២២
៤	វិភាគទានសង្គមរបស់សាជីវកម្ម	២៣
៥	របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម	៣២

១

សាររបស់នាយកប្រតិបត្តិ

ជូនចំពោះភាគទុនិក វិនិយោគិន អតិថិជន និងដៃគូជាទីគោរព

ធនាគារ ABA បានឈានចូលឆ្នាំ ២០២៥ ដោយមានជំហរដ៏រឹងមាំមួយ ហើយក៏បានបញ្ចប់ឆ្នាំជាមួយនឹងលទ្ធផលដ៏លេចធ្លោជាច្រើនទៀត។ ដោយមានយុទ្ធសាស្ត្រច្បាស់លាស់, ការអនុវត្តការងារប្រកបដោយវិន័យ, និងទំនុកចិត្តពីអតិថិជនរាប់លាននាក់ ABA បានបន្តពង្រីកភាពឈានមុនរបស់ខ្លួននៅក្នុងវិស័យធនាគារនៅកម្ពុជា ខណៈសម្រេចបានកំណើនប្រកបដោយចីរភាព នៅទូទាំងបណ្តាញប្រតិបត្តិការរបស់ខ្លួន។

សមិទ្ធផលហិរញ្ញវត្ថុរបស់យើង បានឆ្លុះបញ្ចាំងពីទំនុកចិត្តរបស់អតិថិជនមកលើ ABA ក្នុងនាមជាជ្រើសដៃគូដែលពួកគាត់ពេញចិត្ត។ ទ្រព្យសកម្មសរុបសម្រេចបានជាង ១៦ ពាន់លានដុល្លារ, ប្រាក់បញ្ញើអតិថិជន សម្រេចបានជិតដល់ ១៣ ពាន់លានដុល្លារ, និង ផលបត្រប្រាក់កម្ចីដុល បានដល់ ៩,៦ ពាន់លានដុល្លារ។ មូលដ្ឋានដើមទុនដ៏រឹងមាំ សន្ទនីយភាពប្រកបដោយសុខភាព និងប្រាក់ចំណេញប្រកបដោយសង្គតិភាពរបស់យើង បានផ្តល់នូវមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការរីកចម្រើននាពេលអនាគត និងភាពធន់រយៈពេលវែង។

ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ABA បានវិវត្តពីគ្រឹះស្ថានហិរញ្ញវត្ថុប្រពៃណី ទៅជាអេកូស៊ីស្តែមហិរញ្ញវត្ថុដ៏ទូលំទូលាយពេញលេញ ដែលគាំទ្រដល់ជីវភាពប្រចាំថ្ងៃរបស់អតិថិជន និងការរីកចម្រើនរបស់អាជីវកម្មនានានៅទូទាំងប្រទេសកម្ពុជា។ វឌ្ឍនភាពនេះ បានបន្តពេញមួយឆ្នាំ ២០២៥ នៅពេលដែលយើងបានពង្រឹងផ្លេតហ្វមឌីជីថលរបស់យើងបន្ថែមទៀត ដោយពង្រីកសមត្ថភាពសេវាកម្មរបស់យើង និងណែនាំដំណោះស្រាយថ្មីៗ ដែលត្រូវបានបង្កើតឡើងដើម្បីធ្វើ ឲ្យសេវាធនាគារកាន់តែងាយស្រួល, លឿនជាងមុន, និងអាចប្រើប្រាស់បានគ្រប់ៗគ្នា។

ការរីកចម្រើនរបស់ធនាគារយើង គឺស្របពេលដែលមានការពង្រីកជាបន្តបន្ទាប់នៃសេវាធនាគារសាជីវកម្ម និងពាណិជ្ជកម្មរបស់យើង។ អាជីវកម្មនាពេលបច្ចុប្បន្ននេះ ត្រូវការច្រើនជាងការផ្តល់ហិរញ្ញប្បទានបែបប្រពៃណី។ ពួកគាត់ស្វែងរកដៃគូធនាគារ ដែលមានសមត្ថភាពគាំទ្រដល់តម្រូវការប្រតិបត្តិការ ហិរញ្ញប្បទាន និងពាណិជ្ជកម្មកាន់តែទំនើប។ ធនាគារ ABA បានបន្តពង្រឹងសមត្ថភាពរបស់ខ្លួននៅទូទាំងវិស័យទាំងនេះ ដោយផ្តល់ជូននូវដំណោះស្រាយដ៏ទូលំទូលាយដល់អាជីវកម្មគ្រប់ទំហំ - ចាប់ពីសហគ្រាសធុនតូច និងមធ្យម និងសហគ្រាសដែលកំពុងរីកចម្រើន រហូតដល់សាជីវកម្មក្នុងស្រុកធំៗ និងវិនិយោគិនអន្តរជាតិ ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

ពេញមួយឆ្នាំ ២០២៥ យើងបានពង្រីកការគាំទ្ររបស់យើងបន្ថែមទៀត សម្រាប់វិស័យសំខាន់ៗនៃសេដ្ឋកិច្ចតាមរយៈការផ្តល់ប្រាក់កម្ចីសាជីវកម្ម, ហិរញ្ញប្បទានពាណិជ្ជកម្ម, ហិរញ្ញប្បទានគម្រោង, ដំណោះស្រាយទូទាត់, និងសេវាកម្មគ្រប់គ្រងសាច់ប្រាក់។ យើងនៅតែប្តេជ្ញាផ្តល់ជូនអាជីវកម្មនូវលទ្ធភាពទទួលបានដើមទុន, ជំនាញ, និងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ដែលត្រូវការដើម្បីវិនិយោគ ពង្រីក បង្កើតការងារ និងចូលរួមចំណែកដល់ការអភិវឌ្ឍរយៈពេលវែងរបស់ប្រទេសកម្ពុជា។

ក្នុងនាមជាធនាគារពាណិជ្ជធំជាងគេនៅក្នុងប្រទេស យើងទទួលស្គាល់ថាទំនួលខុសត្រូវរបស់យើង លើសពីការផ្តល់សេវាហិរញ្ញវត្ថុ។ វិស័យធនាគារដ៏រឹងមាំ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ការវិនិយោគ និងទំនុកចិត្តរបស់សាធារណជន។ តាមរយៈការគ្រប់គ្រងហានិភ័យដោយប្រុងប្រយ័ត្ន ការវិនិយោគជាបន្តបន្ទាប់លើបច្ចេកវិទ្យា និងការអនុវត្តអាជីវកម្មប្រកបដោយការទទួលខុសត្រូវ ធនាគារ ABA នៅតែប្តេជ្ញាគាំទ្រដល់ស្ថិរភាព និងវិបុលភាពរយៈពេលវែងរបស់ប្រទេសកម្ពុជា។

ដោយសម្លឹងទៅឆ្នាំ ២០២៦ យើងនៅតែមានសុទិដ្ឋិនិយមប្រកបដោយភាពប្រុងប្រយ័ត្នជានិច្ច។ បរិយាកាសសេដ្ឋកិច្ចសកល និងថ្នាក់តំបន់ នៅតែបន្តបង្ហាញពីភាពមិនប្រាកដប្រជា ហើយអាជីវកម្មនានានៅទូទាំងវិស័យជាច្រើនកំពុងជួបបញ្ហាប្រឈមជាច្រើន។ យ៉ាងណាក៏ដោយ មូលដ្ឋានគ្រឹះរយៈពេលវែងរបស់ប្រទេសកម្ពុជានៅតែរឹងមាំ ដោយមានការគាំទ្រពីវិស័យឯកជនដែលមានស្មារតីសហគ្រិនភាព ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាបន្តបន្ទាប់ និងការធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅទៅក្នុងទីផ្សារតំបន់ និងអន្តរជាតិ។

ក្នុងបរិបទនេះ ធនាគារ ABA បោះជំហានចូលឆ្នាំថ្មីដោយចាប់ផ្តើមពីជំហរដ៏រឹងមាំ និងមានទិសដៅយុទ្ធសាស្ត្រច្បាស់លាស់។ យើងនឹងបន្តវិនិយោគលើបច្ចេកវិទ្យា ពង្រីកសាខានិងបណ្តាញស្វ័យសេវា ពង្រឹងអេកូស៊ីស្តែមរបស់យើង និងបង្កើនសមត្ថភាពដែលអនុញ្ញាតឲ្យយើងបម្រើអតិថិជនកាន់តែមានប្រសិទ្ធភាព។ អ្វីដែលសំខាន់បំផុតនោះគឺ យើងនឹងបន្តវិនិយោគលើបុគ្គលិករបស់យើង ដែលជំនាញ ភាពមោះមុត និងផ្នត់គំនិតដែលអតិថិជនជាចម្បងរបស់ពួកគាត់ នៅតែជាមូលដ្ឋានគ្រឹះនៃភាពជោគជ័យរបស់យើង។ តាមរយៈការអនុវត្តប្រកបដោយវិន័យ និងការគ្រប់គ្រងដ៏ប្រុងប្រយ័ត្ន យើងមានទំនុកចិត្តលើសមត្ថភាពរបស់យើងក្នុងការដោះស្រាយបញ្ហាប្រឈមនាពេលខាងមុខ ខណៈពេលដែលបន្តបង្កើតតម្លៃរយៈពេលវែងសម្រាប់អតិថិជន ភាគហ៊ុនិក បុគ្គលិក និងសហគមន៍ដែលយើងបម្រើ។

តាងនាមគណៈគ្រប់គ្រង ខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជនរបស់យើងចំពោះការជឿទុកចិត្តរបស់ពួកគាត់ ភាគហ៊ុនិករបស់យើងចំពោះការគាំទ្ររបស់ពួកគេ និយតកររបស់យើងចំពោះការណែនាំរបស់ពួកគាត់ និងបុគ្គលិករបស់យើងចំពោះការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងដ៏លេចធ្លោ។

ចុះហត្ថលេខារួច

លោក **Askhat Azhikhanov**
នាយកប្រតិបត្តិ

អំពីធនាគារ ABA



ធនាគារ ABA គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជនឈានមុខគេរបស់ប្រទេសកម្ពុជា ដែលមានការីកចម្រើនប្រកបដោយស្ថិរភាពអស់រយៈពេល ៣០ ឆ្នាំ និងមានជំនាញឯកទេសពិសេសនៅក្នុងទីផ្សារ។

១៩៩៦ ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ ត្រូវបានបង្កើត

៣០ ឆ្នាំនៃដំណើរអភិវឌ្ឍ និងកំណើន

១ ABA ជាធនាគារពាណិជ្ជធំបំផុតនៅកម្ពុជា ផ្អែកលើទ្រព្យសកម្ម ប្រាក់បញ្ញើ កម្ចី និងប្រាក់ចំណេញសុទ្ធ

អំពីយើងខ្ញុំ

ធនាគារ ABA គឺជាគ្រឹះស្ថានហិរញ្ញវត្ថុឯកជនមួយ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៦ ក្រោមឈ្មោះថា ធនាគារវឌ្ឍនៈអាស៊ី ចំការត់។ ឆ្លងកាត់ការអភិវឌ្ឍ និងកំណើន រយៈពេលជាង ៣០ ឆ្នាំកន្លងមកនេះ ធនាគារ ABA បានពង្រឹងជំហររបស់ខ្លួនយ៉ាងរឹងមាំ ក្នុងនាមជាធនាគារពាណិជ្ជដ៏ធំជាងគេរបស់កម្ពុជា។

បណ្តាញសាខាចំនួន ១០៤, ទីតាំងស្វ័យសេវា ABA ២៤/៧ ចំនួន ៤៥ កន្លែង, ម៉ាស៊ីនស្វ័យសេវាជាង ១.៩០០ គ្រឿង នៅទូទាំងប្រទេស ព្រមទាំងសេវាធនាគារអនឡាញ និងកម្មវិធីធនាគារតាមទូរស័ព្ទដៃដ៏ទំនើប បានធ្វើឲ្យធនាគារ ABA មានសមត្ថភាពអាចបំពេញតម្រូវការរបស់សហគ្រាសធុនតូច និងមធ្យម, អាជីវកម្មខ្នាតមីក្រូ, និងរូបវន្តបុគ្គលរាប់លាននាក់ជាមួយសេវាកម្មហិរញ្ញវត្ថុ និងដំណោះស្រាយសេវាធនាគារឌីជីថលដ៏ទំនើបនិងសម្បូរបែប។

ធនាគារ ABA មានក្រុមការងារវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព និងសមាលកម្មដ៏ប្រសើរ ដែលប្តេជ្ញាចិត្តក្នុងការថែរក្សា និងបន្តពង្រឹងប្រសិទ្ធភាពប្រតិបត្តិការរបស់យើង។ គណៈគ្រប់គ្រងអន្តរជាតិរបស់យើង នាំយកនូវជំនាញដ៏មានតម្លៃ ដែលធ្វើឲ្យធនាគារ ABA អាចអនុវត្តការងារស្របតាមបទដ្ឋានសេវាកម្ម និងសុវត្ថិភាពអន្តរជាតិ។

STANDARD &POOR'S

ធនាគារ ABA រក្សាបាននូវចំណាត់ថ្នាក់លទ្ធភាពសងកម្រិត **"B+"** រយៈពេលវែងជាមួយអនាគត **"ស្ថិរភាព"** ពីទីភ្នាក់ងារវាយតម្លៃឥណទាន Standard & Poor's Global Ratings (S&P)។ ចំណាត់ថ្នាក់នេះត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងខែកញ្ញា ឆ្នាំ២០២៥។

កិច្ចខិតខំប្រឹងប្រែងរបស់ ABA ក្នុងការនាំយកផលិតផល និងសេវាកម្មល្អបំផុតជូនដល់អតិថិជន ត្រូវបានទស្សនាវដ្តីហិរញ្ញវត្ថុល្បីៗរបស់ពិភពលោកទទួលស្គាល់៖

- ទស្សនាវដ្តី *The Banker* បានប្រសិទ្ធនាមធនាគារ ABA ជា "ធនាគារដ៏ឆ្នើមប្រចាំឆ្នាំរបស់កម្ពុជា" នៅក្នុងឆ្នាំ ២០១៤, ២០១៦, ២០១៩, ២០២១, ២០២២, ២០២៣ និង ២០២៥ ។
- ទស្សនាវដ្តី *Euromoney* បានប្រគល់ពាន់រង្វាន់ "ធនាគារដ៏ឆ្នើមបំផុតនៅកម្ពុជា" ជូនដល់ធនាគារ ABA រយៈពេល ១២ ឆ្នាំជាប់ៗគ្នា ចាប់ពីឆ្នាំ ២០១៤ ដល់ ២០២៥។
- ទស្សនាវដ្តី *Global Finance* បានប្រសិទ្ធនាមធនាគារ ABA ជា "ធនាគារដ៏ឆ្នើមបំផុតនៅកម្ពុជា" ចាប់ពីឆ្នាំ ២០១៥ រហូតដល់ឆ្នាំ ២០២៥។
- ទស្សនាវដ្តី *Asian Banking and Finance* បានប្រសិទ្ធនាមធនាគារ ABA ជា "ធនាគារបម្រើសេវារូបវន្តបុគ្គលដ៏ឆ្នើមប្រចាំឆ្នាំ" រយៈពេល ៥ ឆ្នាំជាប់ៗគ្នា ចាប់ពីឆ្នាំ ២០២១ ដល់ ២០២៥។

The Banker – CAMBODIA'S BANK OF THE YEAR
២០១៤, ២០១៦, ២០១៩, ២០២១-២០២៣, ២០២៥

EUROMONEY Awards for excellence – BEST BANK IN CAMBODIA
២០១៤ - ២០២៥

GLOBAL FINANCE – CAMBODIA'S BEST BANK
២០១៥ - ២០២៥

BANKING & FINANCE – DOMESTIC RETAIL BANK OF THE YEAR
២០១៥ - ២០២៥

NATIONAL BANK OF CANADA

ធនាគារ ABA គឺជាបុត្រសម្ពន្ធរបស់ធនាគារជាតិកាណាដា ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុដ៏រឹងមាំមួយមានទ្រព្យសកម្មប្រមាណ ៤៤៧ ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០២៦ និងមានបណ្តាញធនាគារអន្តរការីទូលំទូលាយនៅទូទាំងពិភពលោក។

ក្នុងនាមជាភាគហ៊ុនិករបស់ធនាគារ ABA ចាប់តាំងពីឆ្នាំ ២០១៤ មក ធនាគារជាតិកាណាដាបានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុដ៏ធំដំបូងគេបង្អស់មកពីទ្វីបអាមេរិកខាងជើង ដែលបានឈានជើងចូលក្នុងវិស័យធនាគារនៅកម្ពុជា។

ដោយមានទីស្នាក់ការកណ្តាលនៅទីក្រុងម៉ុងរេអាល់ ធនាគារជាតិកាណាដា មានសាខានៅទូទាំងប្រទេសកាណាដា និងបម្រើអតិថិជនប្រមាណ ៣,១ លាននាក់។ ធនាគារនេះ គឺជាគ្រឹះស្ថានធំជាងគេលំដាប់ទីប្រាំមួយនៅក្នុងប្រទេសកាណាដា និងជាធនាគារឈានមុខគេនៅក្នុងខេត្តកេបិច ជាទីដែលខ្លួនក្លាយជាម្រើសទីមួយសម្រាប់បណ្តាសហគ្រាសធុនតូច និងមធ្យមនានា។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វិបសាយ www.nbc.ca ។

ចក្ខុវិស័យ បេសកកម្ម គុណតម្លៃ

ចក្ខុវិស័យរបស់យើង

ចក្ខុវិស័យរបស់ធនាគារ គឺដើម្បីក្លាយជាធនាគារលំដាប់លេខមួយប្រចាំប្រទេស លើផ្នែកផ្គត់ផ្គង់សេវាកម្មធនាគារគួរជាទីទុកចិត្ត ងាយស្រួលប្រើប្រាស់ ប្រកបដោយបច្ចេកវិទ្យាទំនើប និងងាយស្រួលក្នុងការទទួលបាន។ យើងមានបំណងក្លាយជាធនាគារមួយដែលប្រជាជនកម្ពុជាជឿទុកចិត្តក្នុងការបំពេញតម្រូវការសេវាធនាគារផ្ទាល់ខ្លួន និងសម្រាប់អាជីវកម្មរបស់ពួកគាត់ផងដែរ។

បេសកកម្មរបស់យើង

បេសកកម្មរបស់យើង គឺដើម្បីជួយដល់ប្រទេសកម្ពុជា ធុរកិច្ចកម្ពុជា និងប្រជាជនកម្ពុជានៅក្នុងការកសាងអនាគតកាន់តែទូលំទូលាយ និងត្រចះត្រចង់ តាមរយៈការផ្តល់សេវាធនាគារប្រកបដោយជំនាញវិជ្ជាជីវៈខ្ពស់ និងបច្ចេកវិទ្យាទំនើបសម្រាប់គ្រប់គ្នា។ យើងចាត់ទុកខ្លួនយើងថាជាដៃគូដ៏ល្អមួយសម្រាប់សហគមន៍កម្ពុជា ក៏ដូចជាអាជីវកម្មឯកជន និងឯកត្តជនផងដែរ។ យើងនៅទីនេះ ដើម្បីផ្តល់សេវាកម្មជូនប្រទេសកម្ពុជា។

គុណតម្លៃរបស់យើង

គុណតម្លៃរបស់យើងបានបង្កើតជាគ្រឹះដ៏សំខាន់សម្រាប់ធុរកិច្ចរបស់យើង។ យើងជឿជាក់លើសារៈសំខាន់នៃ៖

សុចរិតភាព និងសេចក្តីគោរព

នៅធនាគារ ABA យើងចាត់ទុកចំណុចនេះជាការទទួលខុសត្រូវខ្ពស់របស់យើង ដែលត្រូវបម្រើសេវាជូនរាល់អតិថិជនគ្រប់រូប ប្រកបដោយភាពសុចរិត និងសេចក្តីគោរព។ ដោយប្រកាន់ខ្ជាប់នូវគុណតម្លៃនេះ យើងទទួលបានការជឿទុកចិត្ត និងការគោរពពីអតិថិជនរបស់យើងដូចគ្នា។

ទំនុកចិត្ត និងភាពជាដៃគូ

នៅធនាគារ ABA យើងនៅទីនេះដើម្បីជួយសម្រួល និងជាជំនួយការ។ យើងចាត់ទុកខ្លួនយើងជាដៃគូអាចពឹងពាក់បានដែលអតិថិជនរបស់យើងអាចជឿទុកចិត្ត និងពឹងផ្អែកសម្រាប់តម្រូវការហិរញ្ញវត្ថុរបស់ពួកគេ។

ចីរភាព និងកំណើន

នៅធនាគារ ABA យើងតែងតែគិតគូរអំពីអនាគតរបស់ធនាគារ និងប្រជាជនកម្ពុជា ព្រមទាំងប្រទេសកម្ពុជាយើង។ យើងសូមបង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុតដូចគ្នាចំពោះបុគ្គលិកក៏ដូចជាអតិថិជនរបស់យើងផងដែរ។ ការណ៍នេះហើយ ដែលធានាបាននូវភាពរីកចម្រើនប្រកបដោយចីរភាពរបស់ធនាគារ។

វិភាគទាន

នៅធនាគារ ABA យើងមានបំណងចូលរួមចំណែកវិជ្ជមានសម្រាប់ប្រទេសកម្ពុជា។ យើងចង់ដើរតួនាទីដែលផ្តល់សារប្រយោជន៍សម្រាប់ការរស់នៅរបស់អតិថិជនយើង ក៏ដូចជាសម្រាប់អនាគតរបស់ប្រទេសយើងផងដែរ។

ក្រមសីលធម៌ និងសុជីវធម៌

នៅធនាគារ ABA យើងអនុវត្តស្តង់ដារក្រមសីលធម៌ និងសុជីវធម៌ខ្ពស់រវាងគ្នានឹងគ្នា និងគ្រប់សកម្មភាពការងារដែលយើងធ្វើ ទាំងនៅក្នុង និងក្រៅធនាគារ។ គោលការណ៍ផ្ទាល់ទាំងនេះហើយ ដែលជាមូលដ្ឋានសម្រាប់រាល់ទំនាក់ទំនងប្រចាំថ្ងៃ ពោលគឺជាមួយអតិថិជន និងសហគមន៍ដែលយើងកំពុងផ្តល់សេវាជូន ក៏ដូចជាជាមួយបុគ្គលិករបស់យើងផងដែរ។

គុណភាពនៃសេវាកម្ម

នៅធនាគារ ABA យើងខិតខំស្វែងរកដំណោះស្រាយដើម្បីឆ្លើយតបចំពោះរាល់តម្រូវការសេវាធនាគារទាំងអស់។ យើងមានបំណងផ្តល់សេវាកម្មធនាគារប្រកបដោយទំនុកចិត្ត និងមានបច្ចេកវិទ្យាទំនើបសម្រាប់អតិថិជនទាំងអស់របស់យើង មិនថាពួកគេជាម្ចាស់គណនីផ្ទាល់ខ្លួន ឬម្ចាស់គណនីអាជីវកម្ម។

ពានរង្វាន់



ពានរង្វាន់ធនាគារដ៏ឆ្នើមប្រចាំឆ្នាំ

ធនាគារ ABA ត្រូវបានប្រសិទ្ធនាមជា ធនាគារដ៏ឆ្នើមប្រចាំឆ្នាំ ២០២៥ របស់កម្ពុជា ដោយ The Banker ដែលជាទស្សនាវដ្តីហិរញ្ញវត្ថុអន្តរជាតិ ក្រោម Financial Times Group នៅចក្រភពអង់គ្លេស។ ពានរង្វាន់នេះទទួលស្គាល់ការផ្តល់សេវាហិរញ្ញវត្ថុដ៏លេចធ្លោ, ឧត្តមភាពនវានុវត្តន៍, និងការរួមចំណែកប្រកបដោយចីរភាពរបស់ ABA ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។



ពានរង្វាន់ធនាគារដ៏ឆ្នើមរបស់កម្ពុជា

ABA បានទទួលពានរង្វាន់ធនាគារដ៏ឆ្នើមរបស់កម្ពុជាឆ្នាំ ២០២៥ ពីទស្សនាវដ្តី Euromoney រយៈពេល ១២ឆ្នាំ ជាប់ៗគ្នា។ ការទទួលស្គាល់នេះ ឆ្លុះបញ្ចាំងពីសមត្ថភាពរបស់ ABA ក្នុងការបន្តឈានមុខ ទាំងសេវាធនាគារឌីជីថល ទាំងសេវាធនាគាររូបវន្ត និងជាធនាគារគំរូ នៅក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា និងក្នុងតំបន់។



ពានរង្វាន់ធនាគារបម្រើសេវារូបវន្តបុគ្គលដ៏ឆ្នើមនៅកម្ពុជា

ធនាគារ ABA ទទួលបានពានរង្វាន់លើកទីប្រាំជាប់ៗគ្នា ពីទស្សនាវដ្តី Asian Banking and Finance ដោយស្តែងឲ្យឃើញពីទំនុកចិត្តមុតមាំរបស់អតិថិជន និងការប្តេជ្ញាចិត្តរបស់ធនាគារចំពោះនវានុវត្តន៍ និងដំណោះស្រាយដែលផ្តោតលើអតិថិជន។ គណៈវិនិច្ឆ័យបានកត់សម្គាល់ពីសមិទ្ធផលសំខាន់ៗ រួមមានអតិថិជនជាង ៥,១ លាននាក់ និងការបង្កើនប្រសិទ្ធភាពជាបន្តបន្ទាប់នៃផ្លែតហ្វូមធនាគារចល័ត និងអនឡាញសម្រាប់អតិថិជនបុគ្គល និងអាជីវកម្ម។



ពានរង្វាន់ធនាគារដ៏ឆ្នើមបំផុតនៅកម្ពុជា

ធនាគារ ABA ទទួលបានពានរង្វាន់ “ធនាគារល្អបំផុតនៅកម្ពុជា” លើកទី១១ ជាប់ៗគ្នាដោយទស្សនាវដ្តី Global Finance។ ពានរង្វាន់នេះបង្ហាញពីឧត្តមភាពរបស់ធនាគារក្នុងនវានុវត្តន៍ឌីជីថល ធនាគារចល័ត និងដំណោះស្រាយហិរញ្ញវត្ថុដែលផ្តោតលើអតិថិជន ដែលឆ្លើយតបទៅនឹងតម្រូវការវិវត្តរបស់អតិថិជនទូទាំងប្រទេស។



ពានរង្វាន់នវានុវត្តន៍ហិរញ្ញវត្ថុឆ្នើមប្រចាំឆ្នាំ

ធនាគារ ABA ទទួលបានពានរង្វាន់ “នវានុវត្តន៍ហិរញ្ញវត្ថុឆ្នើមប្រចាំឆ្នាំ – សេវាកម្មហិរញ្ញវត្ថុ” ពី កម្មវិធី The Asian Innovation Excellence Awards ឆ្នាំ ២០២៥ ដោយទទួលស្គាល់សមត្ថភាពជាឈានមុខរបស់ ABA ក្នុងវិស័យធនាគារឌីជីថល។ ពានរង្វាន់នេះបង្ហាញពីការវិវត្តជាបន្តបន្ទាប់របស់ ABA Mobile រួមទាំងនវានុវត្តន៍សំខាន់ៗដូចជា FacePass ដែលជាមុខងារផ្ទៀងមុខជាក់ស្តែងដំបូងគេក្នុងវិស័យធនាគាររបស់កម្ពុជា, Navi ដែលជាជំនួយការនិម្មិតផ្នែកសេវាធនាគារដំបូងគេ, និងមុខងារវិភាគហិរញ្ញវត្ថុផ្ទាល់ខ្លួន ទំនើបឈានមុខ – ដែលទាំងអស់នេះ បង្កើតបាននូវស្តង់ដារថ្មីសន្លាង នៃសេវាធនាគារឌីជីថលដែលមានសុវត្ថិភាពខ្ពស់ និងផ្តោតលើតម្រូវការរបស់អតិថិជន នៅក្នុងប្រទេសកម្ពុជា។

ធនាគារអន្តរការី

រូបិយប័ណ្ណ	ឈ្មោះធនាគារអន្តរការី	លេខកូដ SWIFT
AUD	JPMorgan Chase Bank National Association, ប្រទេសអូស្ត្រាលី	CHASAU2X
CAD	National Bank of Canada, ប្រទេសកាណាដា	BNDCCAMMINT
CNY	ICBC Limited សាខាភ្នំពេញ	ICBKKHPP
	Bank of China (Hong Kong) Limited, សាខាភ្នំពេញ	BKCHKHPPCLR
EUR	National Bank of Canada, ប្រទេសកាណាដា	BNDCCAMMINT
	Commerzbank AG, ប្រទេសអាល្លឺម៉ង់	COBADEFF
GBP	Standard Chartered Bank, ប្រទេសអង់គ្លេស	SCBLGB2L
JPY	Sumitomo Mitsui Banking Corporation, ប្រទេសជប៉ុន	SMBCJPJT
KRW	Woori Bank, ប្រទេសកូរ៉េខាងត្បូង	HVBKKRSE
SGD	DBS Bank, ប្រទេសសិង្ហបុរី	DBSSSGSG
THB	Standard Chartered Bank(Thai), ប្រទេសថៃ	SCBLTHBX
	Kasikornbank Public Company Limited, ប្រទេសថៃ	KASITHBK
USD	National Bank of Canada, ប្រទេសកាណាដា	BNDCCAMMINT
	JPMorgan Chase Bank National Association, សហរដ្ឋអាមេរិក	CHASUS33
	Standard Chartered Bank, សហរដ្ឋអាមេរិក	SCBLUS33
	Standard Chartered Bank Limited, ប្រទេសសិង្ហបុរី	SCBLSG22
	Woori Bank, ប្រទេសកូរ៉េខាងត្បូង	HVBKKRSE
	Kookmin Bank, ប្រទេសកូរ៉េខាងត្បូង	CZNBKRSE
	KEB Hana, ប្រទេសកូរ៉េខាងត្បូង	KOEXKRSE
	DBS Bank, ប្រទេសសិង្ហបុរី	DBSSSGSG
	Oversea – Chinese Banking Corporation, ប្រទេសសិង្ហបុរី	OCBCSGSG
	Joint Stock Commercial Bank for Foreign Trade of Vietnam, ប្រទេសវៀតណាម	BFTVVNVX
	KasikornBank Public Company Limited, ប្រទេសថៃ	KASITHBK
	The Bank of New York Mellon	IRVTUS3N
VND	Joint Stock Commercial Bank for Foreign Trade of Vietnam, ប្រទេសវៀតណាម	BFTVVNVX

ការគូសបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ

ឆ្នាំសារពើពន្ធគិតត្រឹមថ្ងៃទី៣១ ខែធ្នូ (ធ្វើសវនកម្មរួចលើកលែងសូចនាករសមិទ្ធកម្មគន្លឹះ និងព័ត៌មានទូទៅ)	**២០២៥**	**២០២៤**
តារាងតុល្យការ (គិតជាលានដុល្លារអាមេរិក)		
ប្រាក់បញ្ញើសរុប	១២.៨៥៣,១	១១.០១១,១
ឥណទានដុលសរុប	៩.៦៤០,២	៨.៦៦៧,៣
មូលធន	២.៦៧៥,៧	២.២៩៨,១
ទ្រព្យសកម្មសរុប	១៦.១៥៣,៨	១៣.៧៥៩,៥
គណនីលទ្ធផល (គិតជាលានដុល្លារអាមេរិក)		
ចំណូលការប្រាក់សុទ្ធ	៧១២,៦	៦២០,១
ចំណូលកម្រៃ និងជើងសាសុទ្ធ និងចំណូលផ្សេងៗ	៧៦,៧	៦៣,៣
ចំណេញសុទ្ធ	៣៧៧,៦	២៩៩,៦
សូចនាករសមិទ្ធកម្មគន្លឹះ (%)		
ROAE	១៥,២	១៤,៩
ROAA	២,៥	២,៤
ថ្លៃដើម/ចំណូល	២៩,៨	៣១,១
អនុបាតសន្ទនីយភាព	១៣៧,២	២២២,៣
អនុបាតបញ្ញើឥណទាន	៧៤,៥	៧៨,៤
អនុបាតសាធនភាព	១៧,៤	២១,១
ព័ត៌មានទូទៅ		
សាខាបើកដំណើរការ	១០៤	៩៩
បុគ្គលិក	១០.៣១៣	៩.៧០៥
ម៉ាស៊ីនស្វ័យសេវា	១.៩១៨	១.៧៦១
ចំនួនគណនី	៨.២៨៤.៣៣០	៥.៩៥៧.៨២៨
អ្នកខ្ចីប្រាក់	១៥៥.៩០៦	១៣៥.៥៤១

លទ្ធផលហិរញ្ញវត្ថុ

ទ្រព្យសកម្ម

គិតជាលានដុល្លារអាមេរិក

១៧,៤%

កើនឡើងធៀបនឹងឆ្នាំ២០២៤

១៦.១៥៤
២០២៥

១៣.៧៦០
២០២៤

មូលធនរបស់ភាគហ៊ុនិក

គិតជាលានដុល្លារអាមេរិក

១៦,៤%

កើនឡើងធៀបនឹងឆ្នាំ២០២៤

២.៦៧៦
២០២៥

២.២៩៨
២០២៤

ប្រាក់បញ្ញើ

គិតជាលានដុល្លារអាមេរិក

១៦,៧%

កើនឡើងធៀបនឹងឆ្នាំ២០២៤

១២.៨៥៣
២០២៥

១១.០១១
២០២៤

ប្រាក់កម្ចីដុល

គិតជាលានដុល្លារអាមេរិក

១១,២%

កើនឡើងធៀបនឹងឆ្នាំ២០២៤

៩.៦៤០
២០២៥

៨.៦៦៧
២០២៤

ប្រាក់ចំណេញសុទ្ធ

គិតជាលានដុល្លារអាមេរិក

២៦%

កើនឡើងធៀបនឹងឆ្នាំ២០២៤

៣៧៧,៦
២០២៥

២៩៩,៦
២០២៤

ចំនួនគណនី

គិតជាលាន

៣៩%

កើនឡើងធៀបនឹងឆ្នាំ២០២៤

៨.២៨
២០២៥

៥,៩៦
២០២៤

បណ្តាញសាខា

ការិយាល័យកណ្តាល

អគារលេខ ១៤១, ១៤៦, ១៤៨, ១៤៨ អា បេ សេ ដេ និង១៦២ អា មហាវិថី ព្រះសីហនុ និង អគារលេខ ១៥ និង ១៥៣ អា បេ សេ ផ្លូវលេខ ២៧៨ និង អគារលេខ ១៧១ ផ្លូវត្រសក់ផ្អែម សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

១ ៨០០ ២០៣ ២០៣ (ប្រព័ន្ធទូរស័ព្ទឥតគិតថ្លៃ)
ទូរសារ (+៨៥៥) ២៣ ២១៦ ៣៣៣

info@ababank.com
www.ababank.com

P.O. Box ២២៧៧
SWIFT: **ABAAKHPP**

ស្នាក់ការកណ្តាល	០២៣ ២២៥ ៣៣៣
ផ្សារអ៊ីអនម៉លមានជ័យ	០៨១ ២០៨ ៧២០
ផ្សារអ៊ីអនសែនសុខ	០៩៨ ២០៣ ១៤៩
ជីឌីធី ចៅវើ	០៩៨ ២០៦ ៤៤០
ខណ្ឌ៧មករា – សង្កាត់មនោរម្យ	០៨១ ២០៤ ៣០៧
ខណ្ឌ៧មករា – សង្កាត់វាលវង់	០៩៨ ២០៣ ៨៦៩
ខណ្ឌកំបូល – សង្កាត់កន្ទោក	០៩៨ ២០៥ ៩៨១
ខណ្ឌចំការមន – សង្កាត់ទន្លេបាសាក់ "ក"	០៩៨ ២០៣ ៩៨៣
ខណ្ឌចំការមន – សង្កាត់ទន្លេបាសាក់ "ខ"	០៩៨ ២០៥ ៥៨៣
ខណ្ឌចំការមន – សង្កាត់បឹងត្របែក	០៩៨ ២០៦ ៧៥០
ខណ្ឌចំការមន – សង្កាត់ផ្សារដើមថ្កូវ	០៩៨ ២០៣ ៦៨៩
ខណ្ឌច្បារអំពៅ – សង្កាត់ច្បារអំពៅទី២	០៩៨ ២០៣ ៩២៩
ខណ្ឌច្បារអំពៅ – សង្កាត់និរោធ	០៩៨ ២០៣ ០៤៥
ខណ្ឌជ្រោយចង្វារ – សង្កាត់ជ្រោយចង្វារ	០៩៨ ២០៣ ១៨៩
ខណ្ឌដង្កោ – សង្កាត់ជើងឯក	០៩៨ ២០៣ ៥៧៩
ខណ្ឌដូនពេញ – សង្កាត់ចតុមុខ	០៩៨ ២០៣ ០០១
ខណ្ឌដូនពេញ – សង្កាត់បឹងរាំង	០៩៨ ២០៣ ១៩៩
ខណ្ឌដូនពេញ – សង្កាត់ផ្សារថ្មីទី៣	០៩៨ ២០៣ ៩៧៩
ខណ្ឌដូនពេញ – សង្កាត់ស្រះចក	០៩៨ ២០៣ ៨១៩
ខណ្ឌទួលគោក – សង្កាត់បឹកកក់ទី១ "ក"	០៩៨ ២០៣ ៨៥៩
ខណ្ឌទួលគោក – សង្កាត់បឹកកក់ទី១ "ខ"	០៩៨ ២០៣ ៦៣៧
ខណ្ឌទួលគោក – សង្កាត់បឹងសាឡាង	០៩៨ ២០៣ ៧៩៩
ខណ្ឌទួលគោក – សង្កាត់ផ្សារដេប៉ូទី៣	០៩៨ ២០៣ ៤៦៩
ខណ្ឌបឹងកេងកង – សង្កាត់ទួលស្វាយព្រៃទី២	០៨១ ២០៤ ០១៩
ខណ្ឌបឹងកេងកង – សង្កាត់បឹងកេងកងទី៣	០៩៨ ២០៣ ៨០៩
ខណ្ឌពោធិ៍សែនជ័យ – សង្កាត់ចោមចៅទី១	០៨១ ២០៤ ៤២០
ខណ្ឌពោធិ៍សែនជ័យ – សង្កាត់ចោមចៅទី២	០៨១ ២០៥ ៧២១
ខណ្ឌពោធិ៍សែនជ័យ – សង្កាត់ចោមចៅទី៣	០៩៨ ២០៣ ៩៣៩
ខណ្ឌពោធិ៍សែនជ័យ – សង្កាត់សំរោងក្រោម	០៨១ ២០៥ ៧៣៥
ខណ្ឌព្រែកព្នៅ – សង្កាត់ព្រែកព្នៅ	០៩៨ ២០៦ ៣២៨
ខណ្ឌមានជ័យ – សង្កាត់ស្ទឹងមានជ័យទី១ "ក"	០៩៨ ២០៣ ៨៨៩
ខណ្ឌមានជ័យ – សង្កាត់ស្ទឹងមានជ័យទី១ "ខ"	០៩៨ ២០៦ ១៨០
ខណ្ឌសែនសុខ – សង្កាត់គោកឃ្លាង	០៩៨ ២០៣ ៧៧៩
ខណ្ឌសែនសុខ – សង្កាត់ទឹកថ្លា	០៩៨ ២០៣ ៨៤៩
ខណ្ឌសែនសុខ – សង្កាត់អូរបែកក្អម	០៩៨ ២០៣ ០៩៤
ខណ្ឌឫស្សីកែវ – សង្កាត់គីឡូម៉ែត្រលេខ៦	០៩៨ ២០៣ ៦៥៩
ខណ្ឌឫស្សីកែវ – សង្កាត់ច្រាំងចំរេះទី១	០៩៨ ២០៦ ៧២៩
ក្រុងកំពង់សោម – សង្កាត់បិតត្រាង	០៩៨ ២០៦ ៣៦១
ក្រុងតាខ្មៅ – សង្កាត់តាខ្មៅ	០៩៨ ២០៣ ៩១៩
ក្រុងបាត់ដំបង – សង្កាត់រតនៈ	០៩៨ ២០៦ ៥៤៨
ក្រុងបាវិត – សង្កាត់បាវិត	០៩៨ ២០៣ ៣៨៩
ក្រុងប៉ោយប៉ែត – សង្កាត់ប៉ោយប៉ែត	០៩៨ ២០៣ ០១៩
ក្រុងសៀមរាប – សង្កាត់សួក្រាម "ក"	០៩៨ ២០៣ ៦៧៩
ក្រុងសៀមរាប – សង្កាត់សួក្រាម "ខ"	០៩៨ ២០៣ ០៨៩
ក្រុងឧដុង្គម៉ែជ័យ – សង្កាត់វាំងចាស់	០៩៨ ២០៣ ៣៧៩
ខេត្តកំពង់ចាម	០៩៨ ២០៣ ៨៧៩

ខេត្តកំពង់ឆ្នាំង	០៩៨ ២០៣ ០៣៩
ខេត្តកំពង់ធំ	០៩៨ ២០៣ ៤២៩
ខេត្តកំពង់ស្ពឺ	០៩៨ ២០៣ ៩៤៩
ខេត្តកំពត	០៩៨ ២០៣ ៩៥៩
ខេត្តកែប	០៨១ ២០៥ ៧០៧
ខេត្តកោះកុង	០៨១ ២០៤ ១២៣
ខេត្តក្រចេះ	០៩៨ ២០៣ ០៤៩
ខេត្តតាកែវ	០៩៨ ២០៣ ៩០៩
ខេត្តត្បូងឃ្មុំ	០៩៨ ២០៣ ៧៦៩
ខេត្តបន្ទាយមានជ័យ	០៩៨ ២០៣ ៧៥៩
ខេត្តបាត់ដំបង	០៩៨ ២០៣ ៨៣៩
ខេត្តប៉ៃលិន	០៨១ ២០៤ ៦៥៩
ខេត្តពោធិ៍សាត់	០៩៨ ២០៣ ៩៦៩
ខេត្តព្រះសីហនុ	០៩៨ ២០៣ ៨៩៩
ខេត្តព្រៃវែង	០៩៨ ២០៣ ០៥៩
ខេត្តមណ្ឌលគីរី	០៨១ ២០៤ ៥៦៧
ខេត្តរតនគីរី	០៩៨ ២០៣ ៤៩៩
ខេត្តសៀមរាប	០៩៨ ២០៣ ៨២៩
ខេត្តស្ទឹងត្រែង	០៨១ ២០៤ ០៩០
ខេត្តស្វាយរៀង	០៩៨ ២០៣ ០២៩
ខេត្តឧត្តរមានជ័យ	០៨១ ២០៤ ៧៦៥
ខេត្តព្រះវិហារ	០៨១ ២០៤ ៥៩០
ស្រុកកណ្តាលស្ទឹង – ឃុំអន្លង់រមៀត	០៩៨ ២០៣ ៦១៩
ស្រុកកំពង់ត្រឡាច – ឃុំពានី	០៨១ ២០៤ ១៤៩
ស្រុកកំពង់ត្រាច – ឃុំកំពង់ត្រាចខាងកើត	០៩៨ ២០៦ ៥៣៥
ស្រុកកៀនស្វាយ – ឃុំគគីរ	០៩៨ ២០៣ ៤៧៩
ស្រុកកោះធំ – ឃុំព្រែកថ្មី	០៨១ ២០៤ ១៨៦
ស្រុកគីរីវង់ – ឃុំព្រះបាទជាន់ជុំ	០៩៨ ២០៦ ៩៥៣
ស្រុកចំការលើ – ឃុំស្វាយទាប	០៨១ ២០៤ ០៥៣
ស្រុកជើងព្រៃ – ឃុំសូទិព្វ	០៩៨ ២០៣ ៧៤៩
ស្រុកឈូក – ឃុំសត្វពង	០៩៨ ២០៣ ៧២៩
ស្រុកត្រាំកក់ – ឃុំអង្គតាសោម	០៩៨ ២០៣ ៧០៩
ស្រុកថ្មគោល – ឃុំតាពូង	០៩៨ ២០៣ ៧៨៩
ស្រុកបវេល – ឃុំបវេល	០៩៨ ២០៦ ៩៧៧
ស្រុកបាកាន – ឃុំបឹងខ្នារ	០៨១ ២០៤ ២០៩
ស្រុកបាទី – ឃុំត្រពាំងសាប	០៩៨ ២០៦ ៩៤១
ស្រុកបាទី – ឃុំសូរភី	០៩៨ ២០៣ ៦៤៩
ស្រុកបារាយណ៍ – ឃុំបល្ល័ង្ក	០៩៨ ២០៣ ៧៣៩
ស្រុកពញាក្រែក – ឃុំកោងកាង	០៩៨ ២០៥ ៨៧១
ស្រុកពាមរក៍ – ឃុំព្រែកខ្សាយ ខ	០៩៨ ២០៣ ៦២៩
ស្រុកពារាំង – ឃុំរកា	០៨១ ២០៤ ២៩២
ស្រុកពួក – ឃុំពួក	០៨១ ២០៧ ២០០
ស្រុកព្រះនេត្រព្រះ – ឃុំជប់វារី	០៨១ ២០៤ ២៦២
ស្រុកព្រៃឈរ – ឃុំជ្រៃវៀន	០៨១ ២០៤ ១៨៩
ស្រុកព្រៃនប់ – ឃុំវាលរេញ	០៨១ ២០៤ ២៩៧
ស្រុកមង្គលបូរី – ឃុំឫស្សីក្រោក	០៨១ ២០៤ ០២៩
ស្រុកមុខកំពូល – ឃុំព្រែកអញ្ជាញ	០៩៨ ២០៣ ១៥៩
ស្រុកមេមត់ – ឃុំមេមត់	០៩៨ ២០៣ ៦៣៩
ស្រុកមោងឫស្សី – ឃុំគារ	០៩៨ ២០៣ ៤៥៩
ស្រុកសំរោងទង – ឃុំត្រពាំងគង	០៩៨ ២០៣ ៧១៩
ស្រុកសូទ្រនិគម – ឃុំដំដែក	០៨១ ២០៤ ២៨៣
ស្រុកស្ទឹងត្រង់ – ឃុំព្រែកកក់	០៩៨ ២០៦ ៣៧៩
ស្រុកស្អាង – ឃុំកំពង់ចិនជើង	០៨១ ២០៤ ៣៥៥
ស្រុកស្នួល – ឃុំស្នួល	០៩៨ ២០៣ ០៩៩
ស្រុកស្រែ អំបិល – ឃុំជ្រោយស្វាយ	០៩៨ ២០៦ ៦២៤
ស្រុកស្វាយជ្រំ – ឃុំក្រោលគោ	០៩៨ ២០៣ ៣៤៩
ស្រុកស្អាង – ឃុំព្រែកគយ	០៩៨ ២០៣ ៣៦៩
ស្រុកអង្គរជ័យ – ឃុំភ្នំកុង	០៩៨ ២០៦ ៧៧៦
ស្រុកអង្គស្នួល – ឃុំបែកចាន	០៩៨ ២០៣ ៤៨៩
ស្រុកអូរាំងឪ – ឃុំគងជ័យ	០៩៨ ២០៥ ៦១៩

ក

អភិបាលកិច្ចសាជីវកម្ម

ភាគហ៊ុនិក

គិតត្រឹមដំណាច់ឆ្នាំ ២០២៥ រចនាសម្ពន្ធភាគហ៊ុនរបស់ធនាគារ ABA មានដូចខាងក្រោម៖

ឈ្មោះភាគហ៊ុនិក	ចំនួនភាគហ៊ុន	ចំនួនទឹកប្រាក់ គិតជាដុល្លារ
ធនាគារជាតិកាណាដា	១.៣១៩.៩៩៩	១.៣១៩.៩៩៩.០០០
ក្រុមហ៊ុន Natcan Trust	១	១.០០០
សរុប	**១.៣២០.០០០**	**១.៣២០.០០០.០០០**

១ ភាគហ៊ុន = ១.០០០ ដុល្លារអាមេរិក

ធនាគារជាតិកាណាដា

ធនាគារ ABA គឺជាបុត្រសម្ពន្ធរបស់ធនាគារជាតិកាណាដា (www.nbc.ca) ដែលជាគ្រឹះស្ថានហិរញ្ញវត្ថុ មានទ្រព្យសកម្មជាង ៤៧ ពាន់លានដុល្លារអាមេរិក គិតត្រឹមថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០២៥ និងមានបណ្តាញធនាគារអន្តរការីនៅទូទាំងពិភពលោក។ ដោយមានទីស្នាក់ការកណ្តាលនៅទីក្រុងម៉ុងរេអាល់ ធនាគារជាតិកាណាដា មានសាខានៅទូទាំងប្រទេសកាណាដា និងបម្រើអតិថិជនប្រមាណ ៣,១ លាននាក់។ ធនាគារនេះគឺជាធនាគារធំជាងគេលំដាប់ទីប្រាំមួយនៅក្នុងប្រទេសកាណាដា និងជាធនាគារឈានមុខគេនៅក្នុងខេត្តកេបិច ជាទីដែលខ្លួនក្លាយជាម្រើសទីមួយសម្រាប់បណ្តាសហគ្រាសធុនតូច និងមធ្យមនានា។

ក្រុមហ៊ុន NATCAN TRUST

ក្រុមហ៊ុន Natcan Trust ចុះបញ្ជីក្នុងឆ្នាំ ១៩៩២ ក្រោមច្បាប់ក្រុមហ៊ុន និងអណត្តិព្យាបាលកាណាដា ហើយជាបុត្រសម្ពន្ធរបស់ធនាគារជាតិកាណាដា ("ក្រុមហ៊ុនអាណាព្យាបាលចុងក្រោយ") ដែលគ្រប់គ្រងទាំងស្រុងដោយប្រយោល។ ការិយាល័យកណ្តាលរបស់ក្រុមហ៊ុនស្ថិតនៅទីក្រុងម៉ុងរ៉េអាល់ ខេត្តកេបិច ប្រទេសកាណាដា។

សកម្មភាពហិរញ្ញវត្ថុចម្បងរបស់ក្រុមហ៊ុន Natcan Trust រួមមាន ការផ្តល់ផលិតផលប្រាក់បញ្ញើតាមរយៈបណ្តាញសាខារបស់ក្រុមហ៊ុនអាណាព្យាបាល និងដើរតួជាអាណត្តិព្យាបាល។

មហាសន្និបាតប្រចាំឆ្នាំរបស់ភាគហ៊ុនិក

ធនាគារ ABA រៀបចំមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំរបស់ខ្លួន ដោយអនុវត្តតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម លក្ខន្តិក: និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ។


នៅឆ្នាំ២០២៥ មហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ ត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែមេសា ដោយមានការចូលរួមពីតំណាងភាគហ៊ុនិករបស់ធនាគារ។ សេចក្តីសម្រេចដែលបានធ្វើឡើងនៅមហាសន្និបាត៖


១. មហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ បានចាត់ទុកលទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ABA សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ជាលទ្ធផលវិជ្ជមាន។

២. មហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ បានអនុម័តរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារ ABA សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

រចនាសម្ព័ន្ធអភិបាលកិច្ចសាជីវកម្ម

(គិតត្រឹមដំណាច់ឆ្នាំ២០២៥)




លេខាធិការសាជីវកម្ម
គណៈកម្មាធិការប្រតិបត្តិតាម
គណៈកម្មាធិការសវនកម្ម
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ
មុខងារគ្រប់គ្រងប្រតិបត្តិតាម
មុខងារសវនកម្មផ្ទៃក្នុង
មុខងារគ្រប់គ្រងហានិភ័យ
នាយករងប្រតិបត្តិ
អគ្គនាយករងប្រតិបត្តិ/អគ្គនាយករង/
មន្ត្រីកម្រិតនាយក
ប្រធានអង្គភាព
ប្រធាននាយកដ្ឋាន
ប្រធានសាខាតំបន់
ប្រធានសាខាខេត្ត
ប្រធានសាខា

ក្រុមប្រឹក្សាភិបាល



YVES JACQUOT
ប្រធានក្រុមប្រឹក្សាភិបាល

លោក Yves Jacquot បានបញ្ចប់ការសិក្សាពីសាលា ESSEC នៅប្រទេសបារាំង។ ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩៣ លោកបានកាន់មុខតំណែងជាច្រើនរួមមាន តំណែងនាយកប្រតិបត្តិធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុមួយចំនួននៅប្រទេសបារាំង ក៏ដូចជាធនាគារបម្រើសេវាបុគ្គល, វិស័យវិនិយោគ, ផ្នែកទីផ្សារហិរញ្ញវត្ថុ និងផ្នែកគ្រប់គ្រងទ្រព្យសកម្ម។

ក្នុងឆ្នាំ១៩៩៣ លោកបម្រើការនៅ BRED Banque Populaire និងក្លាយជានាយករងប្រតិបត្តិធនាគារនេះ និងជានាយកប្រតិបត្តិនៃ COFIBRED ដែលជាក្រុមហ៊ុនកាន់កាប់ក្រុមហ៊ុនបុត្រសម្ពន្ធរបស់ក្រុមហ៊ុនមេ។

បច្ចុប្បន្ន លោក Yves Jacquot កាន់មុខតំណែងជា នាយកផ្នែកអភិវឌ្ឍអន្តរជាតិរបស់សម្ពន្ធធនាគារជាតិកាណាដា។

លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៃធនាគារ ABAនៅក្នុងឆ្នាំ២០១៤។



DOMINIC JACQUES
អភិបាល

លោក Dominic Jacques បញ្ចប់ការសិក្សាពីសាលា HEC នៅកាណាដា មានសញ្ញាបត្រ Chatered Accountant (CPA, CA) និង CFA Charterholder។

លោក Jacques មានតួនាទីជាអគ្គនាយករងផ្នែកអភិវឌ្ឍអន្តរជាតិនៅធនាគារជាតិកាណាដា។ លោកទទួលខុសត្រូវក្នុងការគ្រប់គ្រងផ្នែកផលប្រតិនិយោគអន្តរជាតិរបស់ធនាគារ ក៏ដូចជាអភិវឌ្ឍឱកាសធុរកិច្ច។

លោក ផ្តើមអាជីពនៅក្រុមហ៊ុន PriceWaterhouseCoopers។ ឆ្នាំ២០១០ លោក Jacques ចូលរួមជាមួយធនាគារជាតិកាណាដាក្នុងនាយកដ្ឋានយុទ្ធសាស្ត្រនិងអភិវឌ្ឍអាជីវកម្ម។ លោកបានផ្តល់ប្រឹក្សាដល់ថ្នាក់ដឹកនាំជាន់ខ្ពស់ធនាគារស្តីពីការផ្តួចផ្តើមជាយុទ្ធសាស្ត្រ ភាពជាដៃគូ និងការងារសហកម្មនិងលទ្ធកម្ម។

Jacques យល់ដឹងជ្រៅជ្រះក្នុងវិស័យធនាគារ ជាមួយបទពិសោធការងារនៅម៉ុងរ៉េអាល់, ក្រុងឡុង, ប៉ារីស និងសហរដ្ឋអាមេរិក។

នៅឆ្នាំ២០១៦ លោក Jacques ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ ABA។



MADI AKMAMBET
អភិបាលប្រតិបត្តិ

លោក Madi Akmambet មានសញ្ញាបត្រកម្រិត MBA ប្រតិបត្តិ ពី Cass Business School, City University London (២០១៣) និងសញ្ញាបត្រសេដ្ឋកិច្ច ពី Kazakh State Academy of Management (១៩៩៦)។

លោកចាប់ផ្តើមអាជីពឆ្នាំ១៩៩៧ ក្នុងនាយកដ្ឋានរតនាគារនៃក្រសួងហិរញ្ញវត្ថុរបស់សាធារណរដ្ឋកាហ្សាក់ស្ថាន ហើយបន្ទាប់មក លោកដូរទៅនាយកដ្ឋានត្រួតពិនិត្យធនាគារក្នុងធនាគារជាតិនៃកាហ្សាក់ស្ថាន។

ចន្លោះពីឆ្នាំ២០០០ ដល់២០០៧ លោកបានកាន់តួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់នៅតាមបណ្តាក្រុមហ៊ុន, សមាគមគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារពាណិជ្ជនៅកាហ្សាក់ស្ថាន។

បទពិសោធអន្តរជាតិរបស់លោកចាប់ផ្តើមឆ្នាំ២០០៧ ជាមួយគម្រោងអាជីវកម្មនានាក្នុងប្រទេសអ៊ុយបេគីស្ថាន គ្រប់គ្រងដោយ Visor Holding ជាក្រុមហ៊ុនមូលធនឯកជនមានមូលដ្ឋាននៅកាហ្សាក់ស្ថាន។

នៅឆ្នាំ ២០០៩ លោកត្រូវបានតែងតាំងជានាយកប្រតិបត្តិរបស់ធនាគារ ABA នៅកម្ពុជា ដែលលោកបាននាំការអភិវឌ្ឍសំខាន់ៗ។ តាំងពីឆ្នាំ ២០១២ មក លោកជាអភិបាលប្រតិបត្តិនៃក្រុមប្រឹក្សាភិបាល។



MARTIN OUELLET
អភិបាល

ដោយបានបញ្ចប់ការសិក្សាពីសាលា École des Hautes Études Commerciales នៅម៉ុងរ៉េអាល់ លោក Martin Ouellet ជាអ្នកជំនាញផ្នែកគ្រប់គ្រងរតនាគារ ដែលបានចូលរួមសកម្មក្នុងការគ្រប់គ្រងសន្ទនីយភាព និងមូលនិធិ ព្រមទាំងហានិភ័យហិរញ្ញវត្ថុពាក់ព័ន្ធនឹងអត្រាការប្រាក់ និងអត្រាប្តូរប្រាក់បរទេស។ លោកបានចាប់ផ្តើមអាជីពរបស់ខ្លួនក្នុងឆ្នាំ១៩៧៧ ជាមួយក្រុមហ៊ុន Credit Foncier Franco-Canadien និងបានបម្រើការងារយៈពេលជាង ៣០ ឆ្នាំ នៅធនាគារជាតិកាណាដា ដែលលោកត្រូវបានដំឡើងតំណែងដល់អនុប្រធានជាន់ខ្ពស់ និងជាហេរញ្ញិកសាជីវកម្ម។

សព្វថ្ងៃលោក Martin មានមុខតំណែងជានាយកសាជីវកម្ម។ ក្នុងមុខតំណែងនេះ លោកបម្រើការងារនៅក្នុងក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាយោបល់នៃគ្រឹះស្ថានជាច្រើនដូចជា Auditing and Assurance Standards Oversight Council (កាណាដា) និង ធនាគារ Assurance-vie Banque Nationale។ លោកក៏ជាសមាជិករបស់វិទ្យាស្ថានអភិបាលសាជីវកម្ម (កាណាដា)។

លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៃធនាគារ ABA ក្នុងឆ្នាំ២០១៩។



CHRISTIAN ST-ARNAUD
អភិបាល

លោក Christian St-Arnaud បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ The École des Hautes Études Commerciales ទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា។ ចន្លោះឆ្នាំ ១៩៨៣ និង ២០០៩ លោកបានកាន់មុខតំណែងជាច្រើននៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុកាណាដា និងអន្តរជាតិ នៅប្រទេសកាណាដា ដោយផ្តោតលើទីផ្សារដើមទុនឥណទាន។

លោក Christian St-Arnaud បានចូលបម្រើការងារនៅធនាគារជាតិកាណាដា ក្នុងឆ្នាំ ២០០៩ ក្នុងតំណែងជាអនុប្រធានផ្នែកទីផ្សារដើមទុនឥណទាន និងអចលនទ្រព្យ ហើយត្រូវបានតែងតាំងជាអនុប្រធានជាន់ខ្ពស់ផ្នែកឥណទាន ក្នុងឆ្នាំ ២០១២ ទទួលបន្ទុកផ្នែកប្រតិបត្តិការបម្រើសេវាដល់អតិថិជនជារូបវន្ត, ពាណិជ្ជកម្ម និងឥណទានទីផ្សារហិរញ្ញវត្ថុរបស់ធនាគារ រួមមានការវាយតម្លៃ, ការគ្រប់គ្រងផលបត្រ និងអភិវឌ្ឍន៍គំរូឥណទាន។ លោកក៏ធ្លាប់ជាសមាជិកនៃគណៈកម្មាធិការជាន់ខ្ពស់ជាច្រើនរបស់ធនាគារផងដែរ រួមមាន គណៈកម្មាធិការហានិភ័យសកល, គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងគណៈកម្មាធិការឆ្លៃតពិនិត្យគំរូ។

នៅឆ្នាំ ២០១៩ លោក Christian St-Arnaud ត្រូវបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ធនាគារ ABA។



PAOLO PIZZUTO
អភិបាល

លោក Paolo Pizzuto បានបញ្ចប់ អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Université du Québec à Montréal ក្នុងឆ្នាំ២០០៣។

ជាធនាគារិក លោកបានបម្រើការនៅធនាគារជាតិកាណាដា ក្នុងឆ្នាំ ១៩៨៦ ក្នុងមុខតំណែងថ្នាក់គ្រប់គ្រងផ្សេងៗជាច្រើនដល់ឆ្នាំ២០០១ ជាពេលដែលលោកក្លាយជាអនុប្រធានផ្នែកលក់ និងសេវាកម្ម។

នៅឆ្នាំបន្ទាប់ៗ លោកកាន់តំណែងផ្នែកប្រតិបត្តិផ្សេងៗជាច្រើនទៀត រួមមាន សេវាធនាគាររូបវន្ត សេវាធនាគារពាណិជ្ជកម្ម ដំណោះស្រាយការទូទាត់ ការអភិវឌ្ឍដំណើរការ និងព័ត៌មានវិទ្យា។

ចាប់ពីឆ្នាំ ២០១៥ លោក Pizzuto បានកាន់តំណែងជាអនុប្រធានជាន់ខ្ពស់ផ្នែកសេវាធនាគាររូបវន្ត។ លោកក៏កាន់តួនាទីជាប្រធានក្រុមប្រឹក្សាភិបាល Natbank ដែលជាធនាគារសហរដ្ឋអាមេរិកនៅក្នុងរដ្ឋផ្លរីដា និងជាអភិបាលស្តីទីរបស់ Canadian Italian Foundation ចាប់ពីឆ្នាំ ២០០៤។

លោក Paolo Pizzuto បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ ABA ក្នុងឆ្នាំ ២០២០។



HENRI CALVET
អភិបាលឯករាជ្យ

កម្រិតអប់រំ៖ លោកបញ្ចប់ការសិក្សាពី Ecole Normale Supérieure de Cachan និងកម្រិតសាកលវិទ្យាល័យ (Economics, Paris-I Panthéon-Sorbonne)។

លោក Calvet គឺជាស្ថាបនិកនៃ H2C CONSEIL ដែលជាក្រុមហ៊ុនផ្តល់ប្រឹក្សាយោបល់ និងបណ្តុះបណ្តាលដល់គ្រឹះស្ថានឥណទាន និងក្រុមហ៊ុនមូលបត្រ ដោយផ្តោតសំខាន់លើគណនេយ្យធនាគារ ច្បាប់ prudential rules និងការគ្រប់គ្រងផ្ទៃក្នុង (រួមមានការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងការអនុលោមច្បាប់)។

មុនពេលបង្កើតក្រុមហ៊ុនខ្លួនឯង លោកបានចំណាយពេល ១០ឆ្នាំធ្វើការជាមួយធនាគារ French Banking Commission ហើយក្រោយមកបម្រើការឲ្យធនាគារជាច្រើនទៀតមានដូចជា Compagnie Financière Edmond de Rothschild Banque និង Compagnie Parisienne de Reescompte។ល។

លោក Calvet បានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ ABA ក្នុងឆ្នាំ២០១៦។



ETIENNE CHENEVIER
អភិបាលឯករាជ្យ

ដោយបញ្ចប់ការសិក្សាពី Ecole Polytech-nique និង Ecole des Ponts et Chaussées ប្រទេសបារាំង លោក Etienne បានផ្តើមការងារនៅក្រសួងឧស្សាហកម្មបារាំង។ ក្រោយមក លោកចូលរួមក្នុងក្រុមហ៊ុនហ្គាស Air Liquide Group ដែលលោកបានបង្កើតប្រតិបត្តិការលើទឹកដីប្រទេសចិនលើកដំបូងក្នុងឆ្នាំ១៩៩៣ មុនត្រូវបានគេជ្រើសតាំងឲ្យទទួលបន្ទុកកិច្ចព្រមព្រៀងផ្គត់ផ្គង់ដ៏ធំនៃឧស្សាហកម្មហ្គាសដល់វិស័យដែកអ៊ីណុកនៅអាស៊ី។ ក្រោយមកទៀត លោក Etienne ចូលបម្រើការនៅក្រុមហ៊ុន Rio Tinto ដែលលោកបានអភិវឌ្ឍ និងគ្រប់គ្រងលើប្រតិបត្តិការមួយចំនួននៅប្រទេសសិង្ហបុរី, អូស្ត្រាលី, ចិន និងប្រទេសជប៉ុន។

លោកបានចាប់ដៃគូជាមួយក្រុមហ៊ុនបារាំង CityStar ដើម្បីបង្កើត Asian Division ក្នុងឆ្នាំ២០០៥ ដែលលោកជាដៃគូផង និងជាអភិបាលផង។ នៅក្នុងឆ្នាំ២០១៤ លោក Etienne ក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ ABA។



MATHEW WELCH
អភិបាលឯករាជ្យ

លោក Mathew Welch បានបញ្ចប់ការសិក្សាពីសកលវិទ្យាល័យ Oxford ចក្រភពអង់គ្លេស។ បន្ទាប់មក លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតរដ្ឋបាលធុរកិច្ច (MBA) នៅ Harvard Business School។

ឆ្លងកាត់បទពិសោធជាង ២៥ ឆ្នាំនៅអាស៊ី លោកបានបម្រើការនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុនានា រួមមាន HSBC, Standard Chartered និង Merrill Lynch។

លោកបានចំណាយពេលជាច្រើនឆ្នាំនៅក្រុមហ៊ុន McKinsey នៅអាស៊ី។ លោក Mathew ក៏ធ្លាប់កាន់តួនាទីជានាយកគ្រប់គ្រង នៅក្រុមហ៊ុន Temasek Holdings ដោយនៅទីនោះ លោកបានធ្វើការលើផលបត្រជាច្រើននៃធនាគារ និងការវិនិយោគក្រុមហ៊ុនហិរញ្ញវត្ថុនានា។

ក្នុងវិជ្ជាជីវៈកន្លងមក លោក Mathew បានបម្រើការក្នុងក្រុមប្រឹក្សាភិបាល នៅតាមធនាគារ និងក្រុមហ៊ុនផ្តល់សេវាហិរញ្ញវត្ថុជាច្រើនទូទាំងអាស៊ីបាស៊ីហ្វិក ដូចជា សិង្ហបុរី, ឥណ្ឌា, ម៉ង់ហ្គោលី និងវៀតណាម ដោយលោកធ្លាប់ចូលរួមជាសមាជិកនៃគណៈកម្មាធិការសវនកម្ម, ហានិភ័យ, ឥណទាន និងប្រតិបត្តិតាម។

លោក Mathew បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ ABA ក្នុងខែកញ្ញា ឆ្នាំ ២០២៤។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

កាលបរិច្ឆេទ	ប្រភេទកិច្ចប្រជុំ	ឈ្មោះអភិបាលដែលចូលរួមកិច្ចប្រជុំ
១៨ មីនា	កិច្ចប្រជុំផ្ដាល់ ដោយមានការផ្សាយតាមប្រព័ន្ធវីដេអូ (សន្និសីទវីដេអូ)	Yves Jacquot Madi Akmambet Dominic Jacques Martin Ouellet Christian St-Arnaud Paolo Pizzuto Etienne Chenevier Henri Calvet Mathew Welch
១១ មិថុនា	កិច្ចប្រជុំផ្ដាល់ ដោយមានការផ្សាយតាមប្រព័ន្ធវីដេអូ (សន្និសីទវីដេអូ)	Yves Jacquot Madi Akmambet Dominic Jacques Martin Ouellet Christian St-Arnaud Paolo Pizzuto Etienne Chenevier Henri Calvet Mathew Welch
១០ កញ្ញា	កិច្ចប្រជុំផ្ដាល់ ដោយមានការផ្សាយតាមប្រព័ន្ធវីដេអូ (សន្និសីទវីដេអូ)	Yves Jacquot Madi Akmambet Dominic Jacques Martin Ouellet Christian St-Arnaud Paolo Pizzuto Etienne Chenevier Henri Calvet Mathew Welch
១០ ធ្នូ	កិច្ចប្រជុំផ្ដាល់ ដោយមានការផ្សាយតាមប្រព័ន្ធវីដេអូ (សន្និសីទវីដេអូ)	Yves Jacquot Madi Akmambet Dominic Jacques Martin Ouellet Christian St-Arnaud Paolo Pizzuto Etienne Chenevier Henri Calvet Mathew Welch



វិភាគទានសង្គមរបស់សាជីវកម្ម

ទំនួលខុសត្រូវសង្គមរបស់ធនាគារ



ធនាគារ ABA នៅតែប្តេជ្ញាក្នុងការចូលរួមជួយសហគមន៍ តាមរយៈកម្មវិធីទំនួលខុសត្រូវសង្គមជាច្រើន។

នៅឆ្នាំ ២០២៥ ធនាគារបានផ្តោតលើការអប់រំ ចំណេះដឹងហិរញ្ញវត្ថុ សុខភាព សហគ្រិនភាព បច្ចេកវិទ្យាហិរញ្ញវត្ថុ និងនិរន្តរភាពបរិស្ថាន ដោយពង្រឹងតួនាទីរបស់ខ្លួន ក្នុងនាមជាសាជីវកម្មដែលមានទំនួលខុសត្រូវសង្គម។ ជាមួយគោលការណ៍វិភាគទានសង្គមរបស់ខ្លួន ដែលស្របជាមួយនឹងគោលដៅអភិវឌ្ឍន៍ជាតិ ធនាគារ ABA មានគោលបំណងរួមចំណែដល់ការអភិវឌ្ឍយូរអង្វែងនៅក្នុងសង្គមកម្ពុជា។









ការអប់រំ

គម្រោងកែលម្អបរិយាកាសសិក្សាតាមសាលារៀនរដ្ឋ

ABA បានចូលរួមវិភាគទាន ២២ លានរៀល (ប្រហែល ៥.៥០០ ដុល្លារ) ដើម្បីលើកកម្ពស់បរិយាកាសសិក្សា សម្រាប់សិស្សានុសិស្សនៅសាលាបឋមសិក្សាសន្លុង ក្នុងខេត្តតាកែវ។ ការកែលម្អទាំងនេះរួមមាន ការជួសជុលដំបូល និងពិតាន ការបំពាក់ទ្វារ និងបង្អួចថ្មី ដែលធ្វើឲ្យមានរំហូរខ្យល់ចេញចូលគ្រប់គ្រាន់។ ការកែលម្អនេះ បានធ្វើឲ្យថ្នាក់រៀនកាន់តែមានសុវត្ថិភាព និងមានផាសុកភាពជាងមុន សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ នៅបឋមសិក្សាមួយនេះ សរុបចំនួន ៥៤៥ នាក់។

គម្រោងជាមួយសមាគមធនាគារនៅកម្ពុជា (ABC)

ABA បានក្លាយជាអ្នកឧបត្ថម្ភ នៃគំនិតផ្តួចផ្តើមជួសជុលសាលារៀនរបស់ ABC សម្រាប់សាលារៀនចំនួន ១៥ នៅក្នុងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលបានជួសជុលឡើងវិញផ្នែកខាងក្នុង និងខាងក្រៅនៃអគារសាលារៀន ដើម្បីបង្កើតបរិយាកាសសិក្សាល្អសម្រាប់សិស្សានុសិស្ស ។

មូលនិធិកុមារកម្ពុជា (CCF):

ធនាគារ ABA បានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការអប់រំ ដោយបានសន្យាផ្តល់ជំនួយចំនួន ៦០.០០០ ដុល្លារក្នុងរយៈពេលបីឆ្នាំ (២០២៤-២០២៦) ដើម្បីគាំទ្រកម្មវិធីអប់រំបឋមសិក្សារបស់ CCF។ ABA ក៏បានបន្ថែមការគាំទ្រជាថវិកាចំនួន ២០.០០០ ដុល្លារ ដល់កម្មវិធីអាហារូបករណ៍សាកលវិទ្យាល័យឆ្នាំ ២០២៥ របស់ CCF ដើម្បីជួយឲ្យនិស្សិតបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សាដោយជោគជ័យ។

អង្គការរក្សាកុមារ (RKO)

ABA បានចូលរួមវិភាគទានចំនួន ១៦០ លានរៀល (ប្រហែល ៤០.០០០ ដុល្លារ) ដើម្បីគាំទ្រកម្មវិធីសំខាន់ៗចំនួនបីរបស់ RKO ដូចជាការផ្តល់ទឹកស្អាតសម្រាប់បរិភោគ បង្គោលភ្លើងសូឡា និងថ្នាក់រៀនកុំព្យូទ័រដល់សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅក្នុងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។ កម្មវិធីទាំងនេះ មានសារសំខាន់សម្រាប់បេសកកម្មរបស់ខ្លួន ក្នុងការលើកកម្ពស់ និងអភិវឌ្ឍសហគមន៍បានយូរអង្វែង។







មណ្ឌលគាំពារកុមារ គ្រួសារថ្មីតាខ្មៅ

ក្នុងភាពជាដៃគូជាមួយ RKO ធនាគារ ABA បានគាំទ្រការជួសជុលមជ្ឈមណ្ឌលការពាររបស់គ្រួសារថ្មី ដោយជួយឲ្យកុមារចំនួន ៥៥ នាក់កំពុងរស់នៅក្នុងមណ្ឌលទទួលបានបរិយាកាសដែលមានផាសុកភាព និងសុវត្ថិភាពជាងមុន។ កន្លែងដែលបានជួសជុលឡើងវិញរួមមាន ផ្ទះបាយ កន្លែងទុកដាក់ស្បៀងអាហារ ថ្នាក់រៀន និងបន្ទប់គេង។

ការលើកកម្ពស់ការរៀនសូត្រឌីជីថល

ដើម្បីគាំទ្របន្ថែមទៀតដល់លើកកម្ពស់ចំណេះដឹងឌីជីថល ធនាគារ ABA បានបរិច្ចាគកុំព្យូទ័រចំនួន ៣០ គ្រឿងដល់អង្គការស្នាមញញឹមដើម្បីកុមារ (PSE) តាមរយៈ RKO ដើម្បីពង្រឹងបេសកកម្មរបស់ពួកគេក្នុងការអប់រំ និងការពារកុមារក្រីក្រនៅកម្ពុជា។ គំនិតផ្តួចផ្តើមនេះមានគោលបំណងជួយដល់យុវវ័យ ឲ្យមានជំនាញបច្ចេកវិទ្យាសំខាន់ៗ ដែលចាំបាច់ដើម្បីទទួលឱកាសការងារអនាគត នៅក្នុងពិភពឌីជីលូបនីយកម្ម។

ការគាំទ្រកម្មវិធីអាហារូបករណ៍ និងការអប់រំ

តាមរយៈភាពជាដៃគូជាបន្តបន្ទាប់ជាមួយសមាគមនិស្សិតអាហារូបករណ៍សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត (AMT) ធនាគារ ABA បានចូលរួមវិភាគទានចំនួន ១០០.០០០ ដុល្លារ ដើម្បីផ្តល់មូលនិធិដល់កម្មវិធីអាហារូបករណ៍ និងជំនួយហិរញ្ញវត្ថុរបស់ AMT ដើម្បីជួយនិស្សិតមកពីគ្រួសារដែលមានជីវភាពខ្វះខាត ឲ្យទទួលបានការអប់រំកម្រិតឧត្តមសិក្សា និងសម្រេចបានជោគជ័យក្នុងការសិក្សា។







បរិយាបន្នហិរញ្ញវត្ថុ

ការគាំទ្រចំណេះដឹងសេដ្ឋកិច្ច

ធនាគារ ABA បានផ្តល់ថវិកាចំនួន ៥ពាន់ ដុល្លារ តាមរយៈសមាគមធនាគារនៅកម្ពុជា ដើម្បីគាំទ្រដល់ដំណើរទស្សនកិច្ចរបស់សិស្សានុសិស្សទៅកាន់សារមន្ទីរព្រះស្រីឡៀសានវ៉ន (SOSORO) ដោយឥតគិតថ្លៃ ដើម្បីពួកគាត់ទទួលបានការយល់ដឹងអំពីប្រវត្តិសាស្ត្រសេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា។

កម្មវិធីទទួលបានហិរញ្ញប្បទានឆ្នាំ ២០២៥

ធនាគារ ABA បានចូលរួមក្នុងនាមជាឧបត្ថម្ភ ដើម្បីគាំទ្រកម្មវិធី ដែលមានគោលបំណងពង្រឹងលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់ប្រជាពលរដ្ឋដែលមិនទាន់ទទួលបានគ្រប់គ្រាន់។ តាមរយៈការឧបត្ថម្ភគំនិតផ្តួចផ្តើមនេះ ធនាគារជួយកាត់បន្ថយគម្លាតរវាងសេវាកម្មធនាគារ និងសហគមន៍ដែលធ្លាប់មានការខ្វះខាត ឬមិនអាចប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការបាន។

ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល

ABA បានចូលរួមទិវាប្រាក់រៀល ដែលដឹកនាំដោយធនាគារជាតិនៃកម្ពុជា ដើម្បីលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណជាតិ។ គំនិតផ្តួចផ្តើមនេះ លើកតម្កើងមោទនភាពជាតិ ស្ថិរភាពសេដ្ឋកិច្ច និងជំរុញការប្រើប្រាស់ប្រាក់រៀលឲ្យកាន់តែច្រើនទូទាំងប្រទេស។



វេទិកាចំណេះដឹងហិរញ្ញវត្ថុឌីជីថល ២០២៥

ធនាគារ ABA ជាអ្នកឧបត្ថម្ភវេទិកានេះ ដែលមានគោលបំណងផ្តល់ចំណេះដឹងដល់សាធារណជនអំពីសេវាកម្មហិរញ្ញវត្ថុផ្លូវការ និងលើកទឹកចិត្តពួកគាត់ពិនិត្យតាមដានសុខភាពហិរញ្ញវត្ថុរបស់ខ្លួនដើម្បីយល់កាន់តែច្បាស់ អំពីទម្លាប់ចំណាយ និងដើម្បីសម្រេចគោលដៅហិរញ្ញវត្ថុរបស់ពួកគាត់។



កិច្ចប្រឹងប្រែងផ្នែកមនុស្សធម៌ និងការគាំពារសុខភាព

ជំនួយមនុស្សធម៌អំឡុងជម្លោះព្រំដែន

ABA បានបរិច្ចាគថវិកា ១ លាន ដុល្លារ សម្រាប់ជំនួយមនុស្សធម៌ជូនប្រជាពលរដ្ឋ និងពលទាហានដែលរងផលប៉ះពាល់ដោយសារជម្លោះព្រំដែនរវាងកម្ពុជា និងថៃ។ ABA ក៏បានដឹកស្បៀងអាហារ និងបរិក្ខារចាំបាច់ ចំនួន ១០ រថយន្តធំៗទៅកាន់ជំរំភៀសសឹកនៅក្នុងខេត្តចំនួន ៥។

ការគាំទ្រសេវាសុខភាពជនបទ

ABA បានបរិច្ចាគថវិកា ១០០.០០០ ដុល្លារដល់សមាគមគ្រូពេទ្យយុវជនស្ម័គ្រចិត្តសម្តេចតេជោ (TYDA) ដើម្បីគាំទ្រដល់ការព្យាបាលដោយឥតគិតថ្លៃដល់ពលរដ្ឋនៅតំបន់ជនបទ។ ការបរិច្ចាគនេះធានាថាសហគមន៍ដែលខ្វះខាត អាចទទួលបានសេវាសុខភាព និងការព្យាបាលចាំបាច់។









ភាពជាដៃគូជាមួយមន្ទីរពេទ្យកុមារអង្គរ

ABA បានប្តេជ្ញាចិត្តផ្តល់ប្រាក់ចំនួន ៦០.០០០ ដុល្លារក្នុងរយៈពេលបីឆ្នាំ (២០២៤ ដល់ ២០២៦) ដើម្បីគាំទ្រដល់សេវាថែទាំសុខភាពកុមារនៅមន្ទីរពេទ្យកុមារអង្គរ។ នៅឆ្នាំ ២០២៥ ដែលជាឆ្នាំទីពីរនៃការប្តេជ្ញាចិត្តរបស់យើង ធនាគារ ABA បន្តជួយកុមារដែលមានជំងឺ ឲ្យទទួលបានការថែទាំសុខភាពប្រកបដោយគុណភាពខ្ពស់ និងការយកចិត្តទុកដាក់។

បេសកកម្មវះកាត់របស់អង្គការស្នាមញញឹមកម្ពុជា

ABA បានបរិច្ចាគថវិកា ១០.០០០ ដុល្លារ ដើម្បីផ្តល់មូលនិធិដល់កម្មវិធីវះកាត់បបូរមាត់ និងក្រអូមមាត់ឆែមដោយឥតគិតថ្លៃ ជូនប្រពលរដ្ឋខ្មែរទូទាំងប្រទេស។ ការគាំទ្រនេះជួយឲ្យកុមារដែលមានពិការភាពមុខមាត់ ទទួលបានការព្យាបាលឥតគិតថ្លៃ ដើម្បីការរស់ប្រកបដោយសុខភាព និងពេញដោយទំនុកចិត្ត។

កាកបាទក្រហមកម្ពុជា

ធនាគារ ABA បានបរិច្ចាគថវិកា ១០០.០០០ ដុល្លារ ដើម្បីគាំទ្រដល់កម្មវិធីមនុស្សធម៌របស់កាកបាទក្រហមកម្ពុជា រួមមានជំនួយសង្គ្រោះក្នុងគ្រាអាសន្ន, កម្មវិធីថែទាំសុខភាព, និងកិច្ចខិតខំប្រឹងប្រែងសង្គ្រោះសហគមន៍ ដែលជួយដោយផ្ទាល់ដល់ប្រជាពលរដ្ឋងាយរងគ្រោះទូទាំងប្រទេស។



សហគ្រិនភាព

កម្មវិធីនវានុវត្តន៍បញ្ញាស រដូវកាលទី ៥

ក្នុងនាមជាអ្នកឧបត្ថម្ភ Diamond ធនាគារ ABA បានគាំទ្រ កម្មវិធីដែលរៀបចំឡើងដោយមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី “តេជោ” និងបេសកកម្មរបស់មជ្ឈមណ្ឌល ក្នុងការលើកកម្ពស់នវានុវត្តន៍ និងភាពច្នៃប្រឌិត ក្នុងចំណោមធុរកិច្ចថ្មីនៅក្នុងប្រទេស ដែលការណ៍នេះ ជួយជំរុញកំណើនវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជាបន្ថែមទៀតផងដែរ។

វេទិកាសហគ្រិនកំពូលឆ្នាំ ២០២៥

ធនាគារ ABA បានឧបត្ថម្ភវេទិកាសហគ្រិនកំពូល ដែលរៀបចំដោយបណ្តាញសហគ្រិនស្ត្រីកម្ពុជា និងបណ្តាញសហគ្រិនស្ត្រីអាស៊ាន ដែលរំលេចឲ្យឃើញកាន់តែច្បាស់អំពីតួនាទីដ៏សំខាន់នៃសហគ្រិនភាពរបស់ស្ត្រី, កិច្ចសហការក្នុងតំបន់, និងនវានុវត្តន៍ឌីជីថល ក្នុងនាមជាចលករជំរុញកំណើន ។









កម្មវិធីសហគមន៍ និងបរិស្ថាន

ទិវាប្រាក់រៀល ២០២៥

ដើម្បីចូលរួមប្រារព្ធខួបលើកទី៤៥ នៃការដាក់ឲ្យប្រើប្រាស់ប្រាក់រៀលឡើងវិញ ធនាគារ ABA បានចូលរួមក្នុងកម្មវិធីជាច្រើនបន្តបន្ទាប់ ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងលើកកម្ពស់ការប្រើប្រាស់រូបិយប័ណ្ណជាតិ និងបរិយាបន្នហិរញ្ញវត្ថុ។

ជិះកង់ដើម្បីបរិស្ថាន និងសុខភាពកុមារ

ABA បានគាំទ្រព្រឹត្តិការណ៍រៃអង្គាសថវិការបស់មន្ទីរពេទ្យកុមារអង្គរ ដែលបានរៃអង្គាសថវិកាដើម្បីសេវាសុខភាព ស្របពេលដែលសកម្មភាពនេះក៏បានលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន, ជីវិតរស់នៅប្រកបដោយភាពរស់រវើក, និងការចូលរួមសកម្មភាពសហគមន៍។

ពានរង្វាន់ ទេព ឃុនណា

ABA មានមោទនភាពដែលបានចូលរួមជាអ្នកឧបត្ថម្ភកម្មវិធី ការប្រកួតកីឡាវាយកូនបាល់ពានរង្វាន់ ទេព ឃុនណា លើកទី៣០ ឆ្នាំ២០២៥។ ការប្រកួតនេះផ្តល់ឱកាសដល់អត្តពលិកជំនាន់ក្រោយ បង្ហាញទេពកោសល្យរបស់ពួកគាត់, ភ្ជាប់ទំនាក់ទំនងជាមួយកីឡាករអន្តរជាតិ, និងចូលរួមចំណែកអភិវឌ្ឍកីឡាវាយកូនបាល់នៅកម្ពុជា។



កម្មវិធី Bankers' Cycling ២០២៥

ABA បានឧបត្ថម្ភព្រឹត្តិការណ៍នេះ ដើម្បីលើកទឹកចិត្តដល់អ្នកវិជ្ជាជីវៈក្នុងវិស័យធនាគារ ឲ្យមានសកម្មភាពប្រកបដោយសុខភាព នាំមកនូវកាយពលរឹងមាំ។ កម្មវិធីជិះកង់នេះ លើកកម្ពស់ការធ្វើការងារជាក្រុម សុខុមាលភាព និងជីវិតរស់នៅប្រកបដោយភាពរស់រវើក តាមរយៈកីឡា និងការចូលរួមសង្គម សម្រាប់អ្នកដែលបម្រើការងារក្នុងវិស័យហិរញ្ញវត្ថុ។

ក

របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

ព័ត៌មានអំពីធនាគារ

ធនាគារ	ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់	
ចុះបញ្ជីពាណិជ្ជកម្មលេខ	០០០១០៥៩៣	
ទីស្នាក់ការចុះបញ្ជី	អគារលេខ១៤១, ១៤៦, ១៤៨ & ១៤៨ អា បេ សេ ដេ & ១៦២ អា មហាវិថីព្រះសីហនុ ផ្ទះលេខ១៥ & ១៥៣ អា បេ សេ ផ្លូវលេខ២៧៨, ផ្ទះលេv១៧១ ផ្លូវព្រះត្រសក់ផ្អែម ភូមិ៤, សង្កាត់បឹងកេងកងទី១, ខណ្ឌបឹងកេងកង, រាជធានីភ្នំពេញ,ព្រះរាជាណាចក្រកម្ពុជា។	
ភាគទុនិក	ធនាគារជាតិកាណាដា	
	ក្រុមហ៊ុន Natcan Trust Company	
ក្រុមប្រឹក្សាភិបាល	លោក Yves Jacquot	ប្រធានក្រុមប្រឹក្សាភិបាល
	លោក Dominic Jacques	អភិបាល
	លោក Madi Akmambet	អភិបាលប្រតិបត្តិ
	លោក Martin Ouellet	អភិបាល (លាលែងពីតំណែងនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥)
	លោក Christian St – Arnaud	អភិបាល
	លោក Paolo Pizzuto	អភិបាល
	លោក Etienne Chenevier	អភិបាលឯករាជ្យ
	លោក Henri Calvet	អភិបាលឯករាជ្យ
	លោក Mathew Nevil Welch	អភិបាលឯករាជ្យ
គណៈគ្រប់គ្រងសំខាន់ៗ	លោក Askhat Azhikhanov	អគ្គនាយក និងជានាយកប្រតិបត្តិ
	លោក Zhiger Atchabarov	អគ្គនាយករងប្រតិបត្តិ នាយករងប្រតិបត្តិ និងជានាយកប្រតិបត្តិការ
	លោក Babu Ram Gyawali	អគ្គនាយករងប្រតិបត្តិ និងជានាយកហិរញ្ញវត្ថុ
	លោក Galymzhan Temirov	អគ្គនាយករងប្រតិបត្តិ និងជានាយកព័ត៌មានវិទ្យា
	លោក Bibhu Pandey	អគ្គនាយករងប្រតិបត្តិ និងជានាយកឥណទាន
	លោក Sanzhar Abdullayev	អគ្គនាយករងប្រតិបត្តិ និងនាយកផ្នែកកាត និងសេវាកម្មទូទាត់អេឡិចត្រូនិក
	លោក Zokhir Rasulov	អគ្គនាយករងប្រតិបត្តិ និងជានាយកសេវាឌីជីថល
	លោក Igor Zimarev	អគ្គនាយករងប្រតិបត្តិ និងជានាយកទីផ្សារ កិច្ចការ CSR និងលេខាធិការសាជីវកម្ម
	លោក Torsten Kleine Buening	អគ្គនាយករងប្រតិបត្តិ និងជានាយកហានិភ័យ និងទីប្រឹក្សាប្រតិបត្តិតាមសម្រាប់នាយកប្រតិបត្តិ
	លោកស្រី ធាម រមណីយ	អគ្គនាយិការងប្រតិបត្តិ និងជានាយិកាទំនាក់ទំនងគូភាគីប្រធានគ្រប់គ្រងតំបន់
	លោកស្រី ឡុង នីនលីដា	អគ្គនាយិការង និងជានាយិកាគ្រប់គ្រងសាច់ប្រាក់
	លោកស្រី លី វិទ្យា	អគ្គនាយិការង និងជានាយិកាធនធានមនុស្ស
	លោក ឈុន វិចិត្រ	អគ្គនាយករង និងជានាយកសេវាធនាគាររូបវន្តបុគ្គល
	លោក សរ ច័ន្ទវិទ្ធ	អគ្គនាយករង និងជានាយកឥណទានអាជីវកម្មខ្នាតតូច
	លោក ណយ ស៊ីណាក់	អគ្គនាយករង និងជានាយកត្រួតពិនិត្យឥណទាននិងដោះស្រាយបំណុល
	លោក សឹម លីដា	អគ្គនាយករង និងជានាយកឥណទានអាជីវកម្មខ្នាតធំ និងមធ្យម
	លោក អ៊ាង សូរសែន	អគ្គនាយករង និងជានាយកនីតិកម្ម
	លោក អាត ដាឡែន	អគ្គនាយករង និងជានាយករដ្ឋបាល
	លោកស្រី ហៀន ប៉ូលីនដា	អគ្គនាយិការង និងជានាយិកាធុរកិច្ចអន្តរជាតិ
	លោក ប៊ិច គឹមឃុន	អគ្គនាយករង និងជានាយកសន្តិសុខ និងសុវត្ថិភាព
	លោក Watson Thomas Frederick	អគ្គនាយករង និងជានាយកផ្នែកសន្តិសុខព័ត៌មាន
	លោកស្រី ហួត ចាន់ធីតា	អគ្គនាយិការង និងជានាយិកាសេវាធនាគារសាជីវកម្ម
សវនករ	ក្រុមហ៊ុនឌីឡយ៍ធ៍ (ខេមបូឌា) ខូអិលធីឌី	

របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយ សូមបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ហៅកាត់ថា (“ធនាគារ”) និងក្រុមហ៊ុនបុត្រសម្ព័ន្ធ អេប៊ីអេ ត្រាស ឯ.ក (ជារួមហៅកាត់ថា “សម្ព័ន្ធធនាគារ”) និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ (ហៅរួមថា“របាយការណ៍ហិរញ្ញវត្ថុ”) ដែលបានធ្វើសវនកម្មរួច សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ធនាគារ រួមមានការធ្វើប្រតិបត្តិការលើរាល់សកម្មភាពអាជីវកម្មធនាគារ និងការផ្តល់នូវសេវាកម្មវិស័យហិរញ្ញវត្ថុដែលពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពចម្បងរបស់ធនាគារនៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

ធនាគារ កាន់កាប់ភាគហ៊ុនចំនួន ៤៩% របស់ក្រុមហ៊ុន អេប៊ីអេ ត្រាស ឯ.ក ហើយសកម្មភាពសំខាន់របស់ក្រុមហ៊ុនគឺការទិញ លក់ ជួល និងប្រតិបត្តិការអចលនទ្រព្យដែលក្រុមហ៊ុនកាន់កាប់ដោយខ្លួនឯង ឬជួលពីគេ។ ក្រុមហ៊ុន អេប៊ីអេ ត្រាស ឯ.ក ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៥។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារសម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ មានដូចខាងក្រោម ៖

សម្ព័ន្ធធនាគារ	ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ប្រាក់ចំណេញមុនបង់ពន្ធ	៤៧៦.៦៤២	១.៩១១.៨១១	៣៨៣.៧៨៤	១.៥៦២.៣៨៤
ចំណាយពន្ធលើប្រាក់ចំណូល	(៩៩.១១៨)	(៣៩៧.៥៦២)	(៨៤.២៣៣)	(៣៤២.៩១៣)
ប្រាក់ចំណេញក្នុងឆ្នាំ	៣៧៧.៥២៤	១.៥១៤.២៤៩	២៩៩.៥៥១	១.២១៩.៤៧១

ធនាគារ	ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ប្រាក់ចំណេញមុនបង់ពន្ធ	៤៧៦.៦៧១	១.៩១១.៩២៥	៣៨៣.៧៨៤	១.៥៦២.៣៨៤
ចំណាយពន្ធលើប្រាក់ចំណូល	(៩៩.១១៨)	(៣៩៧.៥៦២)	(៨៤.២៣៣)	(៣៤២.៩១៣)
ប្រាក់ចំណេញក្នុងឆ្នាំ	៣៧៧.៥៥៣	១.៥១៤.៣៦៣	២៩៩.៥៥១	១.២១៩.៤៧១

ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងគ្រានេះទេ ក្រៅពីការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភនៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ (ឆ្នាំ២០២៤៖ គ្មាន)។

ដើមទុន

មិនមានការប្រែប្រួលក្នុងការដាក់បញ្ចូលដើមទុនបន្ថែមរបស់ធនាគារក្នុងការិយបរិច្ឆេទនេះទេ។

ការលុបចេញពីបញ្ជី និងសំវិធានធនលើទ្រព្យសកម្មហិរញ្ញវត្ថុ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមស្របទាក់ទងទៅនឹងការលុបចេញពីបញ្ជីនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនរំពឹងថានឹងមានលទ្ធភាពទារត្រលប់វិញនូវលំហូរសាច់ប្រាក់តាមកិច្ចសន្យាទាំងអស់ ឬផ្នែកណាមួយ និងធ្វើសំវិធានធនលើការខាតបង់ឥណទានរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុ ហើយមានការជឿជាក់ថារាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនរំពឹងថានឹងអាចទារត្រលប់បាននូវលំហូរសាច់ប្រាក់តាមកិច្ចសន្យា ត្រូវបានលុបចេញពីបញ្ជី ហើយបានធ្វើសំវិធានធនគ្រប់គ្រាន់លើការខាតបង់ឥណទានរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុ។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនឹងបណ្តាលឲ្យចំនួននៃសំវិធានធនលើការខាតបង់ឥណទានរំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនេះ មានលក្ខណៈមិនគ្រប់គ្រាន់រហូតដល់កម្រិតជាសារវន្តនោះទេ។

ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្របដើម្បីបញ្ជាក់ថាគណៈគ្រប់គ្រងបានប្រតិបត្តិយ៉ាងត្រឹមត្រូវ ដើម្បីប្រាកដថា បណ្តាទ្រព្យសកម្មទាំងឡាយ ដែលទំនងជាមិនអាចបម្រើនៅក្នុងប្រតិបត្តិការអាជីវកម្មទៅតាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចទទួលស្គាល់បានជាក់ស្តែង។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលអាចបណ្តាលឲ្យការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ មានភាពមិនត្រឹមត្រូវនោះទេ។

វិធីសាស្ត្រវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យ ប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ថាមានភាពមិនត្រឹមត្រូវនោះទេ។

បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងអំពី ៖

(ក) ការដាក់បន្ទុកនូវទ្រព្យសកម្មណាមួយរបស់សម្ព័ន្ធធនាគារ និងធនាគារដែលបានកើតឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយ ក្រៅពីបានលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ និង

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះសម្ព័ន្ធធនាគារ និងធនាគារ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់សម្ព័ន្ធធនាគារ និងធនាគារ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេល ១២ ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ។

ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ គណៈគ្រប់គ្រងរបស់សម្ព័ន្ធធនាគារ និងធនាគារ ពុំបានពិនិត្យឃើញកាលៈទេសៈណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារដែលអាចនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវ នោះទេ។

ប្រតិបត្តិការមិនប្រក្រតី

តាមការយល់ដឹងរបស់ក្រុមប្រឹក្សាភិបាល ៖

- លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយធាតុណាមួយ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្តនោះទេ។
- នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានធាតុណាមួយ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទនៃរបាយការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ តាមអ្វីដែលក្រុមប្រឹក្សាភិបាលបានជ្រាប ពុំមានព្រឹត្តិការណ៍ជាសារវន្តណាមួយដែលកើតឡើងបន្ទាប់ពីការិយបរិច្ឆេទនៃរបាយការណ៍ ដែលតម្រូវឲ្យមានការកែសម្រួល ឬលាតត្រដាងក្រៅពីអ្វីដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងកំឡុងការិយបរិច្ឆេទរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

- លោក Yves Jacquot ប្រធានក្រុមប្រឹក្សាភិបាល
- លោក Dominic Jacques អភិបាល
- លោក Madi Akmambet អភិបាលប្រតិបត្តិការ
- លោក Martin Ouellet អភិបាល (លាលែងពីតំណែងនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥)
- លោក Christian St-Arnaud អភិបាល
- លោក Paolo Pizzuto អភិបាល
- លោក Etienne Chenevier អភិបាលឯករាជ្យ
- លោក Henri Calvet អភិបាលឯករាជ្យ
- លោក Mathew Nevil Welch អភិបាលឯករាជ្យ

ផលប្រយោជន៍របស់អភិបាល

ពុំមានអភិបាលណាម្នាក់ ដែលបានកាន់តំណែងនៅក្នុងអំឡុង និងនាចុងការិយបរិច្ឆេទ ទទួលបានផលប្រយោជន៍ នៅក្នុងភាគហ៊ុនរបស់សម្ព័ន្ធធនាគារ និងធនាគារនោះទេ។

អត្ថប្រយោជន៍របស់អភិបាល

នៅក្នុងអំឡុង និងនាចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយ ដែលសម្ព័ន្ធធនាគារ និងធនាគារដើរតួជាគូភាគីក្នុងគោលបំណងអនុញ្ញាតឲ្យសមាជិកក្រុមប្រឹក្សាភិបាល អាចទទួលបាននូវអត្ថប្រយោជន៍ ដោយមធ្យោបាយទិញយកភាគហ៊ុនណាមួយនោះទេ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយសម្ព័ន្ធធនាគារ និងធនាគារ លើកលែងតែការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាល មានភារកិច្ចទទួលខុសត្រូវក្នុងការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុនេះបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា “CIFRSs”)។ ក្រុមប្រឹក្សាភិបាលត្រូវពិនិត្យមើលការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយគណៈគ្រប់គ្រងដែលចាំបាច់ត្រូវ ៖

- អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព។
- អនុលោមទៅតាមស្តង់ដា CIFRSs ឬប្រសិនបើមានការប្រាសចាកណាមួយ ដើម្បីបង្ហាញនូវភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះ ត្រូវបានលាតត្រដាង ពន្យល់និងកំណត់បរិមាណឲ្យបានសមស្របនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីមិនសមស្របក្នុងការសន្មតថាសម្ព័ន្ធធនាគារ និងធនាគារនឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត និង
- ត្រួតពិនិត្យ និងដឹកនាំសម្ព័ន្ធធនាគារ និងធនាគារប្រកបដោយប្រសិទ្ធភាពនិងចូលរួមលើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗទាំងឡាយដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់សម្ព័ន្ធធនាគារ និងធនាគារហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

គណៈគ្រប់គ្រងមានភារកិច្ចទទួលខុសត្រូវ ដើម្បីធានាអះអាងថា រាល់ការតម្រូវខាងលើត្រូវបានអនុវត្ត និងទទួលខុសត្រូវ ក្នុងការការពាររាល់ទ្រព្យសកម្មទាំងអស់របស់សម្ព័ន្ធធនាគារ និងធនាគារ និងចាត់វិធានការសមស្របដើម្បីបញ្ឈៀស និងរកឲ្យឃើញនូវការលួចបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថាសម្ព័ន្ធធនាគារ និងធនាគារបានអនុលោមទៅតាមការតម្រូវ ដូចបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញរួមជាមួយកំណត់សម្គាល់បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នូវស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ដំណាច់ការិយបរិច្ឆេទ ដោយអនុលោមទៅតាមស្តង់ដា CIFRSs និងត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល ហើយគិតត្រឹមកាលបរិច្ឆេទនៃការអនុម័តនេះ មានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាសម្ព័ន្ធធនាគារ និងធនាគារមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទូទាត់បំណុល នៅពេលដល់កាលកំណត់សង។

ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

ចុះហត្ថលេខារួច

_____

លោក Askhat Azhikhanov
អគ្គនាយក និងជានាយកប្រតិបត្តិ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦

របាយការណ៍សវនករឯករាជ្យ

ជូនចំពោះភាគទុនិករបស់ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់

Deloitte.

មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (ហៅកាត់ថា “ធនាគារ”) និងក្រុមហ៊ុនបុត្រសម្ព័ន្ធអេប៊ីអេ ត្រាស ឯ.ក (ហៅជារួមថា “សម្ព័ន្ធធនាគារ”) និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ (ហៅជារួមថា “របាយការណ៍ហិរញ្ញវត្ថុ”) ដែលរួមបញ្ចូលរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដោយឡែករបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងរបាយការណ៍ចំណេញឬខាត និង លទ្ធផលលម្អិតផ្សេងៗរួម និងដោយឡែក របាយការណ៍បម្រែបម្រួលមូលធនរួម និងដោយឡែក និងរបាយការណ៍លំហូរសាច់ប្រាក់រួម និងដោយឡែក សម្រាប់ដំណាច់ការិយបរិច្ឆេទ និងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្តដូចដែលបានបង្ហាញនៅទំព័រទី ៤០ ដល់ទី ១២២។

ជាមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ជាមួយបង្ហាញនូវភាពត្រឹមត្រូវជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា “CIFRSs”)។

មូលដ្ឋានសម្រាប់មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា “CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំដោយអនុលោមទៅតាមស្តង់ដាទាំងនេះ គឺត្រូវបានរៀបរាប់នៅក្នុងផ្នែក ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំឯករាជ្យពីសម្ព័ន្ធធនាគារ និងធនាគារ ដោយអនុលោមទៅតាមក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុតកម្ពុជា ដែលបានចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមជាមួយបទប្បញ្ញត្តិឯករាជ្យភាពដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៃអង្គភាពទទួលខុសត្រូវសាធារណៈនៅប្រទេសកម្ពុជា។ យើងខ្ញុំក៏បានបំពេញនូវការទទួលខុសត្រូវលើក្រមសីលធម៌ផ្សេងៗទៀត ដោយអនុលោមទៅតាមការតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល គឺមានភាពគ្រប់គ្រាន់ និងសមរម្យ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការផ្តល់មតិយោបល់របស់យើងខ្ញុំ។

ព័ត៌មានផ្សេងៗក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករ

គណៈគ្រប់គ្រងទទួលខុសត្រូវទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានព័ត៌មានអំពីធនាគារនៅទំព័រទី ៣៣ និងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលពីទំព័រទី ៣៤ ដល់ទំព័រទី ៣៧ ប៉ុន្តែពុំបានរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់លើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំពុំបានធ្វើការសន្និដ្ឋានអះអាងលើព័ត៌មានផ្សេងៗនេះឡើយ។

ទាក់ទងនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺអានព័ត៌មានផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗនេះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ឬមានកំហុសឆ្គងជាសារវន្តដែលបានកើតឡើង ឬទេ។ ដោយផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញលើព័ត៌មានផ្សេងៗដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តអំពីព័ត៌មានផ្សេងៗនេះ យើងខ្ញុំនឹងរាយការណ៍នូវភាពជាក់ស្តែងនោះ។ យើងខ្ញុំពុំមានអ្វីត្រូវរាយការណ៍ឡើយ។

ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវដោយអនុលោមទៅតាម CIFRSs និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែល គណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃលើលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងបញ្ហាដែលពាក់ព័ន្ធនឹងការបន្តនិរន្តរភាពប្រសិនបើមាន និងការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងមានបំណងរំលាយសម្ព័ន្ធធនាគារ និងធនាគារ ឬបញ្ឈប់អាជីវកម្ម ឬពុំមានជម្រើសជាក់ស្តែងណាមួយក្រៅពីអនុវត្តដូច្នេះ។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើការត្រួតពិនិត្យលើដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ។

ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបានអំណះអំណាងដែលសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុទាំងមូល គឺពុំមានកំហុសឆ្គងជាសារវន្ត ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ និងដើម្បីចេញរបាយការណ៍សវនកររដែលរួមបញ្ចូលមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់ ប៉ុន្តែពុំមែនជាការធានាថាការធ្វើសវនកម្មដែលអនុលោមតាម CISAs នឹងតែងតែរកឃើញជានិច្ចនូវកំហុសឆ្គងជាសារវន្តដែលបានកើតឡើងនោះទេ។ កំហុសឆ្គងអាចកើតឡើងពីការក្លែងបន្លំ ឬការភាន់ច្រឡំ ហើយត្រូវបានពិចារណាជាកំហុសឆ្គងជាសារវន្ត ប្រសិនបើកំហុសឆ្គងនីមួយៗ ឬរួមបញ្ចូលគ្នា ត្រូវបានរំពឹងថាមានឥទ្ធិពល ដល់ការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះជាមូលដ្ឋាន។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សាភាពរឿងឆ្ងល់ប្រកបដោយវិជ្ជាជីវៈ ក្នុងការបំពេញការងារសវនកម្មរបស់យើងខ្ញុំ។ ហើយយើងខ្ញុំបាន៖

- កំណត់ និងវាយតម្លៃលើហានិភ័យនៃកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ដោយរៀបចំ និងអនុវត្តនីតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងដើម្បីទទួលបានភស្តុតាងសវនកម្មដែលគ្រប់គ្រាន់និងសមរម្យ សម្រាប់ជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលពុំបានរកឃើញកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងហានិភ័យដែលបណ្តាលមកពីការភាន់ច្រឡំ ដោយសារតែការក្លែងបន្លំអាចបណ្តាលមកពីការឃុបឃិត ការក្លែងឯកសារ ការលុបចោលដោយចេតនា ការថ្លែងខុស ឬការបំពានលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ទទួលបានការយល់ដឹងពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែពុំមែនដើម្បីបញ្ចេញមតិយោបល់ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់សម្ព័ន្ធធនាគារ និងធនាគារឡើយ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាង ពាក់ព័ន្ធនានាដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រង និងផ្អែកទៅលើភស្តុតាងសវនកម្មដែលបានទទួល ថាតើមានភាពមិនប្រាកដប្រជាជាសារវន្តដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌ ដែលអាចមានការសង្ស័យជាសារវន្តទៅលើលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានភាពមិនប្រាកដប្រជាជាសារវន្ត នោះយើងខ្ញុំត្រូវធ្វើការទាញចំណាប់អារម្មណ៍នៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ ទៅលើការលាតត្រដាងដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងមិនគ្រប់គ្រាន់ យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចបណ្តាលឲ្យសម្ព័ន្ធធនាគារ និងធនាគារបញ្ឈប់ការបន្តនិរន្តរភាពអាជីវកម្ម។
- វាយតម្លៃការបង្ហាញជាទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារ ក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាង និងថាតើរបាយការណ៍ហិរញ្ញវត្ថុ បង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ដែលពាក់ព័ន្ធ ដើម្បីសម្រេចបាននូវការបង្ហាញដែលត្រឹមត្រូវ។
- រៀបចំផែនការ និងធ្វើសវនកម្មសម្ព័ន្ធធនាគារដើម្បីទទួលបាននូវភស្តុតាងសវនកម្មដែលគ្រប់គ្រាន់ និងសមរម្យ ពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុរបស់បណ្តាក្រុមហ៊ុន និងអង្គភាពអាជីវកម្មនានានៅក្នុងសម្ព័ន្ធធនាគារ ជាមូលដ្ឋានដើម្បីបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុរួម។ យើងខ្ញុំទទួលខុសត្រូវលើការដឹកនាំ ការគ្រប់គ្រងនិងការត្រួតពិនិត្យ លើការងារសវនកម្មដែលបានអនុវត្តក្នុងគោលបំណងនៃការធ្វើសវនកម្មរបស់សម្ព័ន្ធធនាគារ។ យើងខ្ញុំនៅតែទទួលខុសត្រូវទាំងស្រុងចំពោះមតិយោបល់សវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំទាក់ទងជាមួយអ្នកទទួលបន្ទុកខាងអភិបាលកិច្ច ពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗ ដូចជា វិសាលភាព និងពេលវេលានៃការធ្វើសវនកម្ម និងការរកឃើញសំខាន់ៗពីសវនកម្ម រួមទាំងកង្វះខាតសំខាន់ៗនៃការត្រួតពិនិត្យផ្ទៃក្នុងដែលបានរកឃើញនៅក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

តំណាងក្រុមហ៊ុន ឌីឡុយធ៍ (ខេមបូឌា) ខូអិលធីឌី

ចុះហត្ថលេខារួច

អ៊ឹង គឹមសុភ័ក្ត្រា
Partner
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម

សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	៤	៦៧៨.៥៧៧	២.៧២៣.១៣០	៥៣៤.៧១៧	២.១៥២.២៣៦
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	៥	២.១០៤.៦៧០	៨.៤៤៦.០៤១	១.៥៨៦.៥៩៦	៦.៣៨៦.០៤៩
សមតុល្យនៅធនាគារនានា	៦	៣.៤៩៩.៨៥៧	១៤.០៤៤.៩២៦	២.៤៧៤.៥៦១	៩.៩៦០.១០៨
ឥណទានផ្តល់ដល់អតិថិជន	៧	៩.៤១៤.៤២២	៣៧.៧៨០.០៧៥	៨.៤៧៥.០៣៣	៣៤.១១២.០០៨
មូលបត្រវិនិយោគ	៨	១២២.៩៤៤	៤៩៣.៣៧៤	៣៩៩.៥៤៤	១.៦០៨.១៦៥
ទ្រព្យសកម្មផ្សេងៗ	៩	១៣១.៦៤៧	៥២៨.២៩៩	១០៣.៦៣៨	៤១៧.១៤៣
ទ្រព្យសម្បត្តិ និងបរិក្ខារ	១០	១០៦.៤២១	៤២៧.០៦៧	៩៦.៩៣១	៣៩០.១៤៧
សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម	១១	៦៨.០៣៩	២៧៣.០៤១	៦៧.៥៥៦	២៧១.៩១៣
ទ្រព្យសកម្មអរូបី	១២	២៦.៤០៤	១០៥.៩៥៩	២០.៨៧៣	៨៤.០១៤
ទ្រព្យសកម្មសរុប		**១៦.១៥២.៩៨១**	**៦៤.៨២១.៩១២**	**១៣.៧៥៩.៤៤៩**	**៥៥.៣៨១.៧៨៣**
បំណុល					
ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ	១៣	១១៩.៤២២	៤៧៩.២៤០	២០៧.០៣៥	៨៣៣.៣១៦
ប្រាក់បញ្ញើរបស់អតិថិជន	១៤	១២.៧៣២.៩១៦	៥១.០៩៧.១៩២	១០.៨០៤.០៧៥	៤៣.៤៨៦.៤០២
ប្រាក់កម្ចី	១៥	២៥២.២៣០	១.០១២.១៩៩	១៧៩.៩៣០	៧២៤.២១៨
បំណុលពន្ធលើប្រាក់ចំណូល	១៦(ក)	៦៤.៣២១	២៥៨.១២០	៤៤.០២៦	១៧៧.២០៥
បំណុលភតិសន្យា	១៧	៧៤.៧៤១	២៩៩.៩៣៦	៧៣.០៤០	២៩៣.៩៨៦
បំណុលផ្សេងៗ	១៨	១៦៣.៩៥៨	៦៥៧.៩៦៣	១០១.៦៧១	៤០៩.២២៦
បំណុលពន្ធពន្យារ	១៦(ខ)	៦៩.៧៤៦	២៧៩.៨៩១	៥១.៥៤៩	២០៧.៤៨៥
បំណុលសរុប		**១៣.៤៧៧.៣៣៤**	**៥៤.០៨៤.៥៤១**	**១១.៤៦១.៣២៦**	**៤៦.១៣១.៨៣៨**
មូលធន					
ដើមទុន	១៩	១.៣២០.០០០	៥.២៩៧.១៦០	១.៣២០.០០០	៥.៣១៣.០០០
ទុនបម្រុងតាមបទប្បញ្ញត្តិ	២០	៥១៧.៦៤២	២.០៧៧.២៩៧	៣៦៧.៧៥៣	១.៤៨០.២០៦
ប្រាក់ចំណេញរក្សាទុក		៨៣៨.០០៥	៣.៣៨៥.១០៥	៦១០.៣៧០	២.៤៧២.០៦១
លម្អៀងពីការប្តូររូបិយប័ណ្ណ		–	(២២.១៩១)	–	(១៥.៣២២)
មូលធនសរុប		**២.៦៧៥.៦៤៧**	**១០.៧៣៧.៣៧១**	**២.២៩៨.១២៣**	**៩.២៤៩.៩៤៥**
បំណុល និងមូលធនសរុប		**១៦.១៥២.៩៨១**	**៦៤.៨២១.៩១២**	**១៣.៧៥៩.៤៤៩**	**៥៥.៣៨១.៧៨៣**

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី ៥០ ដល់ទី ១២២ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍ចំណេញឬខាត និង លទ្ធផលលម្អិតផ្សេងៗរួម

សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ចំណូលពីការប្រាក់	២១	៨៧៧.១៣២	៣.៥១៨.១៧៦	៨៣៤.២៤៥	៣.៣៩៦.២១១
ចំណាយលើការប្រាក់	២១	(១៦៤.៤៩៣)	(៦៥៩.៧៨១)	(២១៤.១១៤)	(៨៧១.៦៥៨)
ចំណូលពីការប្រាក់សុទ្ធ		**៧១២.៦៣៩**	**២.៨៥៨.៣៩៥**	**៦២០.១៣១**	**២.៥២៤.៥៥៣**
ចំណូលពីកម្រៃជើងសា	២២	១០៩.៩៤០	៤៤០.៩៦៩	៩៣.១៩៤	៣៧៩.៣៩៣
ចំណាយលើកម្រៃជើងសា	២២	(៦៩.៨៨៨)	(២៨០.៣២១)	(៥៤.៨១៧)	(២២៣.១៦០)
ចំណូលពីកម្រៃជើងសាសុទ្ធ		**៤០.០៥២**	**១៦០.៦៤៨**	**៣៨.៣៧៧**	**១៥៦.២៣៣**
ចំណូលប្រតិបត្តិការផ្សេងៗ		៣៦.៦៤៦	១៤៦.៩៨៧	២៤.៨៩៨	១០១.៣៦០
ចំណាយបុគ្គលិក	២៣	(១៣៨.២៤១)	(៥៥៤.៤៨៣)	(១២៤.២៩២)	(៥០៥.៩៩៣)
ចំណាយរំលស់	២៤	(៣៥.២៥៦)	(១៤១.៤១២)	(៣២.៦៩៨)	(១៣៣.១១៤)
ចំណាយប្រតិបត្តិការ	២៥	(៦២.០៥៩)	(២៤៨.៩១៩)	(៥៥.៣៣៣)	(២២៥.២៦១)
ការខាតបង់សុទ្ធនៃឱនភាពតម្លៃ លើទ្រព្យសកម្មហិរញ្ញវត្ថុ	២៦	(៧៧.១៣៩)	(៣០៩.៤០៥)	(៨៧.២៩៩)	(៣៥៥.៣៩៤)
ប្រាក់ចំណេញមុនបង់ពន្ធ		**៤៧៦.៦៤២**	**១.៩១១.៨១១**	**៣៨៣.៧៨៤**	**១.៥៦២.៣៨៤**
ពន្ធលើប្រាក់ចំណូល	១៦(គ)	(៩៩.១១៨)	(៣៩៧.៥៦២)	(៨៤.២៣៣)	(៣៤២.៩១៣)
ប្រាក់ចំណេញក្នុងឆ្នាំ		**៣៧៧.៥២៤**	**១.៥១៤.២៤៩**	**២៩៩.៥៥១**	**១.២១៩.៤៧១**
លទ្ធផលលម្អិតផ្សេងៗ		–	(៦.៨៦៩)	–	(៣៤.៤៧៣)
លទ្ធផលលម្អិតសរុបក្នុងឆ្នាំ		**៣៧៧.៥២៤**	**១.៥០៧.៣៨០**	**២៩៩.៥៥១**	**១.១៨៤.៩៩៨**
ប្រាក់ចំណេញផ្តល់ដល់ម្ចាស់ធនាគារ		**៣៧៧.៥២៤**	**១.៥១៤.២៤៩**	**២៩៩.៥៥១**	**១.២១៩.៤៧១**
លទ្ធផលលម្អិតសរុបផ្តល់ដល់ម្ចាស់ធនាគារ		**៣៧៧.៥២៤**	**១.៥០៧.៣៨០**	**២៩៩.៥៥១**	**១.១៨៤.៩៩៨**

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី ៥០ ដល់ទី ១២២ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

របាយការណ៍បម្រែបម្រួលមូលធនរួម

សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	ផ្តល់ដល់ម្ចាស់ធនាគារ								
		ដើមទុន	ទុនបម្រុងតាមបទប្បញ្ញត្តិ		ប្រាក់ចំណេញរក្សាទុក		លម្អៀងពីការប្តូរ រូបិយប័ណ្ណ	សរុប	
	ពាន់ដុល្លារ អាមេរិក	លានរៀល	ពាន់ដុល្លារ អាមេរិក	លានរៀល	ពាន់ដុល្លារ អាមេរិក	លានរៀល	លានរៀល	ពាន់ដុល្លារ អាមេរិក	លានរៀល
ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤									
ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤	១.១០០.០០០	៤.៤៩៣.៥០០	២២១.៦៥៧	៩០៥.៤៧០	៤៥៦.៩១៥	១.៨៤៧.៣៤៧	១៩.១៥១	១.៧៧៨.៥៧២	៧.២៦៥.៤៦៨
ប្រាក់ចំណេញក្នុងឆ្នាំ	–	–	–	–	២៩៩.៥៥១	១.២១៩.៤៧១	–	២៩៩.៥៥១	១.២១៩.៤៧១
លទ្ធផលលម្អិតផ្សេងៗ – លម្អៀងពីការប្តូរ រូបិយប័ណ្ណ	–	–	–	–	–	–	(៣៤.៤៧៣)	–	(៣៤.៤៧៣)
	–	–	–	–	២៩៩.៥៥១	១.២១៩.៤៧១	(៣៤.៤៧៣)	២៩៩.៥៥១	១.១៨៤.៩៩៨
ការបោះផ្សាយដើមទុនបន្ថែម	២២០.០០០	៨៩៥.៦២០	–	–	–	–	–	២២០.០០០	៨៩៥.៦២០
ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅ ទុនបម្រុងតាមបទប្បញ្ញត្តិ	–	–	១៤៦.០៩៦	៥៩៤.៧៥៧	(១៤៦.០៩៦)	(៥៩៤.៧៥៧)	–	–	–
លម្អៀងពីការប្តូរ រូបិយប័ណ្ណ	–	(៧៦.១២០)	–	(២០.០២១)	–	–	–	–	(៩៦.១៤១)
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	**១.៣២០.០០០**	**៥.៣១៣.០០០**	**៣៦៧.៧៥៣**	**១.៤៨០.២០៦**	**៦១០.៣៧០**	**២.៤៧២.០៦១**	**(១៥.៣២២)**	**២.២៩៨.១២៣**	**៩.២៤៩.៩៤៥**
ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥									
ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	១.៣២០.០០០	៥.៣១៣.០០០	៣៦៧.៧៥៣	១.៤៨០.២០៦	៦១០.៣៧០	២.៤៧២.០៦១	(១៥.៣២២)	២.២៩៨.១២៣	៩.២៤៩.៩៤៥
ប្រាក់ចំណេញក្នុងឆ្នាំ	–	–	–	–	៣៧៧.៥២៤	១.៥១៤.២៤៩	–	៣៧៧.៥២៤	១.៥១៤.២៤៩
លទ្ធផលលម្អិតផ្សេងៗ – លម្អៀងពីការប្តូរ រូបិយប័ណ្ណ	–	–	–	–	–	–	(៦.៨៦៩)	–	(៦.៨៦៩)
	–	–	–	–	៣៧៧.៥២៤	១.៥១៤.២៤៩	(៦.៨៦៩)	៣៧៧.៥២៤	១.៥០៧.៣៨០
ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅ ទុនបម្រុងតាមបទប្បញ្ញត្តិ	–	–	១៤៩.៨៨៩	៦០១.២០៥	(១៤៩.៨៨៩)	(៦០១.២០៥)	–	–	–
លម្អៀងពីការប្តូរ រូបិយប័ណ្ណ	–	(១៥.៨៤០)	–	(៤.១១៤)	–	–	–	–	(១៩.៩៥៤)
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**១.៣២០.០០០**	**៥.២៩៧.១៦០**	**៥១៧.៦៤២**	**២.០៧៧.២៩៧**	**៨៣៨.០០៥**	**៣.៣៨៥.១០៥**	**(២២.១៩១)**	**២.៦៧៥.៦៤៧**	**១០.៧៣៧.៣៧១**

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី ៥០ ដល់ទី ១២២ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍លំហូរសាច់ប្រាក់ដោយឡែក

សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
ប្រាក់ចំណេញមុនបង់ពន្ធ		៤៧៦.៦៤២	១.៩១១.៨១១	៣៨៣.៧៨៤	១.៥៦២.៣៨៤
និយ័តភាព៖					
ចំណាយរំលស់	២៤	៣៥.២៥៦	១៤១.៤១២	៣២.៦៩៨	១៣៣.១១៤
ការខាតបង់សុទ្ធនៃឱនភាពតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ	២៦	៧៧.១៣៩	៣០៩.៤០៥	៨៧.២៩៩	៣៥៥.៣៩៤
ចំណេញពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ		(៦)	(២៤)	(២៧)	(១១០)
ចំណេញពីការកែប្រែភតិសន្យា		(១០)	(៤០)	(១១)	(៤៥)
ចំណូលពីការប្រាក់សុទ្ធ	២១	(៧១២.៦៣៩)	(២.៨៥៨.៣៩៥)	(៦២០.១៣១)	(២.៥២៤.៥៥៣)
		(១២៣.៦១៨)	**(៤៩៥.៨៣១)**	**(១១៦.៣៨៨)**	**(៤៧៣.៨១៦)**
បម្រែបម្រួលក្នុង៖					
សមតុល្យនៅធនាគារជាតិនៃកម្ពុជា		(៤៧១.១០៦)	(១.៨៨៩.៦០៧)	(២៧៩.៥៩៣)	(១.១៣៨.២២៣)
សមតុល្យនៅធនាគារនានា		(១.៤៥៥.៣៦៣)	(៥.៨៣៧.៤៦១)	(៣៤១.២៧៨)	(១.៣៨៩.៣៤៣)
ឥណទានផ្តល់ដល់អតិថិជន		(១.០១៨.៤៦៤)	(៤.០៨៥.០៥៩)	(៧៤១.៥១៥)	(៣.០១៨.៧០៨)
ទ្រព្យសកម្មផ្សេងៗ		(៣០.៩៦៤)	(១២៤.១៩៧)	៤៦០	១.៨៧៣
ប្រាក់បញ្ញើរបស់ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ		(៨៦.១៨៥)	(៣៤៥.៦៨៨)	៩៨៧	៤.០១៨
ប្រាក់បញ្ញើរបស់អតិថិជន		១.៩៥៨.០៨៧	៧.៨៥៣.៨៨៧	១.៧៩៧.៨២៧	៧.៣១៨.៩៥៤
បំណុលផ្សេងៗ		៥៤.៩៦៧	២២០.៤៧៣	១០.៣៤២	៤២.១០២
សាច់ប្រាក់សុទ្ធ (ប្រើក្នុង)/បានពីប្រតិបត្តិការ		**(១.១៧២.៦៤៦)**	**(៤.៧០៣.៤៨៣)**	**៣៣០.៨៤២**	**១.៣៤៦.៨៥៧**
ការប្រាក់បានទទួល		៨៦៧.៨៦៨	៣.៤៨១.០១៩	៧៨៥.៩១៣	៣.១៩៩.៤៥២
ការប្រាក់បានបង់		(១៩០.៣០៥)	(៧៦៣.៣១៣)	(២៣១.៣៧៣)	(៩៤១.៩១៩)
ពន្ធលើប្រាក់ចំណូលបានបង់		(៥៥.៦២៦)	(២២៣.១១៦)	(៥៧.៨៦៥)	(២៣៥.៥៦៨)
សាច់ប្រាក់សុទ្ធ (ប្រើក្នុង)/បានពីសកម្មភាពប្រតិបត្តិការ		**(៥៥០.៧០៩)**	**(២.២០៨.៨៩៣)**	**៨២៧.៥១៧**	**៣.៣៦៨.៨២២**

	កំណត់សម្គាល់	ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
ការទិញមូលបត្រវិនិយោគ		(១៧៥.១២៤)	(៧០២.៤២២)	(៤៤១.៩០១)	(១.៧៩៨.៩៧៩)
សាច់ប្រាក់បានពីការលក់ មូលបត្រវិនិយោគ		៤៤៥.០៦៦	១.៧៨៥.១៦០	៣៨៣.៥២៤	១.៥៦១.៣២៦
ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ		(២៦.៨៩៧)	(១០៧.៨៨៤)	(២៨.៣០៣)	(១១៥.២២២)
ការទិញទ្រព្យសកម្មអរូបី		(៩.៦៩២)	(៣៨.៨៧៥)	(៨.០៥០)	(៣២.៧៧២)
សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ		៧	២៨	២៩	១១៨
សាច់ប្រាក់សុទ្ធ បានពី/(ប្រើប្រាស់) ក្នុងសកម្មភាពវិនិយោគ		**២៣៣.៣៦០**	**៩៣៦.០០៧**	**(៩៤.៧០១)**	**(៣៨៥.៥២៩)**
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
ការបោះផ្សាយដើមទុនបន្ថែម		–	–	២២០.០០០	៨៩៥.៦២០
សាច់ប្រាក់បានពីប្រាក់កម្ចី		៩៩១.៨០៩	៣.៩៧៨.១៤៦	១.២១៨.៤១៥	៤.៩៦០.១៦៧
ការទូទាត់សងប្រាក់កម្ចី		(៩២០.៦៤៩)	(៣.៦៩២.៧២៣)	(១.១៨៤.៥៥១)	(៤.៨២២.៣០៧)
ការទូទាត់សងអនុបំណុល		–	–	(៩៦.០០០)	(៣៩០.៨១៦)
ការទូទាត់សងប្រាក់ដើមភតិសន្យា		(១៥.៨៩៥)	(៦៣.៧៥៥)	(១៤.៧៥៥)	(៦០.០៦៨)
សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន		**៥៥.២៦៥**	**២២១.៦៦៨**	**១៤៣.១០៩**	**៥៨២.៥៩៦**
ការ(ថយចុះ) /កើនឡើងសុទ្ធនូវសាច់ប្រាក់ និង សាច់ប្រាក់សមមូល		(២៦២.០៨៤)	(១.០៥១.២១៨)	៨៧៥.៩២៥	៣.៥៦៥.៨៨៩
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ		២.២១១.០៦០	៨.៨៩៩.៥១៧	១.៣៣៥.១៣៥	៥.៤៥៤.០២៥
លម្អៀងពីការប្តូររូបិយប័ណ្ណ		–	(២៧.០៥៨)	–	(១២០.៣៩៧)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ	**២៧**	**១.៩៤៨.៩៧៦**	**៧.៨២១.២៤១**	**២.២១១.០៦០**	**៨.៨៩៩.៥១៧**

ប្រតិបត្តិការមិនមែនសាច់ប្រាក់សំខាន់ៗ

ក្នុងអំឡុងឆ្នាំ២០២៥ មិនមានប្រតិបត្តិការមិនមែនជាសាច់ប្រាក់គួរអោយកត់សម្គាល់នោះទេ។

នៅឆ្នាំ២០២៤ មានការបន្តមូលបត្របំណុលសាជីវកម្មចំនួន ៣០ លានដុល្លារអាមេរិកដែលចេញដោយក្រុមហ៊ុន ខេមបូឌាអ៊ែរផតអិនវេសមិនង.ក សម្រាប់ការសាងសង់ និងអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិតេជោ។

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី ៥០ ដល់ទី ១២២ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយឡែក

សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	៤	៦៧៨.៥៧៧	២.៧២៣.១៣០	៥៣៤.៧១៧	២.១៥២.២៣៦
សមតុល្យនៅធនាគារជាតិនៃកម្ពុជា	៥	២.១០៤.៦៧០	៨.៤៤៦.០៤១	១.៥៨៦.៥៩៦	៦.៣៨៦.០៤៩
សមតុល្យនៅធនាគារនានា	៦	៣.៤៩៩.៨៥៧	១៤.០៤៤.៩២៦	២.៤៧៤.៥៦១	៩.៩៦០.១០៨
ឥណទានផ្តល់ដល់អតិថិជន	៧	៩.៤១៤.៤២២	៣៧.៧៨០.០៧៥	៨.៤៧៥.០៣៣	៣៤.១១២.០០៨
មូលបត្រវិនិយោគ	៨	១២២.៩៤៤	៤៩៣.៣៧៤	៣៩៩.៥៤៤	១.៦០៨.១៦៥
ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ		១.០០០	៤.០១៣	–	–
ទ្រព្យសកម្មផ្សេងៗ	៩	១៣១.៤៨៨	៥២៧.៦៦១	១០៣.៦៣៨	៤១៧.១៤៣
ទ្រព្យសម្បត្តិ និងបរិក្ខារ	១០	១០៦.៤១៩	៤២៧.០៥៩	៩៦.៩៣១	៣៩០.១៤៧
សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម	១១	៦៨.០៣៩	២៧៣.០៤១	៦៧.៥៥៦	២៧១.៩១៣
ទ្រព្យសកម្មអរូបី	១២	២៦.៤០៤	១០៥.៩៥៩	២០.៨៧៣	៨៤.០១៤
ទ្រព្យសកម្មសរុប		**១៦.១៥៣.៨២០**	**៦៤.៨២៥.២៧៩**	**១៣.៧៥៩.៤៤៩**	**៥៥.៣៨១.៧៨៣**
បំណុល					
ប្រាក់បញ្ញើរបស់ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ	១៣	១១៩.៤២២	៤៧៩.២៤០	២០៧.០៣៥	៨៣៣.៣១៦
ប្រាក់បញ្ញើរបស់អតិថិជន	១៤	១២.៧៣៣.៧២៥	៥១.១០០.៤៣៨	១០.៨០៤.០៧៥	៤៣.៤៨៦.៤០២
ប្រាក់កម្ចី	១៥	២៥២.២៣០	១.០១២.១៩៩	១៧៩.៩៣០	៧២៤.២១៨
បំណុលពន្ធលើប្រាក់ចំណូល	១៦(ក)	៦៤.៣២១	២៥៨.១២០	៤៤.០២៦	១៧៧.២០៥
បំណុលភតិសន្យា	១៧	៧៤.៧៤១	២៩៩.៩៣៦	៧៣.០៤០	២៩៣.៩៨៦
បំណុលផ្សេងៗ	១៨	១៦៣.៩៥៩	៦៥៧.៩៦៨	១០១.៦៧១	៤០៩.២២៦
បំណុលពន្ធពន្យារ	១៦(ខ)	៦៩.៧៤៦	២៧៩.៨៩១	៥១.៥៤៩	២០៧.៤៨៥
បំណុលសរុប		**១៣.៤៧៨.១៤៤**	**៥៤.០៨៧.៧៩២**	**១១.៤៦១.៣២៦**	**៤៦.១៣១.៨៣៨**
មូលធន					
ដើមទុន	១៩	១.៣២០.០០០	៥.២៩៧.១៦០	១.៣២០.០០០	៥.៣១៣.០០០
ទុនបម្រុងតាមបទប្បញ្ញត្តិ	២០	៥១៧.៦៤២	២.០៧៧.២៩៧	៣៦៧.៧៥៣	១.៤៨០.២០៦
ប្រាក់ចំណេញរក្សាទុក		៨៣៨.០៣៤	៣.៣៨៥.២១៩	៦១០.៣៧០	២.៤៧២.០៦១
លម្អៀងពីការប្តូររូបិយប័ណ្ណ		–	(២២.១៨៩)	–	(១៥.៣២២)
មូលធនសរុប		**២.៦៧៥.៦៧៦**	**១០.៧៣៧.៤៨៧**	**២.២៩៨.១២៣**	**៩.២៤៩.៩៤៥**
បំណុល និងមូលធនសរុប		**១៦.១៥៣.៨២០**	**៦៤.៨២៥.២៧៩**	**១៣.៧៥៩.៤៤៩**	**៥៥.៣៨១.៧៨៣**

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី ៥០ ដល់ទី ១២២ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍ចំណេញឬខាត និង លទ្ធផលលម្អិតផ្សេងៗដោយឡែក

សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ចំណូលពីការប្រាក់	២១	៨៧៧.១៣២	៣.៥១៨.១៧៦	៨៣៤.២៤៥	៣.៣៩៦.២១១
ចំណាយលើការប្រាក់	២១	(១៦៤.៥០១)	(៦៥៩.៨១៤)	(២១៤.១១៤)	(៨៧១.៦៥៨)
ចំណូលពីការប្រាក់សុទ្ធ		**៧១២.៦៣១**	**២.៨៥៨.៣៦២**	**៦២០.១៣១**	**២.៥២៤.៥៥៣**
ចំណូលពីកម្រៃជើងសា	២២	១០៩.៩៤០	៤៤០.៩៦៩	៩៣.១៩៤	៣៧៩.៣៩៣
ចំណាយលើកម្រៃជើងសា	២២	(៦៩.៨៨៨)	(២៨០.៣២១)	(៥៤.៨១៧)	(២២៣.១៦០)
ចំណូលពីកម្រៃជើងសាសុទ្ធ		**៤០.០៥២**	**១៦០.៦៤៨**	**៣៨.៣៧៧**	**១៥៦.២៣៣**
ចំណូលប្រតិបត្តិការផ្សេងៗ		៣៦.៦៥៨	១៤៧.០៣៥	២៤.៨៩៨	១០១.៣៦០
ចំណាយបុគ្គលិក	២៣	(១៣៨.២២៣)	(៥៥៤.៤១២)	(១២៤.២៩២)	(៥០៥.៩៩៣)
ចំណាយរំលស់	២៤	(៣៥.២៥៦)	(១៤១.៤១២)	(៣២.៦៩៨)	(១៣៣.១១៤)
ចំណាយប្រតិបត្តិការ	២៥	(៦២.០៥២)	(២៤៨.៨៩១)	(៥៥.៣៣៣)	(២២៥.២៦១)
ការខាតបង់សុទ្ធនៃឱនភាពតម្លៃ លើទ្រព្យសកម្មហិរញ្ញវត្ថុ	២៦	(៧៧.១៣៩)	(៣០៩.៤០៥)	(៨៧.២៩៩)	(៣៥៥.៣៩៤)
ប្រាក់ចំណេញមុនបង់ពន្ធ		**៤៧៦.៦៧១**	**១.៩១១.៩២៥**	**៣៨៣.៧៨៤**	**១.៥៦២.៣៨៤**
ពន្ធលើប្រាក់ចំណូល	១៦(គ)	(៩៩.១១៨)	(៣៩៧.៥៦២)	(៨៤.២៣៣)	(៣៤២.៩១៣)
ប្រាក់ចំណេញក្នុងឆ្នាំ		**៣៧៧.៥៥៣**	**១.៥១៤.៣៦៣**	**២៩៩.៥៥១**	**១.២១៩.៤៧១**
លទ្ធផលលម្អិតផ្សេងៗ		–	(៦.៨៦៧)	–	(៣៤.៤៧៣)
លទ្ធផលលម្អិតសរុបក្នុងឆ្នាំ		**៣៧៧.៥៥៣**	**១.៥០៧.៤៩៦**	**២៩៩.៥៥១**	**១.១៨៤.៩៩៨**

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី ៥០ ដល់ទី ១២២ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍បម្រែបម្រួលមូលធនដោយឡែក

សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	ដើមទុន		ទុនបម្រុងតាមបទប្បញ្ញត្តិ		ប្រាក់ចំណេញរក្សាទុក		លម្អៀងពីការប្តូររូបិយប័ណ្ណ	សរុប	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤									
ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤	១.១០០.០០០	៤.៤៩៣.៥០០	២២១.៦៥៧	៩០៥.៤៧០	៤៥៦.៩១៥	១.៨៤៧.៣៤៧	១៩.១៥១	១.៧៧៨.៥៧២	៧.២៦៥.៤៦៨
ប្រាក់ចំណេញក្នុងឆ្នាំ	–	–	–	–	២៩៩.៥៥១	១.២១៩.៤៧១	–	២៩៩.៥៥១	១.២១៩.៤៧១
លទ្ធផលលម្អិតផ្សេងៗ – លម្អៀងពីការប្តូររូបិយប័ណ្ណ	–	–	–	–	–	–	(៣៤.៤៧៣)	–	(៣៤.៤៧៣)
	–	–	–	–	២៩៩.៥៥១	១.២១៩.៤៧១	(៣៤.៤៧៣)	២៩៩.៥៥១	១.១៨៤.៩៩៨
ការបោះផ្សាយដើមទុនបន្ថែម	២២០.០០០	៨៩៥.៦២០	–	–	–	–	–	២២០.០០០	៨៩៥.៦២០
ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ	–	–	១៤៦.០៩៦	៥៩៤.៧៥៧	(១៤៦.០៩៦)	(៥៩៤.៧៥៧)	–	–	–
លម្អៀងពីការប្តូររូបិយប័ណ្ណ	–	(៧៦.១២០)	–	(២០.០២១)	–	–	–	–	(៩៦.១៤១)
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	**១.៣២០.០០០**	**៥.៣១៣.០០០**	**៣៦៧.៧៥៣**	**១.៤៨០.២០៦**	**៦១០.៣៧០**	**២.៤៧២.០៦១**	**(១៥.៣២២)**	**២.២៩៨.១២៣**	**៩.២៤៩.៩៤៥**
ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥									
ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥	១.៣២០.០០០	៥.៣១៣.០០០	៣៦៧.៧៥៣	១.៤៨០.២០៦	៦១០.៣៧០	២.៤៧២.០៦១	(១៥.៣២២)	២.២៩៨.១២៣	៩.២៤៩.៩៤៥
ប្រាក់ចំណេញក្នុងឆ្នាំ	–	–	–	–	៣៧៧.៥៥៣	១.៥១៤.៣៦៣	–	៣៧៧.៥៥៣	១.៥១៤.៣៦៣
លទ្ធផលលម្អិតផ្សេងៗ – លម្អៀងពីការប្តូររូបិយប័ណ្ណ	–	–	–	–	–	–	(៦.៨៦៧)	–	(៦.៨៦៧)
	–	–	–	–	៣៧៧.៥៥៣	១.៥១៤.៣៦៣	(៦.៨៦៧)	៣៧៧.៥៥៣	១.៥០៧.៤៩៦
ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ	–	–	១៤៩.៨៨៩	៦០១.២០៥	(១៤៩.៨៨៩)	(៦០១.២០៥)	–	–	–
លម្អៀងពីការប្តូររូបិយប័ណ្ណ	–	(១៥.៨៤០)	–	(៤.១១៤)	–	–	–	–	(១៩.៩៥៤)
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	**១.៣២០.០០០**	**៥.២៩៧.១៦០**	**៥១៧.៦៤២**	**២.០៧៧.២៩៧**	**៨៣៨.០៣៤**	**៣.៣៨៥.២១៩**	**(២២.១៨៩)**	**២.៦៧៥.៦៧៦**	**១០.៧៣៧.៤៨៧**

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី ៥០ ដល់ទី ១២២ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

របាយការណ៍លំហូរសាច់ប្រាក់ដោយឡែក

សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
ប្រាក់ចំណេញមុនបង់ពន្ធ		៤៧៦.៦៧១	១.៩១១.៩២៥	៣៨៣.៧៨៤	១.៥៦២.៣៨៤
និយ័តភាព៖					
ចំណាយរំលស់	២៤	៣៥.២៥៦	១៤១.៤១២	៣២.៦៩៨	១៣៣.១១៤
ការខាតបង់សុទ្ធនៃឱនភាពតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ	២៦	៧៧.១៣៩	៣០៩.៤០៥	៨៧.២៩៩	៣៥៥.៣៩៤
ចំណេញពីការលក់ទ្រព្យសម្បត្តិនិងបរិក្ខារ		(៦)	(២៤)	(២៧)	(១១០)
ចំណេញពីការកែប្រែភតិសន្យា		(១០)	(៤០)	(១១)	(៤៥)
ចំណូលពីការប្រាក់សុទ្ធ	២១	(៧១២.៦៣១)	(២.៨៥៨.៣៦២)	(៦២០.១៣១)	(២.៥២៤.៥៥៣)
		(១២៣.៥៨១)	**(៤៩៥.៦៨៤)**	**(១១៦.៣៨៨)**	**(៤៧៣.៨១៦)**
បម្រែបម្រួលក្នុង៖					
សមតុល្យនៅធនាគារជាតិនៃកម្ពុជា		(៤៧១.១០៦)	(១.៨៨៩.៦០៦)	(២៧៩.៥៩៣)	(១.១៣៨.២២៣)
សមតុល្យនៅធនាគារនានា		(១.៤៥៥.៣៦៣)	(៥.៨៣៧.៤៦១)	(៣៤១.២៧៨)	(១.៣៨៩.៣៤៣)
ឥណទានផ្តល់ដល់អតិថិជន		(១.០១៨.៤៦៤)	(៤.០៨៥.០៥៩)	(៧៤១.៥១៥)	(៣.០១៨.៧០៨)
ទ្រព្យសកម្មផ្សេងៗ		(៣១.៣១៥)	(១២៥.៦០៤)	៤៦០	១.៨៧៣
ប្រាក់បញ្ញើរបស់ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ		(៨៦.១៨៥)	(៣៤៥.៦៨៨)	៩៨៧	៤.០១៨
ប្រាក់បញ្ញើរបស់អតិថិជន		១.៩៥៨.៨៩៦	៧.៨៥៧.១៣២	១.៧៩៧.៨២៧	៧.៣១៨.៩៥៤
បំណុលផ្សេងៗ		៥៤.៩៦៨	២២០.៤៧៧	១០.៣៤២	៤២.១០២
សាច់ប្រាក់សុទ្ធ (ប្រើក្នុង)/បានពីប្រតិបត្តិការ		**(១.១៧២.១៥០)**	**(៤.៧០១.៤៩៣)**	**៣៣០.៨៤២**	**១.៣៤៦.៨៥៧**
ការប្រាក់បានទទួល		៨៦៧.៨៦៨	៣.៤៨១.០១៩	៧៨៥.៩១៣	៣.១៩៩.៤៥២
ការប្រាក់បានបង់		(១៩០.៣១៣)	(៧៦៣.៣៤៥)	(២៣១.៣៧៣)	(៩៤១.៩១៩)
ពន្ធលើប្រាក់ចំណូលបានបង់		(៥៥.៦២៦)	(២២៣.១១៦)	(៥៧.៨៦៥)	(២៣៥.៥៦៨)
សាច់ប្រាក់សុទ្ធ (ប្រើក្នុង)/បានពីសកម្មភាពប្រតិបត្តិការ		**(៥៥០.២២១)**	**(២.២០៦.៩៣៥)**	**៨២៧.៥១៧**	**៣.៣៦៨.៨២២**

	កំណត់សម្គាល់	ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
		ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
ការទិញមូលបត្រវិនិយោគ		(១៧៥.១២៤)	(៧០២.៤២២)	(៤៤១.៩០១)	(១.៧៩៨.៩៧៩)
សាច់ប្រាក់បានពីការលក់ មូលបត្រវិនិយោគ		៤៤៥.០៦៦	១.៧៨៥.១៦០	៣៨៣.៥២៤	១.៥៦១.៣២៦
ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ		(២៦.៨៩៥)	(១០៧.៨៧៦)	(២៨.៣០៣)	(១១៥.២២២)
ការទិញទ្រព្យសកម្មអរូបី		(៩.៦៩២)	(៣៨.៨៧៥)	(៨.០៥០)	(៣២.៧៧២)
សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ		៧	២៨	២៩	១១៨
ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ		(៤៩០)	(១.៩៦៥)	–	–
សាច់ប្រាក់សុទ្ធ បានពី/(ប្រើប្រាស់) ក្នុងសកម្មភាពវិនិយោគ		**២៣២.៨៧២**	**៩៣៤.០៥០**	**(៩៤.៧០១)**	**(៣៨៥.៥២៩)**
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
ការបោះផ្សាយដើមទុនបន្ថែម		–	–	២២០.០០០	៨៩៥.៦២០
សាច់ប្រាក់បានពីប្រាក់កម្ចី		៩៩១.៨០៩	៣.៩៧៨.១៤៦	១.២១៨.៤១៥	៤.៩៦០.១៦៧
ការទូទាត់សងប្រាក់កម្ចី		(៩២០.៦៤៩)	(៣.៦៩២.៧២៣)	(១.១៨៤.៥៥១)	(៤.៨២២.៣០៧)
ការទូទាត់សងអនុបំណុល		–	–	(៩៦.០០០)	(៣៩០.៨១៦)
ការទូទាត់សងប្រាក់ដើមភតិសន្យា		(១៥.៨៩៥)	(៦៣.៧៥៥)	(១៤.៧៥៥)	(៦០.០៦៨)
សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន		**៥៥.២៦៥**	**២២១.៦៦៨**	**១៤៣.១០៩**	**៥៨២.៥៩៦**
ការ(ថយចុះ) /កើនឡើងសុទ្ធនូវសាច់ប្រាក់ និង សាច់ប្រាក់សមមូល		(២៦២.០៨៤)	(១.០៥១.២១៧)	៨៧៥.៩២៥	៣.៥៦៥.៨៨៩
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ		២.២១១.០៦០	៨.៨៩៩.៥១៧	១.៣៣៥.១៣៥	៥.៤៥៤.០២៥
លម្អៀងពីការប្តូររូបិយប័ណ្ណ		–	(២៧.០៥៩)	–	(១២០.៣៩៧)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ	**២៧**	**១.៩៤៨.៩៧៦**	**៧.៨២១.២៤១**	**២.២១១.០៦០**	**៨.៨៩៩.៥១៧**

ប្រតិបត្តិការមិនមែនសាច់ប្រាក់សំខាន់ៗ

ក្នុងអំឡុងឆ្នាំ២០២៥ មិនមានប្រតិបត្តិការមិនមែនជាសាច់ប្រាក់គួរអោយកត់សម្គាល់នោះទេ។

នៅឆ្នាំ២០២៤ មានការបន្តមូលបត្របំណុលសាជីវកម្មចំនួន ៣០ លានដុល្លារអាមេរិកដែលចេញដោយក្រុមហ៊ុន ខេមបូឌាអ៊ែរផតអិនវេសមិនឯ.ក សម្រាប់ការសាងសង់ និងអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិតេជោ។

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយចាប់ពីទំព័រទី ៥០ ដល់ទី ១២២ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

១. អំពីសម្ព័ន្ធធនាគារ និងធនាគារ

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ហៅកាត់ថា (“ធនាគារ”) បានចុះបញ្ជីនៅកម្ពុជានៅថ្ងៃទី២៥ ខែតុលាឆ្នាំ១៩៩៦ ជាមួយក្រសួងពាណិជ្ជកម្មក្រោមការចុះបញ្ជីលេខ Co. ៣២២/៩៧E (លេខចុះបញ្ជីថ្មី ០០០១០៥៩៣)។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ធនាគារជាតិនៃកម្ពុជា (“NBC”) បានផ្តល់អាជ្ញាប័ណ្ណអចិន្ត្រៃយ៍លេខ ១៤ ដល់ធនាគារ។ ក្រុមហ៊ុនមេ និងក្រុមហ៊ុនមេចុងក្រោយបង្អស់របស់ធនាគារ គឺធនាគារជាតិកាណាដា ដែលជាធនាគារត្រូវបានបង្កើតឡើងក្នុងប្រទេសកាណាដា។

សកម្មភាពចម្បង របស់ធនាគារ គឺផ្តល់សេវាកម្មធនាគារ និងសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធនៅក្នុង ព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរជាសារវន្តទៅលើសកម្មភាពចម្បងរបស់ធនាគារនៅក្នុងការិយបរិច្ឆេទនេះទេ។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅ អគារលេខ១៤១ ១៤៦ ១៤៨ & ១៤៨ អា បេ សេ ដេ & ១៦២ អា មហាវិថីព្រះសីហនុ, ផ្ទះលេខ១៥ & ១៥៣ អា បេ សេ ផ្លូវលេខ២៧៨, ផ្ទះលេខ១៧១ ផ្លូវព្រះត្រសក់ផ្អែម ភូមិ៤ សង្កាត់បឹងកេងកងទី ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុន អេប៊ីអេ ត្រាស ឯ.ក ហៅកាត់ថា (“ក្រុមហ៊ុនបុត្រសម្ព័ន្ធ”) ត្រូវបានបង្កើតឡើងនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៥ ក្រោមការចុះបញ្ជីលេខ ១០០០៤៨៩៩០៧។ ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធមានទីតាំងស្ថិតនៅ អគារលេខ ១៤១ (ជាន់ទី២) មហាវិថីព្រះសីហនុ ភូមិ៤ សង្កាត់បឹងកេងកងទី ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធគឺការទិញ លក់ ជួល និងប្រតិបត្តិការអចលនទ្រព្យដែលក្រុមហ៊ុនកាន់កាប់ដោយខ្លួនឯង ឬជួលពីគេ។

របាយការណ៍ហិរញ្ញវត្ថុរួមរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ (ហៅជារួមថា “សម្ព័ន្ធធនាគារ”) និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ (ហៅជារួមថា”របាយការណ៍ហិរញ្ញវត្ថុ”) ត្រូវបានអនុម័តឲ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦។

២. ព័ត៌មានគោលនយោបាយគណនេយ្យសំខាន់ៗ

២.១. មូលដ្ឋាននៃគណនេយ្យ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា “CIFRSs“)។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយផ្អែកលើ មូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែមានការបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យខាងក្រោម។ សម្រាប់ការប៉ាន់ស្មានលើតម្លៃសមស្រប សូមមើលកំណត់សម្គាល់លេខ ៣១.៦។

២.២. និរន្តរភាពនៃដំណើរការអាជីវកម្ម

នៅពេលអនុម័តរបាយការណ៍ហិរញ្ញវត្ថុ អភិបាលមានការពឹងទុកសមហេតុផលថាសម្ព័ន្ធធនាគារ និងធនាគារមានធនធានគ្រប់គ្រាន់ដើម្បីបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត។ ដូច្នេះ សម្ព័ន្ធធនាគារ និង ធនាគារបានអនុវត្តមូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងដោយឡែក។

២.៣. ស្តង់ដាថ្មី និងស្តង់ដាដែលត្រូវបានធ្វើវិសោធនកម្មដែលមានសុពលភាពនៅក្នុងការិយបរិច្ឆេទនេះ

សម្ព័ន្ធធនាគារ និងធនាគារបានអនុវត្តស្តង់ដាថ្មី និងស្តង់ដាកែសម្រួលទាំងអស់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ធនាគារ។ ការអនុម័តស្តង់ដាថ្មី និងស្តង់ដាកែសម្រួលទាំងនេះ មិនបណ្តាលឲ្យមានការផ្លាស់ប្តូរគោលនយោបាយគណនេយ្យរបស់សម្ព័ន្ធធនាគារ និងធនាគារទេ ហើយពុំមានផលប៉ះពាល់ជាសារវន្តលើការលាតត្រដាង ឬចំនួនទឹកប្រាក់ដែលបានរាយការណ៍សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន ឬការិយបរិច្ឆេទមុនទេ។

ការធ្វើវិសោធនកម្មទៅលើ CIAS ២១ ផលប៉ះពាល់នៃការប្រែប្រួលអត្រាប្តូរប្រាក់ បរទេស ដែលមានចំណងជើង កង្វះខាតនៃការផ្លាស់ប្តូរ	សម្ព័ន្ធធនាគារ និងធនាគារបានអនុវត្តវិសោធនកម្មលើ CIAS ២១លើកទីមួយនាការិយបរិច្ឆេទបច្ចុប្បន្ន។ ការធ្វើវិសោធនកម្មនេះបញ្ជាក់ពីការវាយតម្លៃថារូបិយប័ណ្ណ មួយអាចប្តូររូបិយប័ណ្ណ និងកំណត់អត្រាប្តូរប្រាក់នៅពេលដែលរូបិយប័ណ្ណមិនអាចផ្លាស់ប្តូរបាន។

២.៤. ស្តង់ដាថ្មី និងស្តង់ដាកែសម្រួលដែលបានចេញផ្សាយតែពុំទាន់ចូលជាធរមាន

ស្តង់ដាគណនេយ្យថ្មី និងបានធ្វើវិសោធនកម្មមួយចំនួនត្រូវបានចេញផ្សាយ ដែលមិនទាន់ចូលជាធរមានសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ហើយមិនត្រូវបានអនុវត្តដោយធនាគារមុនកាលកំណត់ទេ។ វិសោធនកម្មទាំងនេះមិនត្រូវបានរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តដល់សម្ព័ន្ធធនាគារ និងធនាគារ នៅក្នុងការិយបរិច្ឆេទបច្ចុប្បន្ន ឬនាពេលអនាគតនោះទេ លើកលែងតែ CIFRS ១៨ ការបង្ហាញ និងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង ការធ្វើវិសោធនកម្មទៅលើ CIFRS ៩ និង CIFRS ៧ ។

CIFRS ១៨ ការបង្ហាញ និង ការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

IFRS ១៨ ការបង្ហាញ និង ការលាតត្រដាង នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបោះពុម្ពផ្សាយដោយក្រុមប្រឹក្សាភិបាលស្តង់ដាគណនេយ្យអន្តរជាតិ (“IASB”) នាថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤។ ស្តង់ដាថ្មីនេះជំនួស IAS ១ ការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុ ខណៈដែលយោងការតម្រូវជាច្រើននៅក្នុង IAS ១ និងណែនាំការតម្រូវថ្មីដូចជា៖

- បង្ហាញប្រភេទដែលបានបញ្ជាក់ និងចំនួនសរុបរងដែលបានកំណត់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត
- ផ្តល់ការលាតត្រដាងអំពីការវាយតម្លៃលើលទ្ធផលដែលកំណត់ដោយគណៈគ្រប់គ្រង នៅក្នុងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
- ធ្វើឲ្យប្រសើរឡើងនូវការប្រមូលផ្តុំ និងការបំបែកព័ត៌មាន។

ស្តង់ដាថ្មីនេះមានប្រសិទ្ធភាពសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី១ ខែមករា ឆ្នាំ២០២៧ ជាមួយនឹងការអនុញ្ញាតឲ្យអនុវត្តជាមុន និងត្រូវអនុវត្តទៅក្រោយ។

អភិបាលរបស់ធនាគារជឿជាក់ថាការអនុវត្តស្តង់ដាថ្មីនេះអាចមានផលប៉ះពាល់ដល់ការបង្ហាញ និងការលាតត្រដាងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការិយបរិច្ឆេទអនាគត។ គណៈគ្រប់គ្រងនឹងវាយតម្លៃផលប៉ះពាល់លម្អិតនៃការអនុវត្តស្តង់ដាថ្មីនេះ ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារមុនកាលបរិច្ឆេទចូលជាធរមាន។

វិសោធនកម្មលើចំណាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ (វិសោធនកម្មទៅលើ CIFRS ៩ និង CIFRS ៧)

នៅក្នុងខែឧសភា ឆ្នាំ២០២៤ IASB បានចេញវិសោធនកម្មលើចំណាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ ដែលបានធ្វើវិសោធនកម្មទៅលើ IFRS៩ និង IFRS៧។ ការតម្រូវទាំងនេះនឹងមានប្រសិទ្ធភាពសម្រាប់ការិយបរិច្ឆេទរាយការណ៍ដែលចាប់ផ្តើមនៅ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ ឬក្រោយនេះ ដោយមានការអនុញ្ញាតឲ្យអនុវត្តមុន ហើយវាទាក់ទងនឹង៖

- ការទូទាត់បំណុលហិរញ្ញវត្ថុដោយប្រើប្រាស់ប្រព័ន្ធទូទាត់តាមអេឡិចត្រូនិក និង
- ការវាយតម្លៃលក្ខណៈលំហូរសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ រួមទាំងទ្រព្យសកម្មដែលមានលក្ខណៈពិសេសភ្ជាប់ជាមួយ នឹងនិរន្តរភាព។

អភិបាលនៃសម្ព័ន្ធធនាគារ និងធនាគារកំពុងស្ថិតក្នុងដំណើរការវាយតម្លៃផលប៉ះពាល់នៃវិសោធនកម្មថ្មីនេះ។

២.៥. រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់ការបង្ហាញ

សម្ព័ន្ធធនាគារ និងធនាគារ ធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួន ផ្អែកលើរូបិយប័ណ្ណចំនួន២ គឺប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក។ គណៈគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោល និងជារូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់សម្ព័ន្ធធនាគារ និងធនាគារព្រោះវាឆ្លុះបញ្ចាំងពីសមាសធាតុសេដ្ឋកិច្ចនៃព្រឹត្តិការណ៍មូលដ្ឋាន និងកាលៈទេសៈរបស់សម្ព័ន្ធធនាគារ និងធនាគារ។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទប្រតិបត្តិការនោះ។ ទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុ នាចុងការិយបរិច្ឆេទ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនោះ។ ធាតុមិនមែនរូបិយវត្ថុ ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របនៅក្នុងរូបិយប័ណ្ណបរទេស ត្រូវបានប្តូរតាមអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទដែលតម្លៃសមស្របត្រូវបានកំណត់។ ធាតុមិនមែនរូបិយវត្ថុ ដែលត្រូវបានវាស់វែងនៅក្នុងលក្ខខណ្ឌថ្លៃដើមប្រវត្តិសាស្ត្រជារូបិយប័ណ្ណបរទេសមិនត្រូវបានប្តូរឡើងវិញទេ។

ភាពលម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

ការបង្ហាញជារូបិយប័ណ្ណប្រាក់រៀល

អនុលោមតាមច្បាប់ស្តីពី គណនេយ្យនិងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ការកត់ត្រាប្តូរពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀលត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយប្រើប្រាស់អត្រាចុងការិយបរិច្ឆេទ និងអត្រាមធ្យមសម្រាប់ការិយបរិច្ឆេទ ដូចដែលបានប្រកាសដោយធនាគារជាតិនៃកម្ពុជា។

ទ្រព្យសកម្ម បំណុល ដើមទុន និងទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗដែលបានបង្ហាញ ត្រូវបានប្តូរតាមអត្រាចុងការិយបរិច្ឆេទនាចុងការិយបរិច្ឆេទនីមួយៗ ដោយឡែកខ្លង់ចំណូល និងចំណាយ នៅក្នុងរបាយការណ៍ ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងខ្លង់នៅក្នុងលំហូរសាច់ប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រាមធ្យមសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ លម្អៀងពីការប្តូររូបិយប័ណ្ណនៃដើមទុន និងទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងធាតុមូលធននោះ រីឯលទ្ធផលនៃភាពលម្អៀងដែលកើតឡើងពីការប្តូររូបិយប័ណ្ណផ្សេងៗទៀត ត្រូវបានកត់ត្រាក្នុងលទ្ធផលលម្អិតផ្សេងៗ (OCI)។

របាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញជាប្រាក់រៀល ត្រូវបានធ្វើឡើងដោយផ្អែកលើអត្រាប្តូរប្រាក់ក្នុងមួយដុល្លារអាមេរិកដូចខាងក្រោម៖

	អត្រាចុងការិយបរិច្ឆេទ	អត្រាមធ្យម
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	៤.០១៣	៤.០១១
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	៤.០២៥	៤.០៧១

ការបង្គត់លេខ

តួលេខនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្គត់ខ្ទង់ពាន់សម្រាប់ចំនួនជាប្រាក់ដុល្លារអាមេរិក និងខ្ទង់លានសម្រាប់ចំនួនជាប្រាក់រៀល។

២.៦. មូលដ្ឋាននៃការរួមបញ្ចូលគ្នា

របាយការណ៍ហិរញ្ញវត្ថុរួម រួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានរៀបចំសម្រាប់ការិយបរិច្ឆេទបញ្ចប់នីមួយៗ។ ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាក្រុមហ៊ុនដែលសម្ព័ន្ធធនាគារមានសិទ្ធអំណាចក្នុងការអនុវត្តការគ្រប់គ្រងលើហិរញ្ញវត្ថុ និងគោលនយោបាយប្រតិបត្តិការជំនួញដើម្បីទទួលបានផលប្រយោជន៍ពីសកម្មភាពអាជីវកម្ម។

ការគ្រប់គ្រងកើតឡើងនៅពេលសម្ព័ន្ធធនាគារ៖

- មានអំណាចលើក្រុមហ៊ុនដែលបានវិនិយោគ
- ប្រឈម ឬមានសិទ្ធិលើប្រាក់ចំណេញបានពីការចូលរួមជាមួយក្រុមហ៊ុនដែលបានវិនិយោគ និង
- មានលទ្ធភាពក្នុងការប្រើប្រាស់អំណាចលើការចាត់ចែងប្រាក់ចំណេញ។

សម្ព័ន្ធធនាគារធ្វើការវិភាគឡើងវិញថាតើខ្លួននៅតែមានការគ្រប់គ្រងលើក្រុមហ៊ុនវិនិយោគ ឬទេប្រសិនបើភាពជាក់ស្តែង និងកាលៈទេសៈចង្អុលបង្ហាញថាមានការផ្លាស់ប្តូរកត្តាមួយ ឬច្រើន នៃសមាសធាតុនៃការគ្រប់គ្រងទាំងបី ដូចបានរៀបរាប់ខាងលើ។

នៅពេលសម្ព័ន្ធធនាគារមានសម្លេងតិចជាងភាគច្រើន នៃសិទ្ធបោះឆ្នោតលើក្រុមហ៊ុនវិនិយោគសម្ព័ន្ធធនាគារ ពិចារណាថាតើសម្ព័ន្ធធនាគារមានសិទ្ធអំណាចលើក្រុមហ៊ុនវិនិយោគ នៅពេលសិទ្ធិបោះឆ្នោតគឺ មានភាពគ្រប់គ្រាន់ក្នុងការផ្តល់ឱ្យសម្ព័ន្ធធនាគារ នូវលទ្ធភាព ក្នុងការដឹកនាំសកម្មភាពពាក់ព័ន្ធរបស់ក្រុមហ៊ុនវិនិយោគ។ សម្ព័ន្ធធនាគារពិចារណាភាពជាក់ស្តែង និងកាលៈទេសៈពាក់ព័ន្ធ ក្នុងការវិភាគថាតើសិទ្ធិបោះឆ្នោតរបស់ខ្លួនទៅលើក្រុមហ៊ុនវិនិយោគ គឺគ្រប់គ្រាន់ក្នុងការផ្តល់សិទ្ធអំណាចដល់ខ្លួន ដោយផ្អែកលើកត្តាខាងក្រោម៖

- ទំហំនៃសិទ្ធិបោះឆ្នោតដែលកាន់កាប់ដោយសម្ព័ន្ធធនាគារ ដែលពាក់ព័ន្ធទៅនឹងទំហំ និងការបែងចែកនៃសិទ្ធិកាន់កាប់របស់អ្នកមានសិទ្ធិបោះឆ្នោតដទៃទៀត
- សក្តានុពលនៃសិទ្ធិបោះឆ្នោតកាន់កាប់ដោយសម្ព័ន្ធធនាគារ អ្នកមានសិទ្ធិបោះឆ្នោត និងភាគីដទៃទៀត
- សិទ្ធបានមកពីការរៀបចំដោយកិច្ចសន្យាដទៃទៀត និង
- ភាពជាក់ស្តែង និងកាលៈទេសៈបន្ថែមណាមួយ ដែលបញ្ជាក់ថាសម្ព័ន្ធធនាគារមាន ឬមិនមានលទ្ធភាពក្នុងការដឹកនាំសកម្មភាពពាក់ព័ន្ធ នៅពេលដែលតម្រូវឱ្យមានការសម្រេចចិត្តរួមបញ្ចូលទាំងសិទ្ធក្នុងការបោះឆ្នោតក្នុងការប្រជុំភាទុនិកពីមុន។

ការរួមបញ្ចូលក្រុមហ៊ុនបុត្រសម្ព័ន្ធចាប់ផ្តើម នៅពេលសម្ព័ន្ធធនាគារទទួលបានការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធ ហើយបញ្ចប់នៅពេលសម្ព័ន្ធធនាគារបាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធ។ ជាពិសេសលទ្ធផលនៃការទិញ ឬលក់ក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងអំឡុងឆ្នាំ ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍ចំណេញឬខាត និងលទ្ធផលលម្អិតផ្សេងៗ ចាប់ពីថ្ងៃដែលសម្ព័ន្ធធនាគារទទួលបានការគ្រប់គ្រង រហូតដល់កាលបរិច្ឆេទដែលសម្ព័ន្ធធនាគារបញ្ឈប់ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ។

ក្នុងករណីចាំបាច់ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានធ្វើនិយ័តកម្មឱ្យស្របទៅតាមគោលនយោបាយគណនេយ្យរបស់សម្ព័ន្ធធនាគារ។

រាល់អន្តរក្រុមហ៊ុនជាទ្រព្យសកម្ម និង បំណុល មូលធន ចំណូល ចំណាយ និងលំហូរសាច់ប្រាក់ដែលទាក់ទងនឹងប្រតិបត្តិការរវាងសមាជិករបស់សម្ព័ន្ធធនាគារត្រូវបានលុបបំបាត់ពេលរួមបញ្ចូល។

នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ធនាគារ ការវិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានវាស់វែងតាមថ្លៃដើម ដកឱនភាពតម្លៃបង្គរប្រសិនបើមាន។

២.៧. ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នៅពេលដែលសម្ព័ន្ធធនាគារ និងធនាគារក្លាយជាភាគីនៃបទប្បញ្ញត្តិកិច្ចសន្យានៃឧបករណ៍ទាំងនេះ។ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប។ ថ្លៃដើមប្រតិបត្តិការដែលកំណត់ថាពាក់ព័ន្ធនឹងការទិញ ឬការចេញផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូល ឬដកចេញពីតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ នៅលើការទទួលស្គាល់ដំបូង។ ថ្លៃប្រតិបត្តិការពាក់ព័ន្ធនឹងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុក្នុងតម្លៃសមស្រប តាមរយៈការចំណេញឬខាត ត្រូវបានទទួលស្គាល់ភ្លាមៗ នៅក្នុងចំណេញ ឬខាត។

ទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ ត្រូវបានទទួលស្គាល់ និង លែងទទួលស្គាល់នៅកាលបរិច្ឆេទនៃការធ្វើជួញដូរ ដែលការទិញ ឬលក់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺស្ថិតនៅក្រោមកិច្ចសន្យា ដែលលក្ខខណ្ឌតម្រូវឲ្យមានការផ្តល់ជូនទ្រព្យសកម្មក្នុងរយៈពេលកំណត់ ដែលបានបង្កើតឡើងដោយទីផ្សារដែលពាក់ព័ន្ធ ហើយត្រូវបានវាស់វែងតាមតម្លៃសមស្របរួមទាំងថ្លៃដើមប្រតិបត្តិការ។ ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ត្រូវបានបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគឺគិតទាំងចំនួនដែលត្រូវទទួលបាន និងការប្រាក់ដែលត្រូវទទួលបាន។

ការចាត់ថ្នាក់ និងការវាស់វែងជាបន្តបន្ទាប់

ទ្រព្យសកម្មហិរញ្ញវត្ថុមួយ ត្រូវបានវាស់វែងតាមតម្លៃដករំលស់ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុនោះ បំពេញលក្ខខណ្ឌទាំងពីរដូចខាងក្រោម៖

- ទ្រព្យសកម្មដែលមាននៅក្នុងម៉ូដែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកសម្រាប់ការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (ហៅកាត់ថា “SPPI”) តាមចំនួនប្រាក់ដើមដែលនៅជំពាក់តែប៉ុណ្ណោះ។

ឧបករណ៍បំណុលដែលបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ត្រូវបានវាស់វែងជាបន្តបន្ទាប់ដោយតម្លៃសមស្របតាមរយៈប្រាក់ចំណូលលម្អិតផ្សេងៗទៀត (ហៅកាត់ថា“FVTOCI”) ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងម៉ូដែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកសម្រាប់ការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុផ្តល់នូវកាលបរិច្ឆេទជាក់លាក់ ចំពោះលំហូរសាច់ប្រាក់ ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ តាមចំនួនប្រាក់ដើមដែលនៅសល់តែប៉ុណ្ណោះ។

ជាទូទៅទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗទៀត ត្រូវបានវាស់វែងជាបន្តបន្ទាប់ដោយតម្លៃសមស្របតាមរយៈចំណេញឬខាត (ហៅកាត់ថា“FVTPL”)។

តម្លៃដករំលស់ និងវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព

វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពគឺជាវិធីសាស្ត្រគណនាតម្លៃដករំលស់នៃបំណុលហិរញ្ញវត្ថុ និងការបែងចែកចំណូលការប្រាក់ក្នុងកំឡុងពេលដែលពាក់ព័ន្ធ។

សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុក្រៅពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានទិញ ឬជាឥណទានមានឱនភាពនៃតម្លៃដើម ការប្រាក់ប្រសិទ្ធភាពគឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងត្រូវទទួល (រួមទាំងថ្លៃសេវាទាំងអស់ និងការបង់សង ឬទទួលបាន ដែលបង្កើតបានជាផ្នែកសំខាន់មួយនៃអត្រាការប្រាក់ប្រសិទ្ធភាព ថ្លៃប្រតិបត្តិការ និងបុព្វលាភ ឬតម្លៃអប្បហារផ្សេងទៀត) ដោយមិនរាប់បញ្ចូលសំវិធានធនការខាតបង់ឥណទានរំពឹងទុក ក្នុងអាយុកាលរំពឹងទុកនៃឧបករណ៍បំណុល ឬនៅពេលដែលសមស្រប រយៈពេលខ្លីជាងនេះ ទៅតាមទំហំតម្លៃយោងដុលនៃឧបករណ៍បំណុល សម្រាប់ការទទួលស្គាល់បំណុលលើកដំបូង។

តម្លៃដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងនៅពេលដែលទទួលស្គាល់លើកដំបូង ដកនឹងការសងប្រាក់ដើម បូកនឹងរំលស់បង្គរដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ទទួលស្គាល់ដំបូង និងចំនួនឥណប្រតិទាន ដោយកែតម្រូវសំវិធានធនខាតបង់ឥណទានរំពឹងទុកណាមួយ។ តម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាតម្លៃដករំលស់នៃ ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលកែប្រែសំវិធានធនខាតបង់ឥណទានរំពឹងទុកណាមួយ។

ចំណូលការប្រាក់គឺត្រូវបានទទួលស្គាល់ដោយប្រើប្រាស់វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព សម្រាប់ ឧបករណ៍វាស់វែងបំណុលជាបន្តបន្ទាប់តាមតម្លៃដករំលស់ និង FVTOCI។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុក្រៅពីការទិញ ឬមានប្រភពពីទ្រព្យសកម្មហិរញ្ញវត្ថុដែលជាឥណទានមានឱនភាព ចំណូលការប្រាក់ត្រូវបានគណនាដោយអនុវត្តតាមអត្រាការប្រាក់ប្រសិទ្ធភាព ទៅលើតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុដែលក្លាយជាឥណទានមានឱនភាពជាបន្តបន្ទាប់តែប៉ុណ្ណោះ។ ចំណូលការប្រាក់សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃឥណទាននៅក្នុងការិយបរិច្ឆេទជាបន្តបន្ទាប់ ត្រូវបានកត់ត្រាដោយការអនុវត្តអត្រាការប្រាក់ប្រសិទ្ធភាពលើតម្លៃដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើហានិភ័យនៃឥណទានលើឧបករណ៍ហិរញ្ញវត្ថុដែលមានឱនភាពមានភាពប្រសើរឡើងនៅក្នុងការិយបរិច្ឆេទជាបន្តបន្ទាប់នាំឲ្យទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពឥណទាន ដូច្នេះចំណូលការប្រាក់ត្រូវបានកត់ត្រាដោយការអនុវត្តអត្រាការប្រាក់ប្រសិទ្ធភាពលើតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

ឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់សំវិធានធនលើការខាតបង់សម្រាប់ ការខាតបង់ឥណទានរំពឹងទុក (ហៅកាត់ថា “ECL”) លើឧបករណ៍ហិរញ្ញវត្ថុដូចខាងក្រោម៖

- សមតុល្យនៅធនាគារនានា
- ឥណទានផ្តល់ដល់អតិថិជន
- មូលបត្រវិនិយោគបំណុល
- ប្រាក់កក់និងគណនីត្រូវទទួលផ្សេងៗ
- កិច្ចសន្យាឥណទាន នឹង
- កិច្ចសន្យាធានាហិរញ្ញវត្ថុ។

មិនមានឱនភាពត្រូវបានទទួលស្គាល់លើការវិនិយោគមូលធនឡើយ។

សំវិធានធនលើការខាតបង់រំពឹងទុកសម្រាប់ ពេញមួយអាយុកាលនៃ ECL គឺ ចាំបាច់សម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ប្រសិនបើហានិភ័យឥណទាន លើឧបករណ៍ហិរញ្ញវត្ថុនោះមានការកើនឡើងគួរឲ្យកត់សម្គាល់ ចាប់តាំងពីការទទួលស្គាល់ដំបូង។ ចំពោះឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ECLs ត្រូវបានវាស់វែងតាមចំនួនស្មើនឹង ECL ១២ខែ។ ព័ត៌មានលម្អិតបន្ថែមស្តីពីការកំណត់ នៃការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទានត្រូវបានផ្តល់ជូននៅក្នុងកំណត់សម្គាល់ ៣១.១។

ECLs គឺជាការប៉ាន់ស្មានដោយផ្អែកលើប្រូបាប៊ីលីតេមធ្យមនៃតម្លៃបច្ចុប្បន្ននៃការខាតបង់ឥណទាន។ វាត្រូវបានវាស់វែងជាតម្លៃបច្ចុប្បន្ន នៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលជំពាក់មកសម្ព័ន្ធធនាគារ និងធនាគារតាមកិច្ចសន្យានិងលំហូរសាច់ប្រាក់ដែលសម្ព័ន្ធធនាគារ និងធនាគារំពឹងថានឹងទទួលបានពីការថ្លឹងថ្លែងពីសេណារីយ៉ូសេដ្ឋកិច្ចនាពេលអនាគតដែលត្រូវបានធ្វើអប្បហារដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព (ហៅកាត់ថា “EIR”) របស់ទ្រព្យសកម្មនោះ។

- សម្រាប់កិច្ចសន្យាឥណទានដែលពុំទាន់បានប្រើប្រាស់ ECL គឺជាភាពខុសគ្នារវាងតម្លៃបច្ចុប្បន្ន នៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលសម្ព័ន្ធធនាគារ និងធនាគារត្រូវទទួលបាន ប្រសិនបើអ្នកកាន់កិច្ចសន្យា ដកប្រាក់ឥណទាន និង លំហូរសាច់ប្រាក់ដែលសម្ព័ន្ធធនាគារ និងធនាគារំពឹងថានឹងទទួលបាន ប្រសិនបើឥណទានត្រូវបានប្រើប្រាស់ និង
- សម្រាប់កិច្ចសន្យាធានាហិរញ្ញវត្ថុ ECL គឺជាភាពខុសគ្នារវាង ការទូទាត់ដែលរំពឹងទុកសម្រាប់សងទៅអ្នកកាន់ឧបករណ៍បំណុល ដែលបានធានាដោយដកចេញនូវចំនួនទឹកប្រាក់ដែលសម្ព័ន្ធធនាគារ និងធនាគារំពឹងថានឹងទទួលបានពីអ្នកកាន់បំណុល កូនបំណុល ឬភាគីផ្សេងទៀត។

សម្ព័ន្ធធនាគារ និងធនាគារវាស់វែង ECL ផ្អែកលើមូលដ្ឋានជាក្រុមសម្រាប់សំណៀតឥណទានដែលមានលក្ខណៈហានិភ័យសេដ្ឋកិច្ចស្រដៀងគ្នា។ ការវាស់វែងនៃការខាតបង់ គឺផ្អែកលើតម្លៃបច្ចុប្បន្ន នៃលំហូរសាច់ប្រាក់ដែលរំពឹងទុករបស់ទ្រព្យសកម្ម ដោយប្រើ EIR ដើមរបស់ទ្រព្យសកម្ម។

ព័ត៌មានបន្ថែមស្តីពីការវាស់វែងនៃ ECL ត្រូវបានផ្តល់ជូននៅក្នុងកំណត់សម្គាល់ ៣១.១ រួមទាំងព័ត៌មានលម្អិតអំពីរបៀបដែលឧបករណ៍ត្រូវបានដាក់ជាក្រុម នៅពេលវាយតម្លៃលើមូលដ្ឋានជាក្រុម។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទាន

ទ្រព្យសកម្មហិរញ្ញវត្ថុ គឺមាន "ឱនភាពឥណទាន" នៅពេលមានព្រឹត្តិការណ៍មួយឬច្រើន ដែលមានផលប៉ះពាល់យ៉ាងខ្លាំង លើលំហូរសាច់ប្រាក់ហិរញ្ញវត្ថុដែលរំពឹងទុកនាពេលអនាគត របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពឥណទានសំដៅទៅលើ ទ្រព្យសកម្មដំណាក់កាលទី៣។ ព័ត៌មានលម្អិតបន្ថែមស្តីពីភស្តុតាងប្រើសម្រាប់ការប្រើប្រាស់ការកំណត់សម្គាល់នូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានឱនភាពឥណទានត្រូវបានផ្តល់ជូននៅក្នុងកំណត់សម្គាល់ ៣១.១.២(ក)។

វាប្រហែលជាមិនអាចកំណត់យកព្រឹត្តិការណ៍ដាច់ពីគ្នាតែមួយបានទេ ផ្ទុយទៅវិញ លទ្ធផលនៃការរួមគ្នារបស់ព្រឹត្តិការណ៍មួយចំនួនអាចបណ្តាលឲ្យ ទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពឥណទាន។ សម្ព័ន្ធធនាគារ និងធនាគារត្រូវវាយតម្លៃថាតើឧបករណ៍បំណុល ដែលជាទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាស់ដោយតម្លៃដកវិលស់គឺមានឱនភាពឥណទាននៅចុងការិយបរិច្ឆេទនីមួយៗដែរទេ។ សម្ព័ន្ធធនាគារ និងធនាគារត្រូវពិចារណាលើកត្តាមួយចំនួនដូចជា ទិន្នផលសញ្ញាប័ណ្ណ ការវាយតម្លៃចំណាត់ថ្នាក់ឥណទាន និងសមត្ថភាពរបស់អ្នកខ្ចីក្នុងការប្រមូលទុន ដើម្បីវាយតម្លៃថាតើឧបករណ៍បំណុលរដ្ឋនិងបំណុលសាជីវកម្មមានការខាតបង់ឥណទាន។

ឥណទានមួយត្រូវបានចាត់ទុកថាមានការខាតបង់ឥណទាន នៅពេលដែល ការអនុគ្រោះ ត្រូវបានផ្តល់ទៅឲ្យអ្នកខ្ចីដោយសារតែភាពយ៉ាប់យ៉ឺននៃស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី លើកលែងតែមានភស្តុតាងបង្ហាញថា ជាលទ្ធផលនៃការ ផ្តល់ការអនុគ្រោះ ហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យា បានថយចុះគួរឲ្យកត់សម្គាល់ និងមិនមានសូចនាករផ្សេងទៀតនៃឱនភាពតម្លៃ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលការអនុគ្រោះត្រូវបានពិចារណា ប៉ុន្តែមិនបានផ្តល់ ទ្រព្យសកម្មនោះត្រូវបានគេចាត់ទុកថាមានការខាតបង់ឥណទាន នៅពេលមានភស្តុតាងដែលអាចបង្ហាញពីការខាតបង់ឥណទាន រួមទាំងការបំពេញនិយមន័យនៃការខកខានសង។ សូមមើលខាងក្រោមសម្រាប់និយមន័យនៃការខកខានសង។

និយមន័យនៃការខកខានសង

ភាពសំខាន់ចំពោះការកំណត់ ECL គឺនិយមន័យនៃការខកខានសង។ និយមន័យនៃការខកខានសងត្រូវបានប្រើក្នុងការវាស់តម្លៃរបស់ ECL និងក្នុងការកំណត់ថាតើ ការខាតបង់អាស្រ័យលើអាយុកាល ១២ ខែ ឬពេញមួយអាយុកាល ECL ដោយសារការខកខានសងគឺជាសមាសធាតុមួយ របស់ប្រូបាប៊ីលីតេនៃការខកខានសង (ហៅកាត់ថា “PD”) ដែលមានការប៉ះពាល់ ក្នុងការវាស់វែង ECL និង ការកំណត់នៃការកើនឡើងហានិភ័យឥណទានជាសារវន្ត។

សម្ព័ន្ធធនាគារ និងធនាគារចាត់ទុកព្រឹត្តិការណ៍ដូចខាងក្រោមនេះជាព្រឹត្តិការណ៍ដែលធ្វើឲ្យមានការខកខានសង៖

- អ្នកខ្ចីត្រូវបានវាយតម្លៃហានិភ័យឥណទានផ្ទៃក្នុងថ្នាក់ “១០” ឬហួសកាលកំណត់សងលើសពី ៨៩ ថ្ងៃ សម្រាប់ឥណទានរយៈពេលវែង និងលើសពី ៣០ ថ្ងៃ សម្រាប់ឥណទានរយៈពេលខ្លី ឬ
- អ្នកខ្ចីទំនងជាមិនបំពេញកាតព្វកិច្ចឥណទានរបស់ខ្លួនដល់សម្ព័ន្ធធនាគារ និងធនាគារ។

និយមន័យនៃការខកខានសងនេះ ត្រូវបានប្រើប្រាស់ដោយសម្ព័ន្ធធនាគារ និងធនាគារ សម្រាប់គោលបំណងគណនេយ្យ ក៏ដូចជាសម្រាប់គោលបំណងគ្រប់គ្រងហានិភ័យឥណទានផ្ទៃក្នុង និងគោរពតាមនិយមន័យបទប្បញ្ញត្តិនៃការខកខានសង។

ប្រសិនបើអ្នកខ្ចីមិនទំនងនឹងអាចបំពេញកាតព្វកិច្ចឥណទានរបស់ខ្លួន សម្ព័ន្ធធនាគារ និងធនាគារត្រូវគិតគូរទាំងសូចនាករគុណភាព និងបរិមាណនៅពេលវាយតម្លៃ។ ព័ត៌មានដែលបានវាយតម្លៃគឺអាស្រ័យលើប្រភេទនៃទ្រព្យសកម្ម ឧទាហរណ៍ សូចនាករគុណភាពដែលត្រូវបានប្រើក្នុងការផ្តល់ប្រាក់កម្ចីដល់ធនាគារ ដូចជាការបំពានលើកិច្ចព្រមព្រៀង ដែលមិនអាចប្រើសម្រាប់វាយតម្លៃលើការផ្តល់ប្រាក់កម្ចីឲ្យបុគ្គលឡើយ។ សូចនាករបរិមាណ ដូចជាភាពយឺតយ៉ាវ និងការមិនបង់ប្រាក់លើកាតព្វកិច្ចនៃគូភាគី គឺជាធាតុចូលសំខាន់នៅក្នុងការវិភាគនេះ។ សម្ព័ន្ធធនាគារ និងធនាគារបានប្រើប្រាស់ប្រភពព័ត៌មានជាច្រើនដើម្បីវាយតម្លៃពីការខកខានសង ដែលព័ត៌មានទាំងនោះត្រូវបានបង្កើតឡើង នៅប្រភពខាងក្នុង ឬប្រមូលបានពីប្រភពខាងក្រៅ។ ព័ត៌មានលម្អិតបន្ថែម បានផ្តល់ជូននៅក្នុងកំណត់សម្គាល់ ៣១.១។ ការខកខានសងគឺជាភស្តុតាងដែលបង្ហាញថាទ្រព្យសកម្មមានឱនភាពឥណទាន ដូចដែលបានកត់សម្គាល់នៅក្នុងនិយមន័យនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទាន។ ដូច្នេះឱនភាពឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុ គឺរួមបញ្ចូលនូវទ្រព្យសកម្មដែលខកខានសង និងទ្រព្យសកម្មដែលមិនមានការខកខានសងផ្សេងៗទៀត ដោយសារតែនិយមន័យនៃឱនភាពឥណទានមានលក្ខណៈទូលំទូលាយជាងនិយមន័យនៃការខកខានសង។

ការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន

សម្ព័ន្ធធនាគារ និងធនាគារត្រូវត្រួតពិនិត្យរាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ ដែលតម្រូវឲ្យធ្វើការវាយតម្លៃលើឱនភាពឥណទាន ថាតើមានហានិភ័យឥណទានកើនឡើងជាសារវន្តចាប់តាំងពីមានការទទួលស្គាល់ដំបូងដែរឬទេ។ សម្ព័ន្ធធនាគារ និងធនាគារនឹងធ្វើការវាស់វែងលើសំវិធានធនលើការខាតបង់ដោយផ្អែកលើ ECL ពេញមួយអាយុកាល ជាជាង ECL រយៈពេល ១២ខែ ប្រសិនបើមានការកើនឡើងជាសារវន្តនៃហានិភ័យឥណទាន។

សម្ព័ន្ធធនាគារ និងធនាគារត្រូវប្រៀបធៀបរវាងហានិភ័យនៃការខកខានសង ដែលកើតឡើងលើឧបករណ៍ហិរញ្ញវត្ថុ នាចុងការិយបរិច្ឆេទ ផ្អែកលើអាយុកាលដែលនៅសល់របស់ឧបករណ៍ហិរញ្ញវត្ថុ ជាមួយនឹងហានិភ័យនៃការខកខានដែលបានរំពឹងទុកសម្រាប់អាយុកាលដែលនៅសល់នាចុងការិយបរិច្ឆេទបច្ចុប្បន្ននាពេលដែលឧបករណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ដំបូង ដើម្បីវាយតម្លៃថាហានិភ័យឥណទាននៅលើ ឧបករណ៍ហិរញ្ញវត្ថុមានការកើនឡើងគួរឲ្យកត់សម្គាល់ចាប់តាំងពីការទទួលស្គាល់ដំបូងដែរឬទេ។ ដើម្បីធ្វើការវាយតម្លៃនេះសម្ព័ន្ធធនាគារ និងធនាគារត្រូវពិចារណាទាំងបរិមាណនិងគុណភាពនៃព័ត៌មាន ដែលសមហេតុផល និងអាចគាំទ្របាន រួមទាំងបទពិសោធន៍ពីមុន និងព័ត៌មានព្យាករណ៍នាពេលអនាគតដែលអាចរកបាន ដោយមិនចាំបាច់ចំណាយ ឬប្រឹងប្រែងហួសហេតុ ដោយផ្អែកលើបទពិសោធន៍ពីមុនរបស់សម្ព័ន្ធធនាគារ និងធនាគារ និងជំនាញក្នុងការវាយតម្លៃឥណទាន រួមទាំងព័ត៌មានព្យាករណ៍នាពេលអនាគត។

ព័ត៌មានព្យាករណ៍នាពេលអនាគត រួមមានការរំពឹងទុកនាពេលអនាគតនៃវិស័យដែលសមភាគីរបស់សម្ព័ន្ធធនាគារ និងធនាគារធ្វើប្រតិបត្តិការដែលទទួលបានពីមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងអង្គការស្រដៀងគ្នាផ្សេងទៀត ហើយក៏អាចពិចារណាក្នុងការប្រើប្រាស់ព័ត៌មានសេដ្ឋកិច្ចជាក់ស្តែងនិងការព្យាករណ៍ផ្ទៃក្នុង និងប្រភពខាងក្រៅផ្សេងៗផងដែរ។ សម្ព័ន្ធធនាគារ និងធនាគារបែងចែកសមភាគីរបស់ខ្លួនទៅតាមថ្នាក់ហានិភ័យឥណទាន អាស្រ័យលើគុណភាពឥណទានរបស់ពួកគេ។ ព័ត៌មានជាបរិមាណ គឺជាសូចនាករចម្បងមួយ ដែលបញ្ជាក់អំពីការកើនឡើងគួរឲ្យកត់សម្គាល់នៃហានិភ័យឥណទាន។

PDs ដែលបានប្រើមានរួមបញ្ចូលលក្ខខណ្ឌព្យាករណ៍នាពេលអនាគតហើយសម្ព័ន្ធធនាគារ និងធនាគារប្រើប្រាស់វិធីសាស្ត្រ និងទិន្នន័យដូចគ្នាទៅនឹងការគណនាការខាតបង់រំពឹងទុកលើទ្រព្យសកម្មហិរញ្ញវត្ថុ ECL (សូមមើលកំណត់សម្គាល់ ៣១.១)។

រាល់ការផ្លាស់ប្តូរក្នុងលក្ខខណ្ឌជាក់លាក់ណាមួយទៅលើ PD នឹងធ្វើឲ្យមានការផ្លាស់ប្តូរខ្លាំងទៅលើឧបករណ៍ហិរញ្ញវត្ថុដែលមាន PD ទាបតាំងពីពេលទទួលស្គាល់ដំបូង ជាងឧបករណ៍ហិរញ្ញវត្ថុដែលមាន PD ខ្ពស់ពីដំបូង ដោយសារតែការកើនឡើងជាសារវន្តនូវហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង។

ព័ត៌មានបន្ថែមអំពីការកើនឡើងហានិភ័យឥណទានត្រូវបានផ្តល់ជូននៅក្នុងកំណត់សម្គាល់៣១.១។

ការកែប្រែ និង ការលែងទទួលស្គាល់នៃទ្រព្យសកម្មហិរញ្ញវត្ថុ

ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ កើតឡើងនៅពេលដែលលក្ខខណ្ឌកុងត្រាទាក់ទងនឹងលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើការចរចាឡើងវិញ ឬផ្លាស់ប្តូរជាថ្មី រវាងការទទួលស្គាល់លើកដំបូង និងកាលកំណត់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ការកែប្រែ មានផលប៉ះពាល់ទៅលើចំនួនទឹកប្រាក់ ឬ ពេលវេលានៃលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាភ្លាមៗ ឬនាពេលអនាគត។ លើសពីនេះទៅទៀត ការណែនាំ ឬការកែប្រែលក្ខខណ្ឌនៃកិច្ចសន្យាឥណទានដែលមានស្រាប់ អាចធ្វើឲ្យមានការកែប្រែ ទោះបីជាកិច្ចសន្យាថ្មី ឬការកែប្រែលក្ខខណ្ឌទាំងនេះមិនទាន់មានផលប៉ះពាល់ដល់លំហូរសាច់ប្រាក់ភ្លាមៗក៏ដោយ ប៉ុន្តែវាអាចមានផលប៉ះពាល់ដល់លំហូរសាច់ប្រាក់អាស្រ័យលើថាតើលក្ខខណ្ឌនៃកិច្ចសន្យា ត្រូវបានបំពេញឬមិនបានបំពេញតាមលក្ខខណ្ឌ (ឧទាហរណ៍ ការផ្លាស់ប្តូរលើការកើនឡើងនៃអត្រាការប្រាក់ដែលកើតឡើងនៅពេលដែលមានការបំពានលើលក្ខខណ្ឌកំហិតនៃកិច្ចសន្យា)។

សម្ព័ន្ធធនាគារ និងធនាគារបានធ្វើការចរចាឡើងវិញនូវឥណទានផ្តល់ដល់អតិថិជនដែលមានផលលំបាកផ្នែកហិរញ្ញវត្ថុ ដើម្បីទទួលបានការប្រមូលត្រលប់មកវិញជាអតិបរមា និងកាត់បន្ថយហានិភ័យនៃការខកខានសង។ ឥណទានរៀបចំឡើងវិញត្រូវបានផ្តល់ជូន ក្នុងករណីដែលអ្នកខ្ចីពិតជាបានខិតខំប្រឹងប្រែងទូទាត់បំណុលទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាដើម ប៉ុន្តែវាមានហានិភ័យខ្ពស់ដែលការខកខានសងនឹងត្រូវកើនឡើង ឬការខកខានសងបានកើតឡើងហើយ ដោយរំពឹងថាអ្នកខ្ចីនឹងអាចបំពេញតាមលក្ខខណ្ឌដែលបានកែប្រែ។ លក្ខខណ្ឌដែលបានកែប្រែ ជាធម្មតារួមមានការពន្យារពេលកំណត់ ការផ្លាស់ប្តូរយៈពេលនៃលំហូរសាច់ប្រាក់របស់ឥណទាន (ការទូទាត់សងប្រាក់ដើម និងការប្រាក់) ការកាត់បន្ថយចំនួនលំហូរសាច់ប្រាក់ដែលត្រូវបង់ (ការលើកលែងប្រាក់ដើម និងការប្រាក់) និងការកែប្រែលក្ខខណ្ឌនៃកិច្ចសន្យា។

នៅពេលដែលលក្ខខណ្ឌ នៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានកែប្រែ ហើយការកែប្រែនេះមិនបណ្តាលឲ្យមានការលែងទទួលស្គាល់ សម្ព័ន្ធធនាគារ និងធនាគារនឹងគណនាឡើងវិញតម្លៃយោងដុលដោយផ្អែកទៅលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ និងទទួលស្គាល់ចំណេញ ឬខាតលើការកែប្រែនេះនៅក្នុងរបាយការណ៍ចំណេញ ឬខាត។

ការកំណត់ហានិភ័យឥណទានរបស់ទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់ដំបូងឆ្លុះបញ្ចាំងពីការប្រៀបធៀបនៃ៖

- អាយុកាលដែលនៅសល់របស់ PD ផ្អែកលើទិន្នន័យនៅពេលមានការទទួលស្គាល់ដំបូង និងលក្ខខណ្ឌកិច្ចសន្យាដើមជាមួយនឹង
- អាយុកាលដែលនៅសល់របស់ PD នៅចុងការិយបរិច្ឆេទដោយផ្អែកលើលក្ខខណ្ឌដែលបានកែប្រែ។

ការប៉ាន់ស្មាននៃ PD បង្ហាញពីលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារដើម្បីប្រមូលប្រាក់ចំណូលពីការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ យោងតាមបទពិសោធន៍កន្លងមករបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការអនុវត្តន៍ឥណទានរៀបចំឡើងវិញ ហើយក៏មានសូចនាករណ៍ផ្សេងៗដែលរួមមាន លទ្ធភាពទូទាត់ប្រាក់របស់អ្នកខ្ចីចំពោះលក្ខខណ្ឌកិច្ចសន្យាដែលបានផ្លាស់ប្តូរ ដោយគោលការណ៍នេះមិនបណ្តាលឲ្យមានការឈប់ទទួលស្គាល់ការប៉ាន់ស្មាន PDនោះទេ។ ប្រសិនបើហានិភ័យឥណទាននៅតែកើនឡើងជាសារវន្ត ប្រៀបជាមួយនឹងការប៉ាន់ស្មានសំវិធានធនលើការខាតបង់ដែលទទួលស្គាល់ដំបូង នោះ ECL នឹងវាស់វែងស្មើនឹងមួយអាយុកាល។ សម្ព័ន្ធធនាគារ និងធនាគារបន្តអនុវត្តការវាយតម្លៃដើម្បីបញ្ជាក់ថា បញ្ហានៃការខូចខាតត្រូវបានដោះស្រាយ ដើម្បីកំណត់ថាឥណទានលែងមានការខូចខាតប្រសិនបើមិនមានឱនភាពឥណទាន។ សំវិធានធនលើការខាតបង់ឥណទានជាទូទៅនឹងត្រូវបានវាស់វែងដោយផ្អែកលើ ECL ១២ ខែ នៅពេលមានភស្តុតាងនៃភាពប្រសើរឡើងក្នុងការទូទាត់សងរបស់អ្នកខ្ចី បន្ទាប់ពីមានការកែប្រែដែលនាំឲ្យមានការផ្លាស់ប្តូរបញ្ហាសនៃហានិភ័យឥណទានដែលកើនឡើងជាសារវន្តពីមុន។

សម្ព័ន្ធធនាគារ និងធនាគារលែងទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិតាមកិច្ចសន្យាលើលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុនោះផុតកំណត់ (រាប់បញ្ចូលទាំងការផុតកំណត់ដែលកើតឡើងពីការកែប្រែដោយមានលក្ខខណ្ឌខុសគ្នាជាសារវន្ត) ឬនៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុ និងហានិភ័យ និងភាពជាម្ចាស់នៃទ្រព្យសកម្មត្រូវបានផ្ទេរទៅអង្គភាពផ្សេងទៀត។ សម្ព័ន្ធធនាគារ និងធនាគារត្រូវទទួលស្គាល់ផលប្រយោជន៍ដែលបានរក្សាទុក និងបំណុលពាក់ព័ន្ធដែលអាចនឹងត្រូវបង់ ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារមិនផ្ទេរ ឬរក្សាទុកនូវរាល់ហានិភ័យនិងភាពជាម្ចាស់នៃទ្រព្យសកម្ម និងបន្តគ្រប់គ្រងទ្រព្យសកម្មដែលបានផ្ទេរ។ សម្ព័ន្ធធនាគារ និងធនាគារនៅតែបន្តទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងទទួលស្គាល់កម្ចីសម្រាប់ទឹកប្រាក់ ដែលទទួលបានប្រសិនបើសម្ព័ន្ធធនាគារ និងធនាគាររក្សាទុកជាសារវន្តនូវរាល់ហានិភ័យ និងភាពជាម្ចាស់នៃទ្រព្យសកម្មដែលបានផ្ទេរ។

ការលុបចេញពីបញ្ជី

ឥណទាន និងមូលបត្របំណុលត្រូវបានលុបចេញពីបញ្ជីទាំងស្រុង នៅពេលមិនមានការរំពឹងទុកថាទ្រព្យសកម្មហិរញ្ញវត្ថុនោះអាចប្រមូលបានមកវិញ (ទោះបីជាផ្នែកខ្លះ ឬទាំងស្រុងក៏ដោយ)។ ករណីនេះមានជាទូទៅនៅពេលសម្ព័ន្ធធនាគារ និងធនាគារកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។

ការលុបចេញពីបញ្ជីបង្កើតបានជាការលែងទទួលស្គាល់។ សម្ព័ន្ធធនាគារ និងធនាគារអាចអនុវត្តសកម្មភាពប្តឹង ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជី។ទឹកប្រាក់ប្រមូលបានមកវិញ ដែលបានមកពីសកម្មភាពពង្រឹងការអនុវត្តរបស់សម្ព័ន្ធធនាគារ និងធនាគារនឹងបណ្តាលឲ្យមានការថយចុះតម្លៃនៃការខាតបង់ ដែលនឹងត្រូវបានបង្ហាញនៅក្នុង "ចំណូលប្រតិបត្តិការផ្សេងៗ" នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

ការបង្ហាញនៃសំវិធានធន ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ៖

សំវិធានធនលើការខាតបង់ឥណទានដែលរំពឹងទុក ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងដោយតម្លៃដករំលស់៖ ជាការដកចេញពីតម្លៃដុលនៃទ្រព្យសកម្មនោះ និង
- កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ជាសំវិធានធននៅក្នុងបំណុលផ្សេងៗ។

បំណុលហិរញ្ញវត្ថុ

បំណុលហិរញ្ញវត្ថុ គឺជាកាតព្វកិច្ចក្នុងកិច្ចសន្យា ក្នុងការប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឬដើម្បីបូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ជាមួយសហគ្រាសផ្សេងទៀត ក្រោមលក្ខខណ្ឌដែលមិនអំណោយផលដល់សម្ព័ន្ធធនាគារ និងធនាគារ។

បំណុលហិរញ្ញវត្ថុដែលរួមមានប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់កម្ចី បំណុលភតិសន្យា និងបំណុលផ្សេងៗ ត្រូវបានវាស់វែងដំបូងដោយតម្លៃសមស្របក្រោយគិតថ្លៃដើមប្រតិបត្តិការ។ បំណុលហិរញ្ញវត្ថុទាំងនេះត្រូវបានវាស់ជាបន្តបន្ទាប់នៅតម្លៃដករំលស់ដោយ ប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព គឺជាវិធីសាស្ត្រគណនាការចំណាយរំលស់នៃបំណុលហិរញ្ញវត្ថុ និងការបែងចែកចំណាយការប្រាក់ក្នុងកាលកំណត់។ អត្រាការប្រាក់ប្រសិទ្ធភាព គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទទួលបានតាមរយៈអាយុកាលរំពឹងទុករបស់បំណុលហិរញ្ញវត្ថុ ឬក្នុងរយៈពេលខ្លីជាងប្រសិនបើសមស្របឲ្យស្មើនឹងចំនួនទឹកប្រាក់យោងសុទ្ធលើការទទួលស្គាល់ដំបូង។

ការកែប្រែ និងការលែងទទួលស្គាល់បំណុលហិរញ្ញវត្ថុ

សម្ព័ន្ធធនាគារ និងធនាគារលែងទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចបានចែងក្នុងកិច្ចសន្យាត្រូវបានលុបចោល ឬត្រូវបានបោះបង់ចោល ឬផុតកំណត់។ ភាពខុសគ្នារវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលលែងទទួលស្គាល់ និងទឹកប្រាក់ដែលបានបង់និងត្រូវបង់ ត្រូវបានទទួលស្គាល់នៅក្នុង ចំណេញ ឬខាត។

កិច្ចសន្យាធានាហិរញ្ញវត្ថុ

កិច្ចសន្យាធានាហិរញ្ញវត្ថុដែលបោះផ្សាយដោយធនាគារត្រូវបានវាស់វែងដោយតម្លៃសមស្រប ហើយ

ប្រសិនបើមិនបានវាស់វែងតាមតម្លៃសមស្របវាត្រូវបានវាស់វែងនូវចំនួនខ្ពស់ជាងរវាង៖

- តម្លៃការខាតបង់ដែលត្រូវបានកំណត់តាម CIFRS ៩ និង
- តម្លៃដែលត្រូវបានទទួលស្គាល់ដំបូងដក ប្រាក់ចំណូលបង្គរដែលបានទទួលស្គាល់ស្របតាមគោលនយោបាយប្រាក់ចំណេញរបស់សម្ព័ន្ធធនាគារ និងធនាគារ។

សម្ព័ន្ធធនាគារ និងធនាគារ មិនបានវាស់វែងកិច្ចសន្យាធានាហិរញ្ញវត្ថុដោយតម្លៃសមស្របតាម ចំណេញ ឬខាតទេ។

ការរៀបចំការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនសុទ្ធត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលសម្ព័ន្ធធនាគារ និងធនាគារមានសិទ្ធិអនុវត្តតាមផ្លូវច្បាប់ ក្នុងការកាត់កងបរិមាណដែលបានទទួលស្គាល់ និងមានបំណងដើម្បីទូទាត់នៅលើមូលដ្ឋានសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។ សិទ្ធិក្នុងការកាត់កងត្រូវតែមាននាពេលបច្ចុប្បន្ននេះជាជាងការពឹងផ្អែកលើព្រឹត្តិការណ៍នាពេលអនាគត ហើយត្រូវតែអនុវត្តបានដោយសមភាគីណាមួយទាំងក្នុងដំណើរជំនួញធម្មតា និងមិនមានលទ្ធភាពសងបំណុលឬក្ស័យធនក្នុងករណីមានការខកខានសង។

២.៨. ភតិសន្យា

នៅពេលចាប់ផ្តើមកិច្ចសន្យា សម្ព័ន្ធធនាគារ និងធនាគារធ្វើការវាយតម្លៃថា កិច្ចសន្យាជាភតិសន្យា ឬមានភតិសន្យាដែរ ឬទេ។ សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់សិទ្ធក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាចំពោះគ្រប់កិច្ចសន្យាភតិសន្យាទាំងអស់ ដែលធនាគារគឺជាភតិក: លើកលែងតែការជួលរយៈពេលខ្លី (កំណត់ជាភតិសន្យាជាមួយរយៈពេលភតិសន្យា ១២ខែ ឬតិចជាងនេះ) និងភតិសន្យារបស់ទ្រព្យសកម្មដែលមានតម្លៃទាប។ សម្រាប់ភតិសន្យាទាំងនេះ សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់ ការទូទាត់ភតិសន្យាជាចំណាយប្រតិបត្តិការតាមមូលដ្ឋានថេរដោយផ្អែកទៅតាមរយៈពេលភតិសន្យា លើកលែងតែមូលដ្ឋានជាប្រព័ន្ធមួយផ្សេងទៀតដែលមានផលប្រយោជន៍សេដ្ឋកិច្ច ដែលបានមកពីទ្រព្យសកម្មភតិសន្យាដែលបានប្រើប្រាស់។

បំណុលភតិសន្យា

បំណុលភតិសន្យាត្រូវបានវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យា ដែលមិនទាន់បានបង់នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា និងត្រូវបានធ្វើអប្បហារដោយប្រើអត្រាកម្ចីបន្ថែម ដែលជាអត្រាការប្រាក់សម្ព័ន្ធធនាគារ និងធនាគារនឹងត្រូវបង់ ដើម្បីខ្ចីប្រាក់ក្នុងការទិញទ្រព្យសកម្មមួយដោយដាក់ទ្រព្យបញ្ចាំស្រដៀងគ្នាផ្អែកលើលក្ខខណ្ឌស្រដៀងគ្នា ដែលមានតម្លៃប្រហាក់ប្រហែលតម្លៃនៃសិទ្ធិក្នុងការប្រើទ្រព្យសកម្មនៅcស្ថានភាពសេដ្ឋកិច្ចតែមួយ។

ការទូទាត់ភតិសន្យាដែលត្រូវបញ្ចូលទៅក្នុងការវាស់វែងបំណុលភតិសន្យា រួមមាន៖

- ការទូទាត់ភតិសន្យាថេរ ដកចេញនូវការលើកទឹកចិត្តភតិសន្យាប្រសិនបើមាន
- ការបង់ប្រាក់ពិន័យលើការបញ្ចប់ភតិសន្យា ប្រសិនបើលក្ខខណ្ឌភតិសន្យា បានឆ្លុះបញ្ចាំងពីការអនុវត្តជម្រើសក្នុងការ បញ្ចប់ភតិសន្យា។

បំណុលភតិសន្យា ត្រូវបានបង្ហាញជាធាតុដាច់ដោយឡែកមួយ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

បំណុលភតិសន្យា ត្រូវបានវាស់វែងជាបន្តបន្ទាប់ ដោយការកើនឡើងនូវតម្លៃយោង ដើម្បីឆ្លុះបញ្ចាំងពីការប្រាក់លើបំណុលភតិសន្យា (ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព) និងដោយការថយចុះនូវតម្លៃយោង ដើម្បីឆ្លុះបញ្ចាំងពីការបង់សងភតិសន្យា។

សម្ព័ន្ធធនាគារ និងធនាគារធ្វើការវាស់វែងបំណុលភតិសន្យាឡើងវិញ (និងធ្វើការកែតម្រូវជាមួយនឹងសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ដែលពាក់ព័ន្ធ) នៅពេលដែល៖

- លក្ខខណ្ឌភតិសន្យាមានការផ្លាស់ប្តូរ ដែលក្នុងករណីនេះ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញ ដោយការធ្វើអប្បហារតាមអត្រាអប្បហារដែលបានកែប្រែ។
- កិច្ចសន្យាភតិសន្យាត្រូវបានកែប្រែ ហើយភតិសន្យាដែលបានកែប្រែនេះ មិនត្រូវបានគិតថាជាភតិសន្យាដាច់ដោយឡែកមួយទៀតនោះទេ ដែលក្នុងករណីនេះ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញ ដោយការធ្វើអប្បហារតាមអត្រាអប្បហារដែលបានកែប្រែ ដែលមានប្រសិទ្ធភាពគិតចាប់ពីថ្ងៃដែលមានការកែប្រែនោះ។

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម រួមមាន ការវាស់វែងដំបូងរបស់បំណុលភតិសន្យាដែលពាក់ព័ន្ធការទូទាត់ភតិសន្យាដែលបានធ្វើឡើងនៅពេល ឬមុនពេលថ្ងៃចាប់ផ្តើម និងថ្លៃដើមដំបូងពាក់ព័ន្ធផ្ទាល់ប្រសិនបើមាន។ សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានវាស់វែងជាបន្តបន្ទាប់ តាមរយៈថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃ។

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវធ្វើរំលស់ដោយផ្អែកលើចិរវេលារបស់ភតិសន្យា ឬអាយុកាលប្រើប្រាស់របស់ ទ្រព្យសកម្មដែលពាក់ព័ន្ធ មួយណាលឿនជាង។ រំលស់ត្រូវចាប់ផ្តើម នៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានបង្ហាញជាធាតុដាច់ដោយឡែកមួយនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

២.៩. ទ្រព្យសម្បត្តិ និងបរិក្ខារ

ធាតុនៃទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ពីឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។ ថ្លៃដើមនៃទ្រព្យសម្បត្តិ និងបរិក្ខាររួមមានថ្លៃទិញ និងថ្លៃក្នុងការនាំយកទ្រព្យនោះទៅទីតាំងរបស់ខ្លួនសម្រាប់ការប្រើប្រាស់ដែលបានគ្រោងទុក។

នៅពេលដែលផ្នែកនៃទ្រព្យសម្បត្តិ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ផ្នែកទាំងនោះត្រូវបានចាត់ទុកជាធាតុផ្សេងគ្នារបស់ទ្រព្យសម្បត្តិ និងបរិក្ខារ។

ចំណាយជាបន្តបន្ទាប់ ត្រូវបានធ្វើមូលធនកម្មទៅក្នុងតម្លៃយោង ប្រសិនបើមានភាពប្រាកដថាវាផ្តល់អត្ថប្រយោជន៍ សេដ្ឋកិច្ចនាពេលអនាគតដល់សម្ព័ន្ធធនាគារ និងធនាគារលើសពីស្តង់ដាដើម។ ការជួសជុល និងថែទាំជាប្រចាំ ត្រូវបាន ទទួលស្គាល់ជាចំណាយនៅក្នុងគ្រាដែលបានកើតឡើង។

រំលស់ត្រូវបានគណនាដើម្បីលុបចេញនូវថ្លៃដើមរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ ដកតម្លៃនៅសល់ ដោយប្រើវិធីសាស្ត្ររំលស់ថេរ ផ្អែកលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងចំណេញ ឬខាត។

អាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសម្បត្តិ និងបរិក្ខារ មានដូចខាងក្រោម៖

	អាយុកាលប្រើប្រាស់
ការកែលម្អអគារជួល	១ – ១៥ឆ្នាំ
បរិក្ខារការិយាល័យ គ្រឿងសង្ហារឹម និងគ្រឿងបំពាក់	៥ ឆ្នាំ
យានយន្ត	៥ ឆ្នាំ
កុំព្យូទ័រ និងបរិក្ខារព័ត៌មានវិទ្យា	៥ – ១០ឆ្នាំ

ការងារកំពុងសាងសង់ មិនត្រូវបានគិតរំលស់ទេនៅក្នុងអំឡុងពេលសាងសង់ រហូតដល់ពេលដែលទ្រព្យសម្បត្តិ ដែលពាក់ព័ន្ធបានបញ្ចប់ និងដាក់ឲ្យប្រើប្រាស់។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃនៅសល់ ត្រូវបានពិនិត្យឡើងវិញ និងកែតម្រូវឲ្យបានសមស្រប នៅរៀងរាល់ចុងការិយបរិច្ឆេទ។

ទ្រព្យសម្បត្តិ និងបរិក្ខារ ដែលបានដករំលស់អស់ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបបំបាត់ចោល។

ផ្នែកនៃទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានលែងទទួលស្គាល់នៅពេលបោះចោល ឬនៅពេលដែលមិនមានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចនាពេលអនាគត ដែលត្រូវបានរំពឹងថានឹងកើតឡើងពីការប្រើប្រាស់បន្តនៃទ្រព្យនោះ។ ចំណេញ ឬខាតដែលកើតឡើងដោយសារការលក់ចេញ ឬឈប់ប្រើប្រាស់ទ្រព្យសកម្មត្រូវបានកំណត់ថាជាភាពខុសគ្នារវាងចំណូលលក់ និងតម្លៃយោង ហើយត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត។

២.១០. ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានសូហ្វែរ និងអាជ្ញាប័ណ្ណ និងត្រូវបានបង្ហាញតាមថ្លៃដើម ដករំលស់បង្គរ និងឱនភាពនៃតម្លៃបង្គរប្រសិនបើមាន។ សូហ្វែរអាចត្រូវបានទិញពីអ្នកលក់ ឬបង្កើតឡើងដោយផ្ទៃក្នុង។

ចំណាយជាបន្តបន្ទាប់លើសូហ្វែរ និងអាជ្ញាប័ណ្ណ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោង ប្រសិនបើប្រាកដថា វាផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតឲ្យទៅទ្រព្យសកម្មជាក់លាក់មួយដែលទាក់ទងគ្នា។ រាល់ការចំណាយជាបន្តបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងគ្រាដែលបានកើតឡើង។

សូហ្វែរ និងអាជ្ញាប័ណ្ណ ត្រូវបានធ្វើរំលស់ទៅក្នុងចំណេញ ឬ ខាត ដោយផ្អែកលើមូលដ្ឋានថេរគិតចាប់ពីពេលដែលអាចប្រើប្រាស់បាន។ អាជ្ញាប័ណ្ណ និងសូហ្វែរ ត្រូវបានធ្វើរំលស់ទៅលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានចាប់ពី ៣ឆ្នាំ ដល់២០ឆ្នាំនិង អតិបរមា ៥ ឆ្នាំសម្រាប់សូហ្វែរដែលបានបង្កើតដោយផ្ទៃក្នុង។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃនៅសល់ ត្រូវពិនិត្យឡើងវិញ និងកែតម្រូវឲ្យបានសមស្រប នៅរៀងរាល់ចុងការិយបរិច្ឆេទ។

២.១១. សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលសម្ព័ន្ធធនាគារ និងធនាគារមានកាតព្វកិច្ច (តាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោល) នាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍ សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ។

តម្លៃដែលត្រូវបានទទួលស្គាល់ជាសំវិធានធន គឺជាការប៉ាន់ស្មានដ៏ប្រសើរបំផុត នៃទឹកប្រាក់ដើម្បីដោះស្រាយកាតព្វកិច្ចបច្ចុប្បន្ន នៅចុងការិយបរិច្ឆទដោយគិតគូរពីហានិភ័យ និងភាពមិនច្បាស់លាស់ជុំវិញកាតព្វកិច្ចនោះ។ នៅពេលដែលសំវិធានធន ត្រូវបានវាស់វែងដោយប្រើការរំពឹងទុកនៃលំហូរសាច់ប្រាក់ដើម្បីដោះស្រាយកាតព្វកិច្ចបច្ចុប្បន្ន តម្លៃយោងនោះគឺជាតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ទាំងនោះ។

ការតម្រូវឲ្យមានការទូទាត់សំវិធានធន គឺនៅពេលដែលអត្ថប្រយោជន៍ពីសេដ្ឋកិច្ចខ្លះ ឬទាំងអស់ត្រូវបានរំពឹងអាចយកត្រលប់មកវិញពីតតិយជន នោះគណនីត្រូវទទួល ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ប្រសិនបើប្រាកដថាសំណងនឹងត្រូវបានទទួល និងចំនួនដែលអាចទទួលបានគឺអាចធ្វើការវាស់វែងប្រកបដោយការទុកចិត្តបាន។

២.១២. សំវិធានធនតាមបទប្បញ្ញត្តិ និងទុនបម្រុងតាមបទប្បញ្ញត្តិ

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាស លេខ ធ៧-០១៧-៣៤៤ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាននិង សំវិធានធនលើអឺមភែរមិន ដើម្បីធានាបានភាពត្រឹមត្រូវនៃការទទួលស្គាល់ ការវាស់វែង ការធ្វើសំវិធានធន និងការរាយការណ៍ចំពោះហ្វាស៊ីលីធីដែលមានអឺមភែរមិន របស់ស្ថាប័ន។

ហ្វាស៊ីលីធីនៅក្នុងប្រកាសនេះ សំដៅដល់ឥណទាន និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ទាំងនៅក្នុង ឬក្រៅតារាងតុល្យការ ដែលគ្រឹះស្ថានបានផ្តល់ទៅឲ្យសមភាគី ហើយហ្វាស៊ីលីធីនេះអាចបង្កហានិភ័យឥណទានដល់គ្រឹះស្ថាន។

យោងតាមប្រកាសនេះ សម្ព័ន្ធធនាគារ និងធនាគារត្រូវធ្វើសំវិធានធនសម្រាប់ហ្វាស៊ីលីធីដែលមានអឺមភែរមិន ដោយអនុលោម តាមបទប្បញ្ញត្តិ ទន្ទឹមគ្នានឹងការគណនាសំវិធានធនដោយយោងតាមស្តង់ដា CIFRSs។ សំវិធានធនដែលគណនាតាម CIFRSs ត្រូវបានទទួលស្គាល់ និងកត់ត្រា។ ចំនួនលើសនៃសំវិធានធនដែលបានមកពីការគណនាស្របតាមបទប្បញ្ញត្តិ ប្រៀបធៀបទៅនឹងការគណនាតាម CIFRSs នឹងត្រូវផ្ទេរពីគណនីប្រាក់ចំណេញរក្សាទុកទៅក្នុងគណនីទុនបម្រុងតាមបទប្បញ្ញត្តិ ក្នុងខ្លង់មូលធនរបស់ភាគទុនិកដូចដែលបានបង្ហាញក្នុងកំណត់សម្គាល់លេខ ២១។

នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា បានចេញសារាចរណែនាំលេខ ធ៧-០១៨-០០១ ដើម្បីបញ្ជាក់បន្ថែមលើការអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអឺមភែរមិន។ យោងតាម សារាចរនេះ សម្ព័ន្ធធនាគារ និងធនាគារត្រូវធ្វើការគណនាសំវិធានធនសម្រាប់ហ្វាស៊ីលីធីដែលមានអឺមភែរមិន ដោយអនុលោមតាមបទប្បញ្ញត្តិដោយហ្វាស៊ីលីធីត្រូវបានចាត់ជា ៥ ថ្នាក់ ដែលមានអត្រាសំវិធានធន ដូចខាងក្រោម៖

ចំណាត់ថ្នាក់	ចំនួនថ្ងៃដែលហួសកាលកំណត់សង	អត្រាសំវិធានធន
សំវិធានធនទូទៅ		
ហ្វាស៊ីលីធីរយៈពេលខ្លី (តិចជាងឬស្មើមួយឆ្នាំ)		
ធម្មតា	ពី ០ ទៅ ១៤ ថ្ងៃ	១%
ហ្វាស៊ីលីធីរយៈពេលវែង (លើសពីមួយឆ្នាំ)		
ធម្មតា	ពី ០ ទៅ ២៩ ថ្ងៃ	១%

ចំណាត់ថ្នាក់	ចំនួនថ្ងៃដែលហួសកាលកំណត់សង	អត្រាសំវិធានធន
សំវិធានធនជាក់លាក់		
ហ្វាស៊ីលីធីរយៈពេលខ្លី (តិចជាងឬស្មើមួយឆ្នាំ)		
ឃ្លាំមើល	ពី ១៥ ទៅ ៣០ ថ្ងៃ	៣%
ក្រោមស្តង់ដា	ពី ៣១ ទៅ ៦០ ថ្ងៃ	២០%
សង្ស័យ	ពី ៦១ ទៅ ៩០ ថ្ងៃ	៥០%
បាត់បង់	ពី ៩១ ថ្ងៃឡើងទៅ	១០០%
ហ្វាស៊ីលីធីរយៈពេលវែង (លើសពីមួយឆ្នាំ)		
ឃ្លាំមើល	ពី ៣០ ទៅ ៨៩ ថ្ងៃ	៣%
ក្រោមស្តង់ដា	ពី ៩០ ទៅ ១៧៩ ថ្ងៃ	២០%
សង្ស័យ	ពី ១៨០ ទៅ ៣៥៩ ថ្ងៃ	៥០%
បាត់បង់	ពី ៣៦០ ថ្ងៃឡើងទៅ	១០០%

សំវិធានធនត្រូវបានគណនាជាភាគរយនៃចំនួនសមតុល្យហ្វាស៊ីលីធី ដែលនៅសល់នាចុងការិយបរិច្ឆេទនីមួយៗ។

នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជាបានចេញលិខិត លេខ ធ៣០-០២៥-១៧០ ស្តីពីការគណនាសំវិធានធនតាមបទប្បញ្ញត្តិដើម្បីកំណត់ទុនបម្រុងតាមបទប្បញ្ញត្តិ យោងតាមប្រកាស លេខ ធ៧-០១៧-៣៤៤ ដែលបានលើកឡើងនៅខាងលើ។ យោងតាមលិខិតនេះ ធនាគារ និងស្ថាប័នហិរញ្ញវត្ថុត្រូវធ្វើការគណនាសំវិធានធនតាមបទប្បញ្ញត្តិដោយប្រើប្រាស់តម្លៃយោងដុលរបស់ហ្វាស៊ីលីធីតាម CIFRSs ហើយគុណជាមួយអត្រាសំវិធានធនតាមបទប្បញ្ញត្តិដែលបានកំណត់ខាងលើ។ ការអនុវត្តនេះត្រូវបានចូលជាធរមានគិតចាប់ពីដំណាច់ការិយបរិច្ឆេទហិរញ្ញវត្ថុ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

ការកត់ត្រលប់មកវិញនៃទុនបម្រុងតាមបទប្បញ្ញត្តិ

នៅពេលដែលសំវិធានធនឥនភាពតម្លៃដែលបានគណនាស្របតាមបទប្បញ្ញត្តិមានចំនួនតិចជាងការគណនាតាម CIFRs ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានកត់ត្រលប់មកវិញតាមចំនួនដោយមិនឲ្យលើសពីចំនួន ដែលត្រូវបានកត់ត្រា បើមិនមានទុនបម្រុងតាមបទប្បញ្ញត្តិត្រូវបានទទួលស្គាល់នៅក្នុងឆ្នាំមុនៗទេ។

២.១៣. ចំណូលការប្រាក់សុទ្ធ

ចំណូល និងចំណាយការប្រាក់សម្រាប់ឧបករណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ នៅក្នុងចំណូលការប្រាក់សុទ្ធ ជា “ចំណូលការប្រាក់” និង “ចំណាយការប្រាក់” ក្នុងគណនីចំណេញ ឬខាតដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព។

EIR គឺជាអត្រាដែលធ្វើអប្បហារយ៉ាងពិតប្រាកដនូវលំហូរសាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ស្មានរបស់ឧបករណ៍ហិរញ្ញវត្ថុ តាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុ ឬក្នុងករណីរយៈពេលខ្លី ទៅនឹងតម្លៃយោងសុទ្ធរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ លំហូរសាច់ប្រាក់នាពេលអនាគត ត្រូវបានប៉ាន់ស្មានដោយគិតគូរពីលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍។

ការគណនា EIR រួមបញ្ចូលកម្រៃទាំងអស់ ដែលបានបង់ ឬបានទទួលរវាងភាគីនៃកិច្ចសន្យាដែលបន្ថែមនិងចូលរួមដោយផ្ទាល់ចំពោះកិច្ចសន្យា ថ្លៃដើមប្រតិបត្តិការ និងបុព្វលាភ ឬការបញ្ចុះតម្លៃផ្សេងទៀត។

ចំណូល/ចំណាយការប្រាក់ត្រូវបានគណនាដោយប្រើ EIR ធៀបទៅនឹងតម្លៃយោងដុលនៃ ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានការខាតបង់ឥណទាន (មានន័យថា តម្លៃដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលធ្វើការកែសម្រួលលើការខាតបង់ឥណទានដែលរំពឹងទុក) ឬទៅតម្លៃដករំលស់នៃ បំណុលហិរញ្ញវត្ថុ។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខាតបង់ឥណទាន ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើ EIR ធៀបទៅនឹងតម្លៃដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានការខាតបង់ (មានន័យថា តម្លៃយោងដុល ដកសំវិធានធនសម្រាប់ ECLs)។

២.១៤. ចំណូលពីកម្រៃ និងជើងសារសុទ្ធ

ចំណូល និងចំណាយកម្រៃជើងសា រួមមានកម្រៃទាំងឡាយណាដែលមិនមែនជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (សូមមើលកំណត់សម្គាល់លេខ ២.១៣)។

ចំណូលកម្រៃជើងសាផ្សេងៗទៀត រួមមានកម្រៃណែនាំ កម្រៃបន្តសេវា កម្រៃកិច្ចសន្យា កម្រៃផ្ទេរប្រាក់ កម្រៃសេវា កម្រៃលើឥណទាន និងកម្រៃផ្សេងៗទៀត ត្រូវទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម។

ចំណាយកម្រៃជើងសាផ្សេងៗទៀត ពាក់ព័ន្ធនឹងប្រតិបត្តិការ និងកម្រៃសេវា នឹងត្រូវទទួលស្គាល់ជាចំណាយនៅពេលបានទទួលសេវាកម្ម។

២.១៥. អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី និង រយៈពេលវែង

អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លីត្រូវបានទទួលស្គាល់ទាក់ទងនឹងប្រាក់ឈ្នួល និងប្រាក់បៀវត្សរ៍ក្នុងរយៈពេលដែលសេវាពាក់ព័ន្ធត្រូវបានទទួលស្មើនឹងចំនួនទឹកប្រាក់ ដែលមិនបានអប្បហារនៃអត្ថប្រយោជន៍ដែលរំពឹងថានឹងបង់ជាថ្នូរនឹងសេវានោះ។ បំណុលត្រូវបានទទួលស្គាល់ចំពោះចំនួនទឹកប្រាក់ដែលរំពឹងថានឹងត្រូវបង់ ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលក្នុងការទូទាត់ចំនួនទឹកប្រាក់នេះដែលជាលទ្ធផលនៃសេវាកម្មពីមុនដែលផ្តល់ដោយនិយោជិត ហើយកាតព្វកិច្ចអាចប៉ាន់ស្មានបានដោយភាពជឿជាក់។

អត្ថប្រយោជន៍រយៈពេលវែងរបស់និយោជិត ត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ប្រមាណដែលរំពឹងថានឹងធ្វើឡើងដោយសម្ព័ន្ធធនាគារ និងធនាគារទាក់ទងនឹងសេវាកម្ម ដែលផ្តល់ដោយនិយោជិតរហូតដល់ចុងការិយបរិច្ឆេទ។

២.១៦. ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូល រួមមានពន្ធចរន្ត និងពន្ធពន្យារ។

ពន្ធចរន្ត

ពន្ធចរន្ត គឺជាពន្ធដែលរំពឹងថាត្រូវបង់ទៅលើប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តមួយភាគធំនាចុងការិយបរិច្ឆេទ និងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។ ប្រាក់ចំណេញជាប់ពន្ធ ខុសពីប្រាក់ចំណេញសុទ្ធ ដែលបានរាយការណ៍នៅក្នុងចំណេញ ឬខាត ព្រោះវាមិនរាប់បញ្ចូលចំណូល ឬចំណាយណា ដែលជាប់ពន្ធ ឬអាចកាត់កងក្នុងឆ្នាំផ្សេងទៀត ហើយវាក៏មិនរាប់បញ្ចូលនូវធាតុដែលមិនដែលជាប់ពន្ធ ឬមិនអាចកាត់កងបានផងដែរ។

សំវិធានធនត្រូវបានទទួលស្គាល់ចំពោះបញ្ហា ទាំងឡាយណាដែលការកំណត់ពន្ធមានភាពមិនច្បាស់លាស់ ប៉ុន្តែវាត្រូវបានគេគិតថាអាចនឹងមានលំហូរចេញនៃសាច់ប្រាក់ទៅឲ្យអាជ្ញាធរពន្ធនាពេលអនាគត។ សំវិធានធនត្រូវបានវាស់វែងតាមការប៉ាន់ស្មានដ៏ប្រសើរបំផុតនៃចំនួនទឹកប្រាក់ដែលរំពឹងថានឹងត្រូវបង់។ ការប៉ាន់ស្មានគឺផ្អែកលើការវិនិច្ឆ័យរបស់អ្នកជំនាញពន្ធនៅក្នុងសម្ព័ន្ធធនាគារ និងធនាគារ ដែលមានបទពិសោធន៍ពីមុនទាក់ទងនឹងសកម្មភាពបែបនេះ និងក្នុងករណីខ្លះទៀតដោយផ្អែកលើដំបូន្មានអ្នកជំនាញពន្ធឯករាជ្យ។

ពន្ធពន្យារ

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។ បំណុលពន្ធពន្យារជាទូទៅ ត្រូវបានទទួលស្គាល់លើភាពលម្អៀងបណ្តោះអាសន្នដែលជាប់ពន្ធ ហើយទ្រព្យសកម្មពន្ធពន្យារត្រូវបានទទួលស្គាល់ ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់កាត់កង ជាមួយពន្ធប្រចាំឆ្នាំនៅឆ្នាំបន្តបន្ទាប់។ ពន្ធពន្យារ មិនទទួលស្គាល់ចំពោះទ្រព្យសកម្ម និងបំណុល បណ្តោះអាសន្នដែលកើតឡើងពីការទទួលស្គាល់ដំបូងនៃ មូលនិធិពាណិជ្ជកម្ម ឬពីការទទួលស្គាល់ដំបូង (ក្រៅពីការរួមបញ្ចូលគ្នាអាជីវកម្ម) នៃទ្រព្យសកម្ម និងបំណុលផ្សេងទៀតនៅក្នុងប្រតិបត្តិការដែលមិនប៉ះពាល់ដល់ទាំងប្រាក់ចំណេញជាប់ពន្ធ ឬប្រាក់ចំណេញគណនេយ្យ។

ទ្រព្យសកម្មពន្ធពន្យារ ត្រូវទទួលស្គាល់ចំពោះឥណទានពន្ធដែលមិនទាន់បានប្រើ និងភាពលម្អៀងបណ្តោះ អាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើប្រាស់សម្រាប់កាត់កង ជាមួយពន្ធប្រចាំឆ្នាំនៅឆ្នាំបន្តបន្ទាប់។ ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានត្រួតពិនិត្យនៅរៀងរាល់ចុងការិយបរិច្ឆេទ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន។

ពន្ធពន្យារ ត្រូវបានវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ននៅពេលដែលវាត្រូវកត់ត្រលប់វិញ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តមួយភាគធំនៅចុងការិយបរិច្ឆេទ។

ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងពីផលវិបាកពន្ធដែលនឹងអនុវត្តតាមលក្ខណៈដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងទុកនៅចុងការិយបរិច្ឆេទថា អាចទទួលបានមកវិញ ឬទូទាត់នូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល។

ទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារ អាចកាត់កងបាន នៅពេលដែលមានសិទ្ធិអនុវត្តតាមច្បាប់ដើម្បីកាត់កងរវាងទ្រព្យសកម្មពន្ធចរន្ត ជាមួយនឹង បំណុលពន្ធចរន្ត និងនៅពេលដែលទាក់ទងនឹងពន្ធលើប្រាក់ចំណូល ដែលត្រូវបានប្រមូលដោយអាជ្ញាធរពន្ធដារតែមួយ ហើយសម្ព័ន្ធធនាគារ និងធនាគារមានបំណងទូទាត់ទ្រព្យសកម្ម និង បំណុលពន្ធចរន្តតាមមូលដ្ឋានសុទ្ធ។

ពន្ធចរន្ត និងពន្ធពន្យារសម្រាប់ការិយបរិច្ឆេទ

ពន្ធចរន្ត និងពន្ធពន្យារត្រូវបានទទួលស្គាល់ក្នុង ចំណេញឬខាត លើកលែងតែនៅពេលដែលពន្ធទាំង នោះទាក់ទងទៅនឹងវត្ថុដែលត្រូវបានទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ ឬដោយផ្ទាល់ក្នុងមូលធន ក្នុងករណីនេះពន្ធចរន្តនិងពន្ធពន្យារក៏ត្រូវបានទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ ឬដោយផ្ទាល់ក្នុងមូលធនរៀងគ្នា។

២.១៧. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យដែលមិនមានការកំហិតនៅធនាគារជាតិនៃកម្ពុជា និងការវិនិយោគរយៈពេលខ្លីដែលមានឥណប្រតិទានដើម ៣ខែឬតិចជាង គិតចាប់ពីកាលបរិច្ឆេទដែលបានទិញ ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃហើយត្រូវបានប្រើប្រាស់ដោយសម្ព័ន្ធធនាគារ និងធនាគារក្នុងការគ្រប់គ្រងកិច្ចសន្យារយៈពេលខ្លី។

សាច់ប្រាក់ និងសាច់ប្រាក់សមមូលត្រូវបានកត់ត្រាតាមតម្លៃដកវិលស់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

៣. ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ និងប្រភពសំខាន់ៗនៃការប៉ាន់ស្មានភាពមិនប្រាកដប្រជា

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យជាសារវន្ត និងចំនួនទ្រព្យសកម្មបំណុល ចំណូល និងចំណាយ ដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែទៅលើការប៉ាន់ស្មានគណនេយ្យ ត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងគ្រាដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែ និងការិយបរិច្ឆេទ អនាគតដែលប៉ះពាល់ដោយការកែប្រែនេះ។

៣.១. ការវិនិច្ឆ័យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យជាសារវន្ត

ព័ត៌មានអំពីការវិនិច្ឆ័យក្នុងការអនុវត្តគោលនយោបាយគណនេយ្យ ដែលមានការប៉ះពាល់ជាសារវន្ត លើចំនួន ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

ការវាយតម្លៃម៉ូដែលអាជីវកម្ម

ការចាត់ថ្នាក់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ អាស្រ័យលើលទ្ធផលនៃ SPPI និងម៉ូដែល អាជីវកម្ម(សូមមើលកំណត់សម្គាល់លេខ ២.៧)។ សម្ព័ន្ធធនាគារ និងធនាគារធ្វើការកំណត់ម៉ូដែលអាជីវកម្មនៅកម្រិតមួយ ដែលអាចឆ្លុះបញ្ចាំងពីវិធីសាស្ត្រក្នុងការគ្រប់គ្រងក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ដើម្បីសម្រេចបាននូវគោលដៅអាជីវកម្មជាក់លាក់មួយ។ ការវាយតម្លៃនេះរួមមាន ការវិនិច្ឆ័យដែលឆ្លុះបញ្ចាំងនូវរាល់ភស្តុតាងពាក់ព័ន្ធទាំងអស់ រួមទាំងវិធីវាយតម្លៃ និងវាស់វែងលទ្ធផលរបស់ទ្រព្យសកម្ម ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលរបស់ទ្រព្យសកម្ម និងវិធីគ្រប់គ្រងហានិភ័យទាំងនេះ និងវិធីសាស្ត្រការទទួលបានមកវិញនូវផលប្រយោជន៍គណៈគ្រប់គ្រងទ្រព្យសកម្មនេះ។ សម្ព័ន្ធធនាគារ និងធនាគារធ្វើការតាមដានរាល់ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃដករំលស់ដែលត្រូវបានលែងទទួលស្គាល់មុនកាលកំណត់របស់វា ដើម្បីស្វែងយល់ពីមូលហេតុក្នុងការបោះបង់ចោល និងថាតើមូលហេតុទាំងនោះស្របតាមគោលដៅអាជីវកម្មក្នុងការរក្សាទ្រព្យសកម្មដែរឬទេ។ ការតាមដាននេះ គឺជាផ្នែកនៃការវាយតម្លៃជាបន្តបន្ទាប់របស់សម្ព័ន្ធធនាគារ និងធនាគារ ថាតើម៉ូដែលអាជីវកម្មក្នុងការរក្សាទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះនៅបន្តសមស្របដែរឬទេ ហើយប្រសិនបើមិនសមស្របទេ តើមានការផ្លាស់ប្តូរណាមួយនៅក្នុងម៉ូដែលអាជីវកម្ម និងធ្វើការផ្លាស់ប្តូរចំណាត់ថ្នាក់ទ្រព្យសកម្មទាំងនោះដែរឬទេ។

ការកើនឡើងជាសារវន្តនៃហានិភ័យឥណទាន

ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៣១.១ ECLs ត្រូវវាស់វែងជាសំវិធានធនស្មើនឹង ១២ខែ ចំពោះទ្រព្យសកម្មដែលស្ថិតក្នុងចំណាត់ថ្នាក់ទី១ ឬសំវិធានធនស្មើនឹងពេញមួយអាយុកាលចំពោះទ្រព្យសកម្មដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ និងទី៣។ ទ្រព្យសកម្មមួយ ត្រូវប្តូរទៅស្ថិតនៅក្នុងចំណាត់ថ្នាក់ទី២ នៅពេលដែលហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះមានការកើនឡើងជាសារវន្ត ចាប់តាំងពីពេលទទួលស្គាល់ជាលើកដំបូង។ សម្ព័ន្ធធនាគារ និងធនាគារត្រូវពិចារណានូវព័ត៌មានប្រមើលនាពេលអនាគត ដែលព័ត៌មាននោះគាំទ្រ និងសមស្របទាំងបរិមាណ និងគុណភាពដើម្បីវាយតម្លៃហានិភ័យឥណទានរបស់ទ្រព្យសកម្មមួយមានការកើនជាសារវន្តដែរ ឬទេ។

ការចាត់ក្រុមទ្រព្យសកម្មដែលមានលក្ខណៈហានិភ័យឥណទានស្រដៀងគ្នា

នៅពេលដែល ECLs ត្រូវបានវាស់វែងលើមូលដ្ឋានប្រមូលផ្តុំ ឧបករណ៍ហិរញ្ញវត្ថុត្រូវបានដាក់ជាក្រុមដោយផ្អែកលើលក្ខណៈហានិភ័យរួម។ សម្ព័ន្ធធនាគារ និងធនាគារ តាមដានភាពសមស្របនៃលក្ខណៈហានិភ័យឥណទានជាទៀងទាត់ ដើម្បីវាយតម្លៃថាតើពួកគេបន្តមានលក្ខណៈស្រដៀងគ្នាដែរ ឬទេ។ នេះត្រូវបានទាមទារដើម្បីធានាថា លក្ខណៈហានិភ័យឥណទានគួរតែផ្លាស់ប្តូរ មានការចាត់ថ្នាក់ឡើងវិញនៃទ្រព្យសកម្មមានភាពសមស្រប។ នេះអាចបណ្តាលឲ្យមានផលបត្រថ្មីត្រូវបានបង្កើតឡើង ឬទ្រព្យសកម្មផ្លាស់ប្តូរទៅកាន់ផលបត្រដែលមានស្រាប់ដែលឆ្លុះបញ្ចាំងឲ្យកាន់តែច្បាស់អំពីលក្ខណៈ ហានិភ័យឥណទានស្រដៀងគ្នានៃក្រុមទ្រព្យសកម្មទាំងនោះ។ ការបែងចែកផលបត្រឡើងវិញ និងបម្រែបម្រួលរវាងផលបត្រ គឺជារឿងធម្មតានៅពេលដែលមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន (ឬនៅពេលដែលការកើនឡើងគួរឲ្យកត់សម្គាល់នោះបញ្ច្រាស់) ដូច្នេះហើយទ្រព្យសកម្មផ្លាស់ទីពី ECLs ១២ខែទៅ ECLs ពេញមួយអាយុកាល ឬផ្ទុយមកវិញ ប៉ុន្តែវាក៏អាចកើតឡើងផងដែរនៅក្នុងផលបត្រដែលបន្តត្រូវបានវាស់វែងនៅលើមូលដ្ឋានដូចគ្នានៃ ECLs រយៈពេល ១២ខែ ឬពេញអាយុកាល ប៉ុន្តែបរិមាណនៃ ECL ផ្លាស់ប្តូរដោយសារតែហានិភ័យឥណទាននៃផលបត្រមានភាពខុសគ្នា។

ម៉ូដែលនិងការសន្មតដែលបានប្រើ

សម្ព័ន្ធធនាគារ និងធនាគារប្រើម៉ូដែលនិងការសន្មតផ្សេងៗ ដើម្បីធ្វើការប៉ាន់ស្មាននូវ ECL។ ការវិនិច្ឆ័យត្រូវបានប្រើ ដើម្បីកំណត់ម៉ូដែលដែលសមស្របបំផុតសម្រាប់ប្រភេទទ្រព្យសកម្មនីមួយៗ និងដើម្បីកំណត់នូវការសន្មតដែលត្រូវប្រើក្នុងម៉ូដែលទាំងនេះ រួមទាំងការសន្មតពាក់ព័ន្ធនឹងចលករសំខាន់ៗរបស់ហានិភ័យឥណទាន។

ការកំណត់អាយុកាលរបស់ហ្វាស៊ីលីធីអាចប្រើប្រាស់ឡើងវិញ

សម្ព័ន្ធធនាគារ និងធនាគារបានធ្វើការវាស់វែង ECL ដោយពិចារណាទៅលើហានិភ័យនៃការខកខានក្នុងការសងនៃរយៈពេលកិច្ចសន្យាអតិបរមា។ ដោយឡែកសិទ្ធិរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការទាមទារការសង និងបញ្ឈប់កិច្ចសន្យាមិនបានធ្វើឲ្យមានការប៉ះពាល់ទៅលើការខាតបង់ឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងរយៈពេលនៃកិច្ចសន្យានោះទេសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដូចជា ប័ណ្ណឥណទាន និងឥណទានវិបារូបន៍ ដែលរួមបញ្ចូលទាំងឥណទាន និងផ្នែកនៃកិច្ចសន្យាដែលមិនទាន់បានដក។ ចំពោះឧបករណ៍ហិរញ្ញវត្ថុទាំងនោះ សម្ព័ន្ធធនាគារ និងធនាគារបានធ្វើការវាស់វែង ECL ដែលអាចមានហានិភ័យឥណទាន ហើយ ECL ត្រូវបានកាត់បន្ថយដោយការគ្រប់គ្រងហានិភ័យឥណទាន ទោះបីជារយៈពេលនោះហួសពីរយៈពេលកិច្ចសន្យាអតិបរមាក៏ដោយ។

ការគ្រប់គ្រងទៅលើក្រុមហ៊ុនអេប៊ីអេ ត្រាស ឯ.ក

ធនាគារ កាន់កាប់ភាគហ៊ុនចំនួន ៤៩% និង ភាគទុនិកមួយចំនួន កាន់កាប់ភាគហ៊ុនចំនួន ៥១% របស់ក្រុមហ៊ុន អេប៊ីអេ ត្រាស ឯ.ក។

គណៈគ្រប់គ្រង ជឿជាក់ថា ធនាគារ មានការគ្រប់គ្រងទាំងស្រុង ទៅលើក្រុមហ៊ុនបុត្រសម្ព័ន្ធ ទោះបីជាធនាគារកាន់ភាគហ៊ុនចំនួន ៤៩% របស់ក្រុមហ៊ុន អេប៊ីអេ ត្រាស ឯ.ក ដោយសារការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការទាំងអស់ត្រូវបានគ្រប់គ្រង និងដឹកនាំដោយធនាគារ។

ប្រសិនបើក្រុមប្រឹក្សាភិបាលបានសន្និដ្ឋានថា ផលប្រយោជន៍កម្មសិទ្ធ ៤៩% មិនគ្រប់គ្រាន់ដើម្បីផ្តល់ការគ្រប់គ្រងដល់ធនាគារទេ នោះក្រុមហ៊ុន អេប៊ីអេ ត្រាស ឯ.ក នឹងត្រូវបានចាត់ថ្នាក់ជាក្រុមហ៊ុនសមាគតហើយធនាគារនឹងត្រូវកត់ត្រាវាដោយប្រើវិធីសាស្ត្រមូលធននៃគណនេយ្យ ។

៣.២. ប្រភពសំខាន់ៗនៃការប៉ាន់ស្មានភាពមិនប្រាកដប្រជា

ព័ត៌មានអំពីការសន្មត និងការប៉ាន់ស្មានភាពមិនប្រាកដប្រជាដែលមានការប៉ះពាល់ជាសារវន្តលើចំនួនដែលបាន ទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

ព័ត៌មានដែលរំពឹងទុកទៅថ្ងៃខាងមុខ

សម្ព័ន្ធធនាគារ និងធនាគារបានបង្កើតនូវសេណារីយ៉ូមួយចំនួន និងថ្លឹងថ្លែងសេណារីយ៉ូទាំងនោះតាមសារៈសំខាន់នៃការរំពឹងទុកទៅថ្ងៃខាងមុខ សម្រាប់ប្រភេទផលិតផលនីមួយៗ និងការកំណត់នូវព័ត៌មានដែលរំពឹងទុកទៅថ្ងៃខាងមុខពាក់ព័ន្ធនឹងសេណារីយ៉ូនីមួយៗ។ នៅពេលវាស់វែង ECL សម្ព័ន្ធធនាគារ និងធនាគារប្រើប្រាស់នូវព័ត៌មានដែលរំពឹងទុកទៅថ្ងៃខាងមុខ ដែលមានប្រភពអាចជឿជាក់ទុកចិត្តបាន និងសមហេតុផល ដោយផ្អែកលើការសន្មតចំពោះការផ្លាស់ប្តូរនាអនាគតនូវចលករសេដ្ឋកិច្ចផ្សេងគ្នា និងរបៀបដែលចលករទាំងនេះមានការប៉ះពាល់គ្នាទៅវិញទៅមក។ ព័ត៌មានបន្ថែមអំពីការវិភាគគុណភាពឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានផ្តល់ជូននៅក្នុងកំណត់សម្គាល់ ៣១.១។

ECL បន្ថែមរបស់គណៈគ្រប់គ្រង

សម្ព័ន្ធធនាគារ និងធនាគារបានកត់ត្រា ECL បន្ថែមរបស់គណៈគ្រប់គ្រង ដើម្បីចាប់យកហានិភ័យឥណទានដែលមិនត្រូវបានឆ្លុះបញ្ចាំងយ៉ាងពេញលេញនៅក្នុងម៉ូដែល ECL និងនៅក្រោមស្ត្រេសសេណារីយ៉ូ ដោយសារតែភាពមិនប្រាកដប្រជាក្នុងទស្សនវិស័យសេដ្ឋកិច្ចនាពេលអនាគត។ ព័ត៌មានបន្ថែមអំពីការវិភាគគុណភាពឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានផ្តល់ជូននៅក្នុងកំណត់សម្គាល់ ៣១.១.៣។

ប្រូបាប៊ីលីតេនៃការខកខានសង (ហៅកាត់ថា “PD”)

PD គឺជាធាតុចូលដ៏សំខាន់ក្នុងការវាស់វែង ECL។ PD គឺជាការប៉ាន់ស្មាននូវភាពប្រហាក់ប្រហែលនៃការខកខានសងក្នុងរយៈពេលណាមួយ ដែលការគណនារបស់វា ត្រូវបានរួមបញ្ចូលនូវទិន្នន័យប្រវត្តិសាស្ត្រ ការសន្មត និងលក្ខខណ្ឌរំពឹងទុកនាពេលអនាគត។ ព័ត៌មានបន្ថែមអំពីការវិភាគគុណភាពឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានផ្តល់ជូននៅក្នុងកំណត់សម្គាល់ ៣១.១។

អត្រាខាតបង់ពេលខកខានសង (ហៅកាត់ថា “LGD”)

LGD គឺជាការប៉ាន់ស្មាននូវការខាតបង់កើតចេញមកពីការខកខានសង។ វាផ្អែកទៅលើភាពខុសគ្នារវាង លំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលដល់កាលកំណត់ត្រូវបង់សង និង លំហូរសាច់ប្រាក់ដែលម្ចាស់កម្ចីរំពឹងថានឹងទទួលបាន ដោយគិតទាំងលំហូរសាច់ប្រាក់ពីទ្រព្យដាក់ធានា និងការពង្រឹងឥណទានទាំងមូល។ ព័ត៌មានបន្ថែមអំពីការវិភាគគុណភាពឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានផ្តល់ជូននៅក្នុងកំណត់សម្គាល់ ៣១.១។

ពន្ធ

ប្រព័ន្ធពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈច្រើនប្រភេទ និងបទប្បញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ ដែលជាទូទៅមានភាពមិនច្បាស់លាស់ មានភាពផ្ទុយគ្នា និងអាស្រ័យទៅលើការបកស្រាយ។ ជាទូទៅ យុត្តាធិការនិងអាជ្ញាធរពន្ធភាគច្រើន តែងតែមានការបកស្រាយផ្សេងៗពីគ្នា។ ពន្ធ គឺត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការអង្កេតដោយអាជ្ញាធរ ដែលត្រូវបានផ្តល់សិទ្ធិអំណាចដោយច្បាប់ក្នុងការដាក់ពិន័យការផាកពិន័យ និងការគិតការប្រាក់។

បញ្ហាទាំងនេះអាចបង្កើតឲ្យមានហានិភ័យពន្ធយ៉ាងខ្លាំងសម្រាប់សម្ព័ន្ធធនាគារ និងធនាគារ។គណៈគ្រប់គ្រងជឿជាក់ថា ពួកគេ មានការយល់ដឹងពីបទប្បញ្ញត្តិពន្ធដែលពាក់ព័ន្ធ និងបានធ្វើសំវិធានធនដែលមានលក្ខណៈគ្រប់គ្រាន់ដោយផ្អែកទៅ លើការបកស្រាយរបស់ពួកគេស្របតាមច្បាប់ពន្ធនាពេលបច្ចុប្បន្ន។ ទោះជាយ៉ាងណាក៏ដោយអាជ្ញាធរជាប់ពាក់ព័ន្ធ អាចនឹងមានបំណកស្រាយខុសគ្នា ហើយផលប៉ះពាល់អាចមានទំហំធំ។ ព័ត៌មានបន្ថែមអំពី យថាភាពនៃពន្ធ ត្រូវបានផ្តល់ជូននៅក្នុងកំណត់សម្គាល់ ៣២។

៤. សាច់ប្រាក់ក្នុងដៃ

សម្ព័ន្ធធនាគារ និងធនាគារ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
សាច់ប្រាក់ក្នុងដៃ	៥៩៧.០២៥	២.៣៩៥.៨៦២	៥០៣.៧១៦	២.០២៧.៤៥៧
សាច់ប្រាក់កំពុងប្រមូល	៨១.៥៥២	៣២៧.២៦៨	៣១.០០១	១២៤.៧៧៩
	៦៧៨.៥៥៧	**២.៧២៣.១៣០**	**៥៣៤.៧១៧**	**២.១៥២.២៣៦**

៥. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

សម្ព័ន្ធធនាគារ និងធនាគារ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
រយៈពេលខ្លី				
គណនីចរន្ត	២៨៩.៦៤២	១.១៩៨.៤៥០	២៨៩.៩៧១	១.១៦៧.១៣៣
មូលបត្រអាចជួញដូរបាន (NCD) (i)	៧៨៦.៦៣៥	៣.១៥៦.៧៦៦	៤២០.៣៨២	១.៦៩២.០៣៨
ទុនបម្រុងកាតព្វកិច្ច (ii)	៨៨៦.៧០៨	៣.៥៥៨.៣៦០	៧៤៣.៤២៧	២.៩៩២.២៩៤
រយៈពេលវែង				
ប្រាក់តម្កល់ធានាលើដើមទុន (iii)	១៣២.៦៨៥	៥៣២.៤៦៥	១៣២.៨១៦	៥៣៤.៥៨៤
	២.១០៤.៦៧០	**៨.៤៤៦.០៤១**	**១.៥៨៦.៥៩៦**	**៦.៣៨៦.០៤៩**

(i) មូលបត្រអាចជួញដូរបាន

ក្នុងមូលបត្រអាចជួញដូរបាន សម្ព័ន្ធធនាគារ និងធនាគារបានដាក់មូលបត្រចំនួន ២២៧ លានដុល្លារអាមេរិក (៩១០.៩៥១លានរៀល) ជាទ្រព្យធានាលើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (២០២៤៖ ១៥៣លានដុល្លារអាមេរិក ឬ ៦១៥.៨២៥ លានរៀល) និងចំនួន ៣២ លានដុល្លារអាមេរិក (១២៨.៤១៦ លានរៀល) ជាទ្រព្យធានាលើ ឥណទានវិបារូបន៍ (២០២៤៖ ២៥ លានដុល្លារអាមេរិក ឬ ១០០.៦២៥ លានរៀល)។ នាថ្ងៃទី ៣១ ធ្នូ ២០២៥ សម្ព័ន្ធធនាគារ និងធនាគារមិនទាន់បានប្រើឥណទានវិបារូបន៍នៅឡើយទេ។

(ii) ទុនបម្រុងកាតព្វកិច្ច

ទុនបម្រុងកាតព្វកិច្ចគឺជាប្រាក់បម្រុងដែលប្រែប្រួលតាមកម្រិតនៃប្រាក់បញ្ញើរបស់អតិថិជន និងប្រាក់កម្ចីពីបរទេស។ វាត្រូវបានរក្សាទុកដោយអនុលោមតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០២០-២៣០ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ដែលត្រូវបានគណនាតាមអត្រា ៧% នៃប្រាក់បញ្ញើរបស់អតិថិជនជាប្រាក់រៀល និងរូបិយវត្ថុក្រៅពីប្រាក់រៀល។

នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានចេញលិខិតជូនដំណឹងលេខធ៧-០២៣-០០៥ ដើម្បីបង្កើនអត្រាដល់៩%សម្រាប់រូបិយប័ណ្ណផ្សេងទៀត ខណៈពេលដែលរូបិយប័ណ្ណរៀលត្រូវបានរក្សានៅអត្រា ៧% ដែលត្រូវអនុវត្តពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានចេញលិខិតជូនដំណឹងលេខធ៧-០២៣-២៦២១ ដើម្បីកាត់បន្ថយអត្រាទៅ ៧% សម្រាប់រូបិយប័ណ្ណផ្សេងទៀតមកកម្រិតដូចគ្នាជាមួយនឹងរូបិយប័ណ្ណរៀល ដែលអនុវត្តចាប់ពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជាបានចេញលិខិតជូនដំណឹងលេខ ធ៧-០២៤-១៧១៨ ដើម្បីរក្សានៅអត្រា ៧% សម្រាប់រូបិយប័ណ្ណរៀល និងរូបិយប័ណ្ណផ្សេងទៀតរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

(iii) ប្រាក់តម្កល់ធានាលើដើមទុន

ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០១-១៣៦ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ធនាគារចាំបាច់ត្រូវរក្សាប្រាក់តម្កល់តាមច្បាប់ឲ្យបាន ១០% នៃដើមទុនដែលបានចុះបញ្ជីរបស់ខ្លួន។ ប្រាក់តម្កល់នេះមិនអាចប្រើប្រាស់បានក្នុងប្រតិបត្តិការប្រចាំថ្ងៃនោះទេ និងត្រូវបង្វិលឲ្យធនាគារវិញ នៅពេលដែលធនាគារស្ម័គ្រចិត្តបញ្ឈប់អាជីវកម្មរបស់ខ្លួននៅប្រទេសកម្ពុជា។

ពុំមានសំវិធានលើការខាតបង់ពីឱនភាពតម្លៃត្រូវបានទទួលស្គាល់សម្រាប់សមតុល្យនៅធនាគារជាតិទេព្រោះគណៈគ្រប់គ្រងបានកំណត់ថាហានិភ័យឥណទាននៃហ្វាស៊ីលីធីទាំងនេះមានកម្រិតទាបបំផុត។

៦. សមតុល្យនៅធនាគារនានា

សម្ព័ន្ធធនាគារ និង ធនាគារ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
សមតុល្យនៅធនាគារនានាវាស់វែងតាមតម្លៃដករំលស់	៣.៥០១.៨៤៨	១៤.០៥២.៩១៦	២.៤៧៥.៥៥៨	៩.៩៦៤.១២១
សំវិធានធនលើការខាតបង់ពីឱនភាពនៃតម្លៃ	(១.៩៩១)	(៧.៩៩០)	(៩៩៧)	(៤.០១៣)
	៣.៤៩៩.៨៥៧	**១៤.០៤៤.៩២៦**	**២.៤៧៤.៥៦១**	**៩.៩៦០.១០៨**

តម្លៃយោងដុលត្រូវបានធ្វើការវិភាគដូចខាងក្រោម៖

(ក) តាមប្រភេទ ៖

សម្ព័ន្ធធនាគារ និង ធនាគារ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
គណនីមានកាលកំណត់	២.៩៦៩.៦០២	១១.៩១៧.០១៣	១.៨៦៩.៨១៩	៧.៥២៦.០២១
គណនីសន្សំ	៣១៥.១០៦	១.២៦៤.៥២០	១៦២.៦៥០	៦៥៤.៦៦៦
គណនីចរន្ត	១៣៨.៣៦៩	៥៥៥.២៧៥	២៥.១១៥	១០១.០៨៨
គណនីរំលងអធ្រាត្រ	៧៨.៧៧១	៣១៦.១០៨	៤១៧.៩៧៤	១.៦៨២.៣៤៦
	៣.៥០១.៨៤៨	**១៤.០៥២.៩១៦**	**២.៤៧៥.៥៥៨**	**៩.៩៦៤.១២១**

(ខ) តាមរូបិយប័ណ្ណ ៖

សម្ព័ន្ធធនាគារ និង ធនាគារ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ប្រាក់ដុល្លារអាមេរិក	៣.៥០០.៣៨១	១៤.០៤៧.០២៩	២.៤៧០.១៣៤	៩.៩៤២.២៩០
ប្រាក់រៀលខ្មែរ	៧៥៨	៣.០៤២	៤.០៩១	១៦.៤៦៦
រូបិយប័ណ្ណផ្សេងទៀត	៧០៩	២.៨៤៥	១.៣៣៣	៥.៣៦៥
	៣.៥០១.៨៤៨	**១៤.០៥២.៩១៦**	**២.៤៧៥.៥៥៨**	**៩.៩៦៤.១២១**

(គ) តាមកាលកំណត់ ៖

សម្ព័ន្ធធនាគារ និង ធនាគារ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ក្នុងរយៈពេល ១ ខែ	១.០៩៥.៩៧០	៤.៣៩៨.១២៨	១.២៥៥.៩៩៤	៥.០៥៥.៣៧៧
លើសពី ១ខែ ទៅ ៣ខែ	៧២០.៩៧៣	២.៨៩៣.២៦៥	៣៨៨.៤៧៤	១.៥៦៣.៦០៨
លើសពី ៣ខែ ទៅ ១២ខែ	១.៦៨៤.៩០៥	៦.៧៦១.៥២៣	៨៣១.០៩០	៣.៣៤៥.១៣៦
	៣.៥០១.៨៤៨	**១៤.០៥២.៩១៦**	**២.៤៧៥.៥៥៨**	**៩.៩៦៤.១២១**

(ឃ) តាមអត្រាការប្រាក់(ប្រចាំឆ្នាំ) ៖

សម្ព័ន្ធធនាគារ និង ធនាគារ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤
គណនីមានកាលកំណត់	២,៣០% – ៤,៧៦%	៣,៧០% – ៦,៧០%
គណនីសន្សំ	២,០០% – ៣,៥០%	០,០០% – ៤,២៥%
គណនីចរន្ត	០,១៤% – ៣,៩០%	០,១៤% – ៣,៤៩%
គណនីរំលងអធ្រាត្រ	០,២៥% – ៣,៧៧%	១,០០% – ៤,៣៩%

៧. ឥណទានផ្តល់ដល់អតិថិជន

សម្ព័ន្ធធនាគារ និង ធនាគារ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
វាស់វែងតាមតម្លៃដករំលស់				
ឥណទានពាណិជ្ជកម្ម	៧.៨៨១.៨៩៩	៣១.៦៣០.០៦១	៧.២៣៩.៩០២	២៩.១៤០.៦០៤
ឥណទានវិបារូបន៍	១.២៤៨.៧១០	៥.០១១.០៧៣	១.១៦៦.១៨០	៤.៦៩៣.៨៧៦
ឥណទានអ្នកប្រើប្រាស់៖				
ឥណទានគេហដ្ឋាន	៤១៧.៤៤៥	១.៦៧៥.២០៧	១៨៣.២៣៤	៧៣៧.៥១៧
ឥណទានផ្តល់ដល់បុគ្គលិក	៥១.៩៥០	២០៨.៤៧៥	៤៣.៩៦៤	១៧៦.៩៥៥
ឥណទានយានយន្ត	២០.៥០៣	៨២.២៧៩	១៨.៥៩៣	៧៤.៨៣៦
ឥណទានបុគ្គល	១២.៤៦៣	៥០.០១៤	៩.៧១៤	៣៩.០៩៩
ប័ណ្ណឥណទាន	៧.២៣៣	២៩.០២៤	៥.៧២៣	២៣.០៣៦
ឥណទានដុលសរុប	**៩.៦៤០.២០៣**	**៣៨.៦៨៦.១៣៣**	**៨.៦៦៧.៣១០**	**៣៤.៨៨៥.៩២៣**
សំវិធានធនលើការខាតបង់ពីឱនភាពនៃតម្លៃសរុប	**(២២៥.៧៨១)**	**(៩០៦.០៥៨)**	**(១៩២.២៧៧)**	**(៧៧៣.៩១៥)**
ឥណទានសុទ្ធសរុប	**៩.៤១៤.៤២២**	**៣៧.៧៨០.០៧៥**	**៨.៤៧៥.០៣៣**	**៣៤.១១២.០០៨**

សម្រាប់ព័ត៌មានលម្អិតអំពីឥណទានផ្តល់ដល់អចិជន សូមពិនិត្យកំណត់សម្គាល់៣១.១។

៨. មូលបត្រវិនិយោគ

សម្ព័ន្ធធនាគារ និង ធនាគារ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
មូលបត្រវិនិយោគវាស់វែងតាមតម្លៃដករំលស់ (*)	១២៣.៤៥៦	៤៩៥.៤២៩	៣០.០៦២	១២១.០០១
ប័ណ្ណរតនាគារវាស់វែងតាមតម្លៃដករំលស់ (**)	–	–	៣៦៩.៨៦៩	១.៤៨៨.៧២១
សរុប	១២៣.៤៥៦	៤៩៥.៤២៩	៣៩៩.៩៣១	១.៦០៩.៧២២
សំវិធានធនលើការខាតបង់ពីឱនភាពនៃតម្លៃ	(៥១២)	(២.០៥៥)	(៣៨៧)	(១.៥៥៧)
	១២២.៩៤៤	**៤៩៣.៣៧៤**	**៣៩៩.៥៤៤**	**១.៦០៨.១៦៥**

(*) រួមបញ្ចូលក្នុងមូលបត្រវិនិយោគ គឺជាការវិនិយោគចំនួន ៣០ លានដុល្លារអាមេរិក (១២០.៣៩០ លានរៀល) ក្នុងមូលបត្របំណុលសាជីវកម្មដែលចេញដោយក្រុមហ៊ុន ខេមបូឌាអ៊ែរផតអិនវេសមិនឯ.ក សម្រាប់ការសាងសង់ និងអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិតេជោ។ មូលបត្រវិនិយោគសារជីវកម្មត្រូវបានចេញផ្សាយនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ ដែលមានសុពលភាព៣ឆ្នាំ និងអត្រាការប្រាក់ ៥,៥០% ក្នុងមួយឆ្នាំ ហើយត្រូវបានបន្តនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ រយៈ៣ឆ្នាំ បន្ថែមទៀតក្នុងអត្រាការប្រាក់ ៦,២៥% ក្នុងមួយឆ្នាំ។

នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥ សម្ព័ន្ធធនាគារ និងធនាគារបានធ្វើការវិនិយោគទៅលើមូលបត្របំណុលសាជីវកម្មចំនួនពីរដែលមានតម្លៃ ៥ លានដុល្លារអាមេរិកក្នុងមួយប័ណ្ណ (២០.០៦៥ លានរៀល) ដែលចេញផ្សាយដោយក្រុមហ៊ុនស្នេថេក ជាយណាមិក ឯ.ក ដើម្បីផ្គត់ផ្គង់ថវិកាគម្រោងស្ថានីយ៍អគ្គិសនីពន្លឺព្រះអាទិត្យ ៦០MW ដែលមានរយៈពេល ១៥ ឆ្នាំ និងអត្រាការប្រាក់ស្មើនឹង មធ្យមភាគអត្រាការប្រាក់ SOFR ១៨០ ថ្ងៃ បូក ៣% និង មធ្យមភាគអត្រាការប្រាក់ SOFR ១៨០ ថ្ងៃ បូក ១,៦% ក្នុងមួយឆ្នាំ រៀងៗគ្នា។

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥ សម្ព័ន្ធធនាគារ និងធនាគារបានវិនិយោគក្នុងមូលបត្របំណុលរដ្ឋ ដែលចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានតម្លៃចរឹក ៥០ លានដុល្លារអាមេរិក (២០០.៦៥០ លានរៀល) និងតម្លៃទិញ ៥៣.៣៤៧.៦៥៧ លានដុល្លារអាមេរិក (២១៤.០៨៤ លានរៀល) ដែលមានរយៈពេល ១៥ ឆ្នាំ និងអត្រាការប្រាក់ ៤,៦% ក្នុងមួយឆ្នាំ។ នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៥ តម្លៃដករំលស់ នៃការវិនិយោគនេះគឺ ៥៣.៤៦៩.០៤៥ (២១៤.៥៧១ លានរៀល)។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ សម្ព័ន្ធធនាគារ និងធនាគារបានវិនិយោគក្នុងមូលបត្របំណុលសាជីវកម្ម ដែលមានតម្លៃចរឹក ៣០ លានដុល្លារអាមេរិក (១២០.៣៩០ លានរៀល) ដែលចេញផ្សាយដោយក្រុមហ៊ុន ដូនពេញ អាហ្គ្រីកូ ដើម្បីផ្គត់ផ្គង់ថវិកាសកម្មភាពកសិកម្មជាក់លាក់ដែលមានរយៈពេល ៨ ឆ្នាំ និងអត្រាការប្រាក់ ៥,២៥% ក្នុងមួយឆ្នាំ។

(**) ការវិនិយោគលើប័ណ្ណរតនាគារបរទេសបានដល់ពេលកំណត់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ឆ្នាំ២០២៤៖ មានរយៈពេលចន្លោះពី ៤ ដល់ ៩ ខែ ជាមួយអត្រាការប្រាក់ថេរ ចន្លោះពី ៤,៣៧% ដល់ ៥,០៦%)។

៩. ទ្រព្យសកម្មផ្សេងៗ

សម្ព័ន្ធធនាគារ	ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥		ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤	
	ពាន់ដុល្លារអាមេរិក	លានរៀល	ពាន់ដុល្លារអាមេរិក	លានរៀល
ប្រាក់កក់ និងបុរេប្រទាន	៤៥.១៥០	១៨១.១៨៧	៤៨.៨៣២	១៩៦.៥៤៩
ការទូទាត់ជាមុន	៣២.២៥៣	១២៩.៤៣១	២៤.៨១៦	៩៩.៨៨៤
